ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

# ដំណើររយៈពេល ២០ឆ្នាំ របស់កម្ពុជា ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

# CAMBODIA'S 20-YEAR JOURNEY AS A WTO MEMBER



# បុព្វកថា

ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ៩០ ប្រជាពលរដ្ឋកម្ពុជាបានរស់នៅក្រោមដំបូលសន្តិភាពដ៏ពេញលេញ ហើយប្រទេសជាតិមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចចាប់ផ្ដើមលូតលាស់ ដែលជាលទ្ធផលនៃការខិតខំប្រឹងប្រែង តាមរយៈការដាក់ចេញនូវចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ព្រមទាំងកម្មវិធីកែទម្រង់នានា ប្រកបដោយស្មារតីបុរេសកម្មនិងការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងគោលបំណងធានាកំណើនសេដ្ឋកិច្ច លើកកម្ពស់ភាពប្រកួតប្រជែង កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម។

ផ្អែកលើកត្តាបុព្វប្រធានទាំងនេះ រាជរដ្ឋាភិបាលបានសម្លឹងទៅរកការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់និងសកល ដែលក្នុងនោះ ការសម្រេចចិត្តលើនយោបាយ និងយុទ្ធសាស្ត្រផ្ដើមចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងចុងទសវត្សរ៍ឆ្នាំ៩០ គឺជាការសម្រេចចិត្តប្រកបដោយចក្ខុវិស័យ ថ្វីត្បិតតែមូលដ្ឋានសេដ្ឋកិច្ចរបស់កម្ពុជានាពេលនោះនៅមិនទាន់រឹងមាំក្តី ប៉ុន្តែរាជរដ្ឋាភិបាលបានធ្វើការថ្លឹងថ្លែងដោយម៉ត់ចត់រវាងផលចំណេញនិងបញ្ហាប្រឈម ក៏ដូចជាបទប្បញ្ញត្តិនិងគោលនយោបាយរបស់កម្ពុជានាពេលនោះជាមួយនឹងលក្ខខណ្ឌតម្រូវនៃការចូលជាសមាជិក WTO ព្រមទាំងកំណែទម្រង់ផ្សេងៗដែលកម្ពុជាត្រូវយកមកអនុវត្តក្រោយបានចូលជាសមាជិកពេញលេញ។ ឈរលើទស្សនវិស័យវែងឆ្ងាយ កម្ពុជាបានធ្វើការចរចាយ៉ាងសកម្មក្នុងដំណើរការចូលជាសមាជិក WTO រហូតបានបញ្ចប់ជាស្ថាពរនិងក្លាយជាសមាជិកទី១៤៨ នៃ WTO នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

ក្នុងនាមជាសមាជិកពេញសិទ្ធិនៃ WTO កម្ពុជាទទួលបានទីផ្សារក្រោមប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុត (MFN) ក៏ដូចជាប្រព្រឹត្តកម្មពិសេសនិងដោយឡែកដែលផ្ដល់ជូនកម្ពុជាក្នុងនាមជាសមាជិកអភិវឌ្ឍន៍តិចតួចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិនានារបស់ WTO ជាពិសេសការបើកច្រកទីផ្សារដែលមានភាពអនុគ្រោះ និងវិធានអនុគ្រោះមួយចំនួនទៀតផងដែរ។ កម្ពុជាក៏ទទួលបានផលចំណេញពីវិធានការគាំទ្រផ្សេងៗក្នុងទម្រង់ជាការកសាងសមត្ថភាពនិងជំនួយបច្ចេកទេសពី WTO និងពីសមាជិក និងស្ថាប័នដៃគូអភិវឌ្ឍន៍នានា ដែលការគាំទ្រទាំងនោះបានដើរតួយ៉ាងសំខាន់ដល់ការអនុវត្តកម្មវិធីកំណែទម្រង់នានាដែលកម្ពុជាបានសន្យានៅពេលចូលជាសមាជិក និងការសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍ជាតិផ្សេងៗទៀត ក៏ដូចជាពន្លឿនដល់ការធ្វើសមាហរណកម្មពេញលេញចូលក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។

ក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ កម្ពុជាសម្រេចបាននូវសមិទ្ធផលធំដាក់លាក់ជាច្រើន រួមមាន៖ កំណើនទំហំពាណិជ្ជកម្មពី ៤,៥ ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០០៤ រហូតដល់ ៤៧,៨៨ ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣ ដែលក្នុងនោះការនាំចេញបានកើនឡើងជាង ៩៤០% ជាមួយនឹងការកើនឡើងនៃទីផ្សារគោលដៅរហូតដល់ ១៥៥ ប្រទេស។ ការវិនិយោគដោយផ្ទាល់ពីបរទេសមានកំណើនពី ១១០ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០០០ ដល់ ៤,៩២ ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣។ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់របស់កម្ពុជាមានកំណើនពីត្រឹម ៤១០ ដុល្លារអាម៉េរិកក្នុងឆ្នាំ២០០៤ ដល់ ១ ៨៧៥ ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣។ កត្តាទាំងនោះ បានរួមចំណែកដល់ការកាត់បន្ថយអត្រាភាពក្រីក្រពី ៦០% ក្នុងឆ្នាំ២០០០ មកនៅត្រឹម ១៦% ក្នុងឆ្នាំ២០២២។ ជាមួយនោះដែរ ការចូលជាសមាជិក WTO បានជំរុញដល់ការប្រែក្លាយកម្ពុជាពីប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកស្ទើរតែទាំងស្រុងលើវិស័យកសិកម្ម ទៅជាសេដ្ឋកិច្ចមានឧស្សាហូបនីយកម្ម

និងពិពិធកម្មខ្ពស់ ដែលអនុញ្ញាតឱ្យកម្ពុជានាំចេញនូវទំនិញជាច្រើនមុខ ក្នុងវិស័យសម្លៀកបំពាក់ ទាំងវិស័យកសិកម្ម កម្មន្តសាល និងឧស្សាហកម្ម រួមមាន អង្ករ ដំឡូងមី ស្វាយចន្ទី កៅស៊ូ សំលៀកបំពាក់ ស្បែកជើង កាបូបធ្វើដំណើរ ទោចក្រយាន គ្រឿងអេឡិចត្រូនិក បរិក្ខារបង្គុំយានយន្ត និងទំនិញមានតម្លៃបន្ថែមក្នុងស្រុកជាច្រើនមុខទៀត។ សមាជិកភាពនៃ WTO បានផ្តល់ឱ្យកម្ពុជានូវឱកាសបង្កើនសមត្ថភាពស្ថាប័ននិងមន្ត្រីក្នុងការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងតំបន់មួយចំនួនទៀត ដើម្បីបើកច្រកទីផ្សារបន្ថែមពីលើច្រកទីផ្សារអនុគ្រោះដែលទទួលបានក្រោម WTO។ សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងអំពីភាពជោគជ័យនៃការអនុវត្តគោលនយោបាយសេដ្ឋកិច្ចមួយ ដោយយកវិស័យពាណិជ្ជកម្មជាកំលាំងចលករចម្បងក្នុងការរុញច្រានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ធ្វើឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យម ៧% ក្នុងរយៈពេល ២០ ឆ្នាំកន្លងមកមុននឹងការកើតឡើងនូវវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០១៩។

ជាមួយនឹងបរិវត្តកម្មសង្គម-សេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់កម្ពុជា ក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ក្នុងនាមជាសមាជិក WTO កម្ពុជាក៏បានរួមចំណែកជាមួយនឹងសមាជិកដទៃទៀត ក្នុងការចរចាយ៉ាងសកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងនូវវិធានពាណិជ្ជកម្មពហុភាគី និងគាំទ្រដល់កំណែទម្រង់របស់អង្គការនេះឱ្យទៅជាស្ថាប័នពាណិជ្ជកម្មសកលមួយ ប្រកបដោយបរិយាបន្ន សមធម៌ និងប្រសិទ្ធភាព ដោយមានការអភិវឌ្ឍជាស្នូល។ កម្ពុជាគឺជាប្រទេសអភិវឌ្ឍន៍តិចតួចដំបូងគេ ដែលបានបង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ WTO និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ក្នុងឆ្នាំ២០១៧ ហើយបានបំពេញតួនាទីយ៉ាងស័ក្តិសមជាប្រធានសម្របសម្រួលនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងការបម្រើផលប្រយោជន៍ទូលំទូលាយជូនដល់ក្រុមប្រទេសសមាជិកអភិវឌ្ឍន៍តិចតួចជាសមាជិក និងបានធ្វើជាជនបង្គោលតាមវិស័យនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្នុងការពិភាក្សានិងចរចាលើប្រធានបទសំខាន់ និងមានអត្ថប្រយោជន៍ដល់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច។ កិច្ចខិតខំប្រឹងប្រែងនេះ បានបង្ហាញពីការវាយតម្លៃខ្ពស់ចំពោះសារៈសំខាន់របស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលមាន WTO ជាស្នូល ក៏ដូចជាឆ្លុះបញ្ចាំងពីការអភិវឌ្ឍឡើងនូវសមត្ថភាពពេញលេញនិងការរីកចម្រើននូវសក្តានុពលរបស់កម្ពុជា ក្នុងការចូលរួមពិភាក្សាលើបញ្ហាផ្សេងៗ និងរួមចំណែកដល់ការរកដំណោះស្រាយ និងធ្វើឱ្យប្រសើរឡើងនៃក្របខណ្ឌពាណិជ្ជកម្មសាកល ដើម្បីជាប្រយោជន៍ជាតិ។

ទន្ទឹមនឹងនេះ ក្នុងបរិការណ៍សេដ្ឋកិច្ចសកលដែលមានការប្រែប្រួលនិងមិនប្រាកដប្រជា កម្ពុជាត្រូវប្រឈមនឹងបញ្ហាថ្មីៗ រួមមាន ការប្រែប្រួលរចនាសម្ព័ន្ធនិងនិម្មាបនកម្មសេដ្ឋកិច្ច ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយដែលបង្កឱ្យមានសង្គ្រាមពាណិជ្ជកម្ម ការគាំពារនិយមនិងជាតិនិយម ក៏ដូចជាការប្រែប្រួលអាកាសធាតុ និងបរិវត្តកម្មដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល។ ក្នុងន័យនេះ កម្ពុជាត្រូវសម្របខ្លួនតាមនិន្នាការប្រែប្រួលសកលទាំងនេះ និងគិតគូរឱ្យបានម៉ត់ចត់អំពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសម្រាប់ដំណាក់កាលនីមួយៗ ក្នុងគោលបំណងសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ឈរលើទស្សនវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បី "កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព" ដែលគោលដៅចម្បង រួមមាន៖ ទី១-រក្សាចលនាការណ៍នៃសុខសន្តិភាព, កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម; និងទី២-កសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិ។

ផ្អែកលើសមិទ្ធផល និងចក្ខុវិស័យសំខាន់ៗ ដែលបានរំលេចក្នុងរបាយការណ៍ស្តីពី "ដំណើរ២០ឆ្នាំ របស់កម្ពុជាក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក" រៀបចំចងក្រងដោយក្រសួងពាណិជ្ជកម្ម ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរដល់ក្រសួងពាណិជ្ជកម្ម និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានចូលរួមបំ ពេញតួនាទីយ៉ាងល្អប្រសើរនិងអន្តរសកម្មក្រោមក្របខណ្ឌ WTO ក្នុងការអនុវត្តកាតព្វកិច្ច និងកសាងសង្គម-សេដ្ឋកិច្ចកម្ពុជា។

ខ្ញុំសូមសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅជូនដល់ឥស្សរជនឆ្នើម និងក្រុមអ្នកចរចាកម្ពុជាដែលដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលបានប្រើប្រាស់អស់កម្លាំងកាយចិត្ត ចូលរួមយ៉ាងសកម្មក្នុងការចរចាឱ្យកម្ពុជាចូលជាសមាជិក WTO បានយ៉ាងជោគជ័យ។ ស្នាដៃទាំងនេះ ឆ្លុះបញ្ចាំងពីកិច្ចសហការជាធ្លុងមួយ និងដោយមិនខ្លាចនឿយហត់ ក្នុងបុព្វហេតុនាំមកនូវការរីកចម្រើន និងវិបុលភាព ដើម្បីជាប្រយោជន៍ជាតិ និងប្រជាពលរដ្ឋខ្មែរទាំងអស់។

ថ្ងៃ អង្គារ ៦កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០២៤
**ប្រធានព្រឹទ្ធសភា**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

តាមរយៈការដាក់ចេញ និងអនុវត្តយ៉ាងត្រឹមត្រូវតាមយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនាពេលកន្លងមក កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្មទៅក្នុងតំបន់ និងពិភពលោក ក្នុងគោលដៅបង្កើតកាលានុវត្តភាពនៃវិមាត្រសេដ្ឋកិច្ចដ៏ធំធេង និងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ដែលក្នុងនោះការក្លាយជាសមាជិកទី១៤៨ នៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់កម្ពុជានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ តាមរយៈកិច្ចខិតខំប្រឹងប្រែងចរចាយ៉ាងសកម្មរបស់កម្ពុជាជាមួយសមាជិកនានាដែលបានចាប់ផ្តើមតាំងពីទសវត្សរ៍ឆ្នាំ៩០ ក្រោមការចង្អុលបង្ហាញ និងអនុសាសន៍យុទ្ធសាស្ត្រដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺជាការបោះជំហានជាប្រវត្តិសាស្ត្រ និងជាយុទ្ធសាស្ត្រដែលមានចក្ខុវិស័យវែងឆ្ងាយ។

ក្រោយការចូលជាសមាជិក WTO រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តកាតព្វកិច្ចកំណែទម្រង់គោលនយោបាយ និងច្បាប់ដែលកម្ពុជាបានសន្យាក្នុងពិធីសារនៃការចូលជាសមាជិក WTO ដើម្បីឱ្យរបបពាណិជ្ជកម្មកម្ពុជាមានសង្គតិភាពជាមួយនឹងវិធានរបស់អង្គការនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ និងធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធពាណិជ្ជកម្មជាច្រើន រួមមានច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម ច្បាប់ស្តីពីវិនិយោគ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត ដែលជាកាតព្វកិច្ចដែលកម្ពុជាបានសន្យាក្នុង WTO។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនផងដែរ ដើម្បីបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងនិន្នាការសកល ដែលក្នុងនោះ រួមមានគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផែនការយុទ្ធសាស្ត្រទាញយកប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងគោលនយោបាយជាតិជាក់លាក់តាមវិស័យ ដូចជាសម្រាប់ផលិតផលស្វាយចន្ទី ដំឡូងមី សូត្រ ជាដើម។

ទន្ទឹមនឹងការអនុវត្តកាតព្វកិច្ចដែលបានសន្យា ក្នុងនាមជាសមាជិកអភិវឌ្ឍន៍តិចតួចរបស់ WTO កម្ពុជាក៏ទទួលបាននូវអត្ថប្រយោជន៍ជាច្រើន ដូចជាច្រកចូលទីផ្សារទូលំទូលាយរួមជាមួយនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មដែលមិនជាប់ពន្ធគយនិងមិនជាប់កូតា ប្រព្រឹត្តកម្មពិសេសនិងដោយឡែក និងវិធានការអនុគ្រោះដទៃទៀតក្រោមក្របខ័ណ្ឌអង្គការ WTO ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មរបស់កម្ពុជា ឱ្យបានពេញលេញទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ កត្តាទាំងអស់នេះបានជួយឱ្យកម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម ដូចជាកំណើនសេដ្ឋកិច្ចខ្ពស់ កំណើនទំហំពាណិជ្ជកម្មនិងវិនិយោគ ពិពិធកម្មទំនិញនិងទីផ្សារនាំចេញ និងមូលដ្ឋានផលិតកម្ម ក៏ដូចជារួមចំណែកដ៏សំខាន់ក្នុង

ការបង្កើតការងារនិងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។

ឆ្នាំ២០២៤ គឺជាខួប២០ឆ្នាំ នៃដំណើររបស់កម្ពុជានៅក្នុង WTO។ ដើម្បីអបអរសាទរព្រឹត្តិការណ៍ដ៏ឧត្តុង្គឧត្តមនេះ ក៏ដូចជាឆ្លុះបញ្ចាំងអំពីតួនាទីនិងសមិទ្ធផលរបស់កម្ពុជាដែលសម្រេចបានក្នុងរយៈពេល២ទសវត្សរ៍កន្លងមក ក្រសួងពាណិជ្ជកម្មបានរៀបចំរបាយការណ៍សង្ខេបស្ដីពី **"ដំណើរ ២០ឆ្នាំ របស់កម្ពុជាក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក"**។ របាយការណ៍នេះបានរំលេចយ៉ាងប្រត្យក្ស អំពីតួនាទីនិងសកម្មភាពរបស់កម្ពុជាក្នុងនាមជាសមាជិក WTO ផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីនិងតំបន់ យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ច កំណែទម្រង់ក្នុងស្រុក កាលានុវត្តភាពនិងបញ្ហាប្រឈម និងជម្រើសគោលនយោបាយសម្រាប់ទិសដៅការងារបន្ទាប់។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ក្រសួងពាណិជ្ជកម្ម** ដែលបានដឹកនាំផលិតបាននូវឯកសារដ៏មានតម្លៃនេះ ហើយខ្ញុំក៏មានសេចក្ដីជឿជាក់យ៉ាងមុតមាំថា របាយការណ៍នេះនឹងក្លាយជាឯកសារដ៏មានសារៈសំខាន់មួយសម្រាប់ការយល់ដឹងរបស់សាធារណជន ហើយក៏នឹងផ្ដល់នូវធាតុចូលសម្រាប់ទិសដៅការងារសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្មកម្ពុជាក្នុង WTO និងបម្រើជាឯកសារជំនួយក្នុងការងារសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងអ្នកស្រាវជ្រាវ។ ជាពិសេស ឯកសារនេះបានឆ្លុះបញ្ចាំងអំពីជំហានជាប្រវត្តិសាស្ត្រ និងយុទ្ធសាស្ត្រនៃការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកល ក្នុងប្រវត្តិសាស្ត្រកម្ពុជាផងដែរ ក្រោមការសម្រេចចិត្តដ៏ត្រឹមត្រូវ និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ថ្ងៃ អង្គារ ៦កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម និងក្នុងនាមខ្លួននាងខ្ញុំផ្ទាល់ នាងខ្ញុំសូមគោរពសម្តែងនូវកតញ្ញុតាធម៌ និងការដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងគណៈរដ្ឋមន្ត្រីក្នុងបណ្តាអាណត្តិកន្លងមក ដែលបានកំណត់ទិសដៅ និងចក្ខុវិស័យយ៉ាងមុតស្រួច ព្រមទាំងបានធ្វើការសម្រេចចិត្តយ៉ាងត្រឹមត្រូវបំផុតជាប្រវត្តិសាស្ត្រ ក្នុងការនាំយកព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ គុណូបការៈដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ជូនជាតិមាតុភូមិលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម ពិតជាធំធេង និងមិនអាចកាត់ថ្លៃបានសម្រាប់ព្រះរាជាណាចក្រកម្ពុជា និងជនរួមជាតិខ្មែរទាំងអស់។

ជាមួយគ្នានេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសម្តែងនូវការកោតសរសើរយ៉ាងក្រៃលែងជូនចំពោះសមាជិកទាំងអស់នៃក្រុមការងារចរចាកម្ពុជាចូលជាសមាជិក WTO មានសមាជិកសរុបទាំងអស់១១៦ រូប ដែលដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** និងជាប្រធានក្រុមចរចាកម្ពុជា ដែលបានដឹកនាំក្រុមការងារ និងចូលរួមការចរចាយ៉ាងសកម្ម ឱ្យទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ នាងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានដឹកនាំ និងចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់ និងត្រឹមត្រូវ នូវកំណែទម្រង់វិស័យពាណិជ្ជកម្មឱ្យស្របតាមវិធានក្រោមក្របខណ្ឌ WTO និងទាញយកសក្តានុពលពេញលេញពីសមាជិកភាពនេះ ឱ្យក្លាយជាឧត្តមភាពយ៉ាងពិតប្រាកដសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនេះដែរ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានផ្តល់ការគាំទ្រជាជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដល់កម្ពុជាក្នុងដំណើរការចរចាចូលជាសមាជិក WTO និងក្រោយការចូលជាសមាជិក ដែលការគាំទ្ររបស់ស្ថាប័នអន្តរជាតិទាំងនេះ ពិតជាមានសារៈសំខាន់ក្នុងការរួមចំណែកជួយឱ្យការចរចា និងការអនុវត្តកំណែទម្រង់របស់កម្ពុជាទទួលបានជោគជ័យដ៏ត្រចះត្រចង់។

ជាចុងក្រោយ នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានបន្តរក្សាសមិទ្ធផលសម្រេចបាន និងដឹកនាំនាវាកម្ពុជាប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម នាងខ្ញុំសូមប្តេជ្ញាបំពេញកិច្ចការងារឱ្យកាន់តែសកម្មខ្លាំងក្លាបន្ថែមទៀត និងចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោល-នយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នាំមកនូវការអភិវឌ្ឍភាពរីកចម្រើនលូតលាស់ ភាពសម្បូររុងរឿង ស្ថិតស្ថេរ ចីរកាល ជូនជាតិ និងមាតុភូមិកម្ពុជាជាដរាបតរៀងទៅ។

ថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

## សហនិពន្ធ៖

លោក Cato Adrian និងលោក Angelo Silvy, អតីតបុគ្គលិក ផ្នែកត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម នៃអង្គការពាណិជ្ជកម្មពិភពលោក, និងជាអ្នកជំនាញខាងគោលនយោបាយពាណិជ្ជកម្ម និងការចូលជាសមាជិក។

## គាំទ្រដោយ៖

| | | |
|---|---|---|
| - ឯកឧត្តម | សុខ សុភ័ក្ត្រ | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម |
| - ឯកឧត្តម | ពេជ ឫទ្ធី | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម |
| - ឯកឧត្តម | ឡុង កែមវិចិត្រ | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ |
| - ឯកឧត្តម | សួន ប្រសិទ្ធ | អគ្គរាជទូត និងជាប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស (អ.ព.ព) |
| - ឯកឧត្តម | Sven CALLEBAUT | ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម |
| - លោក | អេង សុធីរ័ន្ត | អគ្គនាយករងសេវាពាណិជ្ជកម្ម |
| - លោក | សុខ ប៊ុនថន | អគ្គនាយករងពាណិជ្ជកម្មអន្តរជាតិ |
| - លោក | សៀង ហុង | ប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ (ផ.ផ.ច.) |
| - លោក | គង់ សុខហេង | ទីប្រឹក្សាពាណិជ្ជកម្មនៃ អ.ព.ព |
| - លោក | សួស អ៊ឹមសូជីវី | ទីប្រឹក្សាពាណិជ្ជកម្មនៃ អ.ព.ព |
| - លោក | គង់ សុធារ៉ា | អនុប្រធាននាយកដ្ឋាន ផ.ផ.ច. |
| - លោក | ណែន ចាន់សាមុត | អនុព័ន្ធពាណិជ្ជកម្មនៃ អ.ព.ព |
| - លោក | តេង ជីវ័ន្ត | ប្រធានការិយាល័យនៃនាយកដ្ឋាន ផ.ផ.ច. |
| - លោកស្រី | ម៉ី ម៉ូលីកា | ប្រធានការិយាល័យនៃនាយកដ្ឋាន ផ.ផ.ច. |
| - លោក | ធឹម ភារ៉ា | អនុប្រធានការិយាល័យនៃនាយកដ្ឋាន ផ.ផ.ច. |

## ពិនិត្យ និងកែសម្រួលដោយ៖

ក្រុមការងារព័ត៌មាន ផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ របស់ក្រសួងពាណិជ្ជកម្ម

**បោះពុម្ពជាភាសាខ្មែរ និងភាសាអង់គ្លេស**
**លើកទី១ ខែតុលា ឆ្នាំ២០២៤**

**រក្សាសិទ្ធិបោះពុម្ព និងបោះផ្សាយដោយក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា**

**អាសយដ្ឋាន:** ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរសព្ទ:** ១២៦៦
**អ៊ីម៉ែល:** cabinet.info@moc.gov.kh

# មាតិកា


១. សេចក្តីផ្តើម ........................................................................................ 1
២. កម្ពុជានៅក្នុងWTO ........................................................................................ 4
៣. កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ និងទ្វេភាគី ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ............ 11
៤. យុទ្ធសាស្ត្រនៃកំណើនរបស់កម្ពុជា........................................................................ 17
៥. សមិទ្ធកម្មសេដ្ឋកិច្ច........................................................................................22
៦. សមាជិកភាព WTO និងកំណែទម្រង់ក្នុងស្រុក ................................................32
៧. កាលានុវត្តភាព និងបញ្ហាប្រឈមនៅពេលខាងមុខ ..............................................39
៨. ជម្រើសគោលនយោបាយ........................................................................................42
៩. សេចក្តីសន្និដ្ឋាន ........................................................................................45


# Contents


1. INTRODUCTION ........................................................................................59
2. CAMBODIA IN THE WTO ........................................................................................62
3. REGIONAL AND BILATERAL TRADE AGREEMENTS, TRADE PREFERENCES 69
4. CAMBODIA'S GROWTH STRATEGIES........................................................................................75
5. ECONOMIC PERFORMANCE ........................................................................................80
6. WTO MEMBERSHIP AND DOMESTIC REFORMS ..............................................90
7. OPPORTUNITIES AND CHALLENGES AHEAD ..............................................97
8. POLICY OPTIONS ........................................................................................100
9. CONCLUSION ........................................................................................103

# ដំណើររយៈពេល ២០ ឆ្នាំរបស់កម្ពុជាក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

## ១. សេចក្តីផ្តើម

១. រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត*កម្មវិធីជាតិសម្រាប់នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា* ដោយផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ ក្នុងឆ្នាំ១៩៩៤។ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាឡើងវិញចូលទៅក្នុងសេដ្ឋកិច្ចថ្នាក់តំបន់ និងពិភពលោក គឺជាធាតុមួយសំខាន់ក្នុងចំណោមធាតុចាំបាច់ជាច្រើននៅក្នុងកម្មវិធីនេះ។ កម្ពុជាបានដាក់ពាក្យស្នើសុំចូលជាសមាជិកស្ថាបនិកនៃ WTO ជាលើកដំបូងនៅខែតុលា ឆ្នាំ១៩៩៤ ហើយបន្ទាប់មកក្រុមការងាររបស់ WTO ក៏ត្រូវបានបង្កើតឡើង។ ក៏ប៉ុន្តែ ដំណើរការត្រួតពិនិត្យ និងផ្តល់ការយល់ព្រមលើសំណើកម្ពុជា ត្រូវបានពន្យារពេលដោយសារ WTO ត្រូវបានបង្កើតជាផ្លូវការនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ ហើយកម្ពុជាចាំបាច់ត្រូវឆ្លងកាត់ការចរចា ដើម្បីចូលជាសមាជិកដោយអនុលោមតាមមាត្រា XII នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស ដែលតម្រូវឱ្យកម្ពុជារៀបចំអនុស្សរណៈស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេស និងក្រុមការងារចរចារបស់រាជរដ្ឋាភិបាល។

២. ក្នុងចន្លោះពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានរៀបចំក្រុមការងារ និងឯកសារពាក់ព័ន្ធ និងបានបញ្ជូនអនុស្សរណៈស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាជាផ្លូវការជូនទៅ WTO នៅខែឧសភា ឆ្នាំ១៩៩៩។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាផ្លូវការចំនួន ៥ លើក ក្រោមអធិបតីភាពលោក Andrea Meloni (ប្រទេសអ៊ីតាលី) ដើម្បីធ្វើការពិភាក្សាលើលក្ខខណ្ឌនៃការចូលជាសមាជិកនេះ ចាប់ពីខែឧសភា ឆ្នាំ២០០១ រហូតដល់ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣។ សរុបមក គណៈប្រតិភូសមាជិកចំនួន ២៤ រូប (ដោយរាប់សហគមន៍អឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួនជាគណៈប្រតិភូតែមួយ) បានចូលរួមក្នុងក្រុមការងារ។

៣. សមាជិក WTO បានអនុម័តកញ្ចប់នៃការចូលជាសមាជិករបស់កម្ពុជា (ព្រមទាំងកញ្ចប់របស់ប្រទេសនេប៉ាល់) នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់ WTO លើកទីប្រាំ នៅទីក្រុង Cancún ប្រទេសម៉ិកស៊ិក កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣។ កម្ពុជា និងប្រទេសនេប៉ាល់បានក្លាយជាប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ដំបូងគេ ដែលបានចូលជាសមាជិក WTO តាមរយៈការចរចាយ៉ាងពេញលេញរបស់ភាគីក្រុមការងារ។ កម្ពុជាបានជូនដំណឹងជាផ្លូវការទៅកាន់លេខាធិការដ្ឋាន WTO ថា កម្ពុជាបានទទួលយកលក្ខខណ្ឌចូលជាសមាជិក នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ ហើយជាលទ្ធផល កម្ពុជាបានក្លាយជាសមាជិកទី១៤៨ របស់ WTO ក្នុងរយៈពេល ៣០ ថ្ងៃក្រោយមក ពោលគឺនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

៤. នៅដំណាក់កាលក្រោយៗទៀត ការចរចារបស់កម្ពុជាត្រូវបានជំរុញដោយសេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សានៃ WTO ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០២ (ឯកសារ WT/L/៥០៨) ដើម្បីជួយសម្រួល និងពន្លឿនការចូលជាសមាជិករបស់ LDCs តាមរយៈនីតិវិធីសាមញ្ញ និងដែលមានការសម្របសម្រួល។ ស្របតាមសេចក្តីសម្រេចនេះ សមាជិក WTO ត្រូវអនុវត្តការអត់ធ្មត់ក្នុងការស្នើសុំសម្បទាន និងការសន្យានានាក្នុងការធ្វើពាណិជ្ជកម្មទំនិញ និងសេវាកម្ម ដោយពិចារណាលើលក្ខខណ្ឌដែលមានស្រាប់របស់ WTO សម្រាប់ LDC។ ការទទួលអនុវត្តកិច្ចព្រមព្រៀងពហុភាគីរបស់ WTO (ស្តីពីលទ្ធកម្មរដ្ឋាភិបាល និងស្តីពីពាណិជ្ជកម្មផ្នែកយន្តហោះស៊ីវិល) ឬការចូលរួមក្នុងគំនិតផ្តួចផ្តើមតាមជម្រើសស្តីពី ការចូលច្រកទីផ្សារតាមវិស័យ មិនមែនជាបុរេលក្ខខណ្ឌសម្រាប់ទទួលបានសមាជិកភាពនៃ WTO នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ LDCs ដែលចូលជាសមាជិក WTO ត្រូវផ្តល់ការបើកច្រកទីផ្សារសម្រាប់ទំនិញ និងសេវាកម្ម ដែលសមស្របនឹងការអភិវឌ្ឍតម្រូវការផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្មរបស់ពួកគេ។ វិធានស្តីពីប្រព្រឹត្តកម្មពិសេស និងដោយឡែកដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនានារបស់ WTO និងលិខិតុបករណ៍គតិយុត្តដទៃទៀត អាចអនុវត្តបានចំពោះសមាជិកដែលជា LDCs ទាំងអស់។ រយៈពេលអន្តរកាល និងការរៀបចំនានាត្រូវបានផ្តល់ជូនដោយគិតគូរពីការអភិវឌ្ឍតម្រូវការផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្មរបស់សមាជិករៀងៗខ្លួន ភ្ជាប់ដោយផែនការសកម្មភាពជាក់លាក់ ដើម្បីជានាអនុលោមភាពតាមប្រព័ន្ធនៃWTO។ ការអនុវត្តនឹងត្រូវបានគាំទ្រដោយជំនួយបច្ចេកទេស និងវិធានការកសាងសមត្ថភាពដែលផ្តល់ដោយសមាជិក WTO តាមការចាំបាច់។

៥. របាយការណ៍ស្តីពីការចូលជាសមាជិករបស់កម្ពុជា (ឯកសារ WT/ACC/KHM/21) ដែលរួមបញ្ចូលពិធីសារនៃការចូលជាសមាជិករបស់ខ្លួន កំណត់ខចែង និងលក្ខខណ្ឌនានា ដើម្បីជានាបាននូវអនុលោមភាពតាមវិធានរបស់ WTO។ ការចូលច្រកទីផ្សារ ដែលកម្ពុជាបានផ្តល់ជូនសមាជិក WTO ដទៃទៀត ត្រូវបានចែងនៅក្នុងឯកសារ (WT/ACC/KHM/21/Add.1) ទំនិញ (និង WT/ACC/KHM/21/Add.2) សេវាកម្ម។

៦. ដំណើរការចូលជាសមាជិក បានដើរទន្ទឹមគ្នានឹងកំណែទម្រង់ក្នុងស្រុក ហើយកញ្ចប់ការចូលជាសមាជិកបានផ្តល់ផែនការលម្អិតសម្រាប់ការងារបន្ថែម បន្ទាប់ពីកម្ពុជាបានចូលជាសមាជិក WTO។ តាមរយៈការសម្រេចចិត្តរបស់ខ្លួនក្នុងការផ្សារភ្ជាប់គោលនយោបាយពាណិជ្ជកម្ម ទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី (MTS) កំណត់នៅក្រោម WTO រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់បរិយាកាសវិនិយោគ និងធុរកិច្ចដែលអាចព្យាករណ៍ទុកមុនបានដល់វិនិយោគិន ពាណិជ្ជករ និងភាគីពាក់ព័ន្ធផ្សេងទៀត។ សមាជិកភាពនៃ WTO ក៏ផ្តល់ជាវេទិកា និងមូលដ្ឋានសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាក់លាក់បន្ថែមទៀតផងដែរ។ កំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ដែលគាំទ្រដោយគោលនយោបាយពាណិជ្ជកម្មដែលសំឡឹងមើលទៅខាងក្រៅ បានធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើងយ៉ាងប្រត្យក្ស និងបានចូលរួមចំណែកលុបបំបាត់ភាពក្រីក្ររបស់ប្រជាជនមួយផ្នែកធំ។

# សក្ខីកម្ម

រំលឹកឡើងវិញ តើអ្វីជាពេលវេលាដ៏គួរឱ្យចងចាំបំផុត នៅក្នុងដំណើរការរបស់កម្ពុជាចូលជាសមាជិអង្គការពាណិជ្ជកម្មពិភពលោក (WTO)?

"អ្វីដែលគួរឱ្យចងចាំបំផុតមួយក្នុងការចូលជាសមាជិករបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO)គឺពេលវេលាដ៏ខ្លី ដែលកម្ពុជាត្រូវបញ្ចប់ការចរចាចូលជាសមាជិក មុនពេលការផុតរលត់នៃកិច្ចព្រមព្រៀងស្តីពី វាយនភណ្ឌនិងសំលៀកបំពាក់ និងលក្ខខណ្ឌរឹតត្បិតទាំងអស់ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៥។ ការបញ្ចប់ការចរចាចូលជាសមាជិកមុនឆ្នាំ២០០៥ ជួយឱ្យវិស័យនាំចេញរបស់កម្ពុជាចូលទៅកាន់ទីផ្សាររបស់សមាជិកដោយគ្មានកូតា។ ក្រៅពីនេះ កំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចពាណិជ្ជកម្មជាបន្តបន្ទាប់ ដែលបានសន្យាក្នុងដំណើរការចូលជាសមាជិក ដើរតួយ៉ាងសំខាន់ក្នុងការតម្រង់ទិសដៅសេដ្ឋកិច្ចកម្ពុជា ឱ្យឆ្ពោះទៅរកកំណើនប្រកបដោយចីរភាពបរិយាបន្ន និងភាពធន់ ដែលនេះឆ្លុះបញ្ចាំងថា ការចូលជាសមាជិកក្លាយជាពេលវេលាដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន។"

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ**

អតីតរដ្ឋមន្ត្រី និងជាប្រធានក្រុមអ្នកចរចាចូលជាសមាជិក WTO របស់កម្ពុជា

ក្នុងនាមស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប និងក្រោយមកជាអគ្គនាយក WTO ខ្ញុំបានរក្សាការចងចាំដ៏ច្បាស់នៃដំណើរការរបស់កម្ពុជាចូលជាសមាជិក WTO និងការចូលរួមរបស់ខ្ញុំផ្ទាល់ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ ការចងចាំនៃកិច្ចសហប្រតិបត្តិការ ការប្តេជ្ញាចិត្ត ភាពស៊ីសង្វាក់ កិច្ចខិតខំប្រឹងប្រែង និងការរៀបចំតាមលំដាប់លំដោយយ៉ាងជំនាញនៃកំណែទម្រង់សេដ្ឋកិច្ចចាំបាច់។ បន្ទាប់ពី ២០ឆ្នាំមកនេះ ខ្ញុំគិតថាកម្ពុជាគឺភស្តុតាងរស់រវើកនៃការបើកច្រកទីផ្សារពាណិជ្ជកម្ម ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ។"

**លោក Pascal Lamy**

អតីតអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក

(២០០៥-២០១៣)

# ២. កម្ពុជានៅក្នុង WTO

៧. កម្ពុជាបាន និងកំពុងចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ WTO ចាប់តាំងពីបានចូលជាសមាជិកក្នុងឆ្នាំ ២០០៤ ស្របតាមមាត្រា XII នៃកិច្ចព្រមព្រៀង WTO។ កម្ពុជាចូលរួមនៅក្នុងការងាររបស់គណៈកម្មាធិការ និងអនុគណៈកម្មាធិការសំខាន់ៗទាំងអស់របស់ WTO ក៏ដូចជា ក្រុមប្រឹក្សាចំនួនបី និងសន្និសីទថ្នាក់រដ្ឋមន្ត្រីដែលជាកម្រិតខ្ពស់។ កម្ពុជាក៏ចូលរួមយ៉ាងសកម្មក្នុងការចរចាលើបញ្ហាថ្មីៗ ដូចជា បញ្ហាជលផល កំណែទម្រង់ WTO និងយន្តការដោះស្រាយវិវាទ ការចាកចេញពីឋានៈ LDC ពាណិជ្ជកម្ម និងបរិស្ថាន និងគំនិតផ្តួចផ្តើមរួមថ្មីៗមួយដូចជា គំនិតផ្តួចផ្តើមរួមគ្នាស្តីពី *ការសម្របសម្រួលការវិនិយោគសម្រាប់ការអភិវឌ្ឍ* និងនៅក្នុងគំនិតផ្តួចផ្តើមផ្នែកបរិស្ថានស្តីពី *ការបំពុលដោយប្លាស្ទិក និងការជួញដូរប្លាស្ទិកប្រកបដោយនិរន្តរភាពបរិស្ថាន*។ កម្ពុជាគឺជាសមាជិកមួយនៃក្រុមចរចាជាច្រើន ដែលរួមមានសមាជិកប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី អាស៊ាន ប្រទេស G-90 និងប្រទេសអភិវឌ្ឍន៍តិចតួច(LDCs)។ កម្ពុជាបានផ្តល់នូវប្រព័ន្ធប្រជាជាតិអនុគ្រោះបំផុត (MFN) ដល់ដៃគូពាណិជ្ជកម្ម រួមទាំងប្រទេសដែលមិនមែនជាសមាជិក WTO ផងដែរ និងបានចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗថ្នាក់ជាតិ ជាមួយសមាជិកនានា តាមរយៈបទអន្តរាគមន៍របស់ខ្លួននៅក្នុងគណៈកម្មាធិការ និងអនុគណៈកម្មាធិការ និងក្រុមការងារផ្សេងៗ។

៨. ដោយយកចិត្តទុកដាក់យ៉ាងខ្លាំង និងយល់ច្បាស់អំពីអត្ថប្រយោជន៍នៃការចរចា និងចូលរួមឱ្យបានសកម្មក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី (MTS) កម្ពុជាបានក្លាយជាប្រទេស LDC បង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ WTO និងអង្គការអន្តរជាតិពាក់ព័ន្ធ ក្នុងឆ្នាំ២០១៧។ ក្នុងឆ្នាំ២០១៧ នោះផងដែរ កម្ពុជាបានបំពេញតួនាទីជាប្រធានសម្របសម្រួលក្រុម LDC ហើយកម្ពុជាក៏បានដើរតួនាទីជាជនបង្គោលសម្រាប់ក្រុម LDC នៅក្នុងប្រធានបទ/បញ្ហាផ្សេងៗ ដែលរួមមាន ទីផ្សារមិនជាប់ពន្ធគយ និងមិនជាប់កូតា (DFQF) និងកំណែទម្រង់ WTO។ សរុបមក កម្ពុជាបានអនុវត្តយ៉ាងសកម្ម ដើម្បីផលប្រយោជន៍របស់ក្រុម LDC នៅក្នុង WTO។ នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃ WTO លើកទី១១ នៅទីក្រុង Buenos Aires ក្នុងខែធ្នូ ឆ្នាំ២០១៧ កម្ពុជា តាងនាមឱ្យក្រុម LDC បានដាក់ចេញនូវសំណើមួយ ដែលផ្តោតសំខាន់លើប្រព្រឹត្តកម្មពិសេស និងដោយឡែករបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេស LDCs ដែលទាំងនេះជាចំណុចសំខាន់សម្រាប់ភាពជឿជាក់ និងប្រសិទ្ធភាពរបស់ MTS។ កម្ពុជាបានផ្តោតសំខាន់លើតម្រូវការពិសេសរបស់ LDCs ក្រោយពេលចូលជាសមាជិក ដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងកញ្ចប់នៃការសន្យា ចូលជាសមាជិក និងបានអំពាវនាវឱ្យលុបបំបាត់គ្រប់ទម្រង់នៃការគាំទ្រវិស័យកសិកម្មក្នុងស្រុកដែលប៉ះពាល់ដល់ពាណិជ្ជកម្ម ។ កម្ពុជាបានកត់សម្គាល់ថា គោលការណ៍នៃប្រព្រឹត្តកម្មពិសេស និងដោយឡែក គួរតែជាផ្នែកដ៏សំខាន់មួយនៃការចរចានាពេលអនាគត រួមមានការឧបត្ថម្ភធនលើវិស័យជលផល ដែល LDCs បានគាំទ្រ

និងបានអំពាវនាវឱ្យសមាជិកអនុវត្តឱ្យបានពេញលេញនូវសេចក្តីសម្រេចនេះ ដែលមានអំណោយផលដល់ LDCs ដោយបានអនុម័តនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី នាពេលកន្លងមក។[1]

៩. កម្ពុជាបានទទួលយកវិសោធនកម្មពិធីសារឆ្នាំ ២០០៥ ស្តីពីកិច្ចព្រមព្រៀង TRIPS នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ និងពិធីសារឆ្នាំ២០១៤ ទាក់ទងនឹងកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦។ កម្ពុជាបានទទួលយកក្រមនៃការអនុវត្តឱ្យបានល្អប្រសើរនូវផ្នែករបាំងបច្ចេកទេសក្នុងការធ្វើពាណិជ្ជកម្ម (TBT) របស់ WTO ក្នុងឆ្នាំ២០១៧។ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ កម្ពុជាបានតម្កល់លិខិតតុបករណ៍ ស្តីពីការអនុម័តកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល និងបន្តចូលរួមយ៉ាងសកម្មក្នុងការចរចាជំណាក់កាលទី ២ នៃកិច្ចព្រមព្រៀងនេះ។[2]

១០. ក្នុងអំឡុងពេលនៃការចរចាការចូលជាសមាជិករបស់ខ្លួន កម្ពុជាបានទទួលយកកាតព្វកិច្ចនានាដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងរបស់ WTO ដែលនឹងអនុវត្ត ឬអនុវត្តជាជំណាក់កាល ដូចបានពិពណ៌នានៅក្នុងរបាយការណ៍របស់ក្រុមការងារ ដែលបានធ្វើការចរចាអំពីការព្រមព្រៀងនេះ និងស្របតាមកាលវិភាគនៃការសន្យារបស់ខ្លួន។ វិស័យនៃគោលនយោបាយជាក់លាក់ ដែលចាំបាច់ត្រូវគ្របដណ្តប់ដោយវិធានWTO ត្រូវបានកំណត់។[3] វិស័យមួយចំនួនក្នុងចំណោមវិស័យទាំងនេះ បានមានវឌ្ឍនភាពតាំងពីមុនពេលដែលដំណើរការចូលជាសមាជិកត្រូវបានបញ្ចប់។ ជាងពាក់កណ្តាលនៃវិស័យទាំងនេះ ច្បាប់ និងបទប្បញ្ញត្តិបានអនុលោមតាមវិធាន WTO រួចរាល់ហើយ ឬអាចត្រូវបានធ្វើឱ្យមានអនុលោមភាព តាមរយៈសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល មុនពេលចូលជាសមាជិកមកម្ល៉េះ។[4]

---

1 ឯកសារ WTO លេខ WT/MIN(១៧)/៤០ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧

2 ព័ត៌មានអំពី WTO បានបើកមើលនៅ https://www.wto.org/english/news_e/news២៤_e/fish_០៦may២៤_e.htm.

3 សូមមើលៈ សុខ ស៊ីផាន់ណា (ឆ្នាំ២០០៥) មេរៀនពីការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសកម្ពុជា. វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី ឯកសារគោលនយោបាយ ADBI លេខ ៧ ១១/០៥ និង WTO ព្រឹត្តិបត្រព័ត៌មានស្តីពីការចូលជាសមាជិករបស់ប្រទេសកម្ពុជា. សូមមើលនៅ https://www.wto.org/english/thewto_e/acc_e/factsheet_cambodge_e.htm.

4 របាយការណ៍ក្រុមការងារ (ឯកសារ WTO លេខ WT/ACC/KHM/២១) បានអនុម័តនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣. ប្រធានបទដែលកំពុងជាចំណោទគឺៈ ការគ្រប់គ្រងតម្លៃ និងគោលការណ៍កំណត់តម្លៃ។ ពន្ធនិងបន្ទុកផ្សេងទៀតលើការនាំចូល ការលើកលែងពន្ធ តម្លៃពន្ធគយ ពន្ធក្នុងស្រុក ឧបសគ្គមិនមែនពន្ធ (កូតា អាជ្ញាប័ណ្ណនាំចូល។ល។) ការត្រួតពិនិត្យអភ័យឯកសិទ្ធិ ការរឹតបន្តឹងការនាំចេញ ការឧបត្ថម្ភធនឧស្សាហកម្ម វិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម (TRIMS) ពាណិជ្ជកម្មរបស់រដ្ឋ តំបន់សេដ្ឋកិច្ចសេរី និងតំបន់សេដ្ឋកិច្ចពិសេស ពាណិជ្ជកម្មឆ្លងកាត់ ឧបត្ថម្ភធនលើការនាំចេញផលិតផលកសិកម្ម ពាណិជ្ជកម្មវាយនភ័ណ្ឌ ការបោះពុម្ពផ្សាយព័ត៌មានអំពីពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ សមាជិកក្រុមការងាររួមមានៈ ប្រទេសអូស្ត្រាលី ប្រទេសកាណាដា ប្រទេសចិន សហភាពអឺរ៉ុប ប្រទេសឥណ្ឌា ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ ប្រទេសម៉ាឡេស៊ី ប្រទេសនូវែលសេឡង់ ប្រទេសប៉ាណាម៉ា ប្រទេសសិង្ហបុរី ប្រទេសចិន តៃប៉ិ ប្រទេសថៃ សហរដ្ឋអាមេរិក ប្រទេសវៀតណាមស៊ុយអេឡា។

# សក្ខីកម្ម

"កម្ពុជាបានទទួលធ្វើប្រធានសម្របសម្រួលក្រុមប្រទេស LDC ស្របពេលដែលកម្ពុជាកំពុងដំណើរការបង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការ WTO នៅដើមឆ្នាំ២០១៧។ ទោះបីជាបទពិសោធន៍និងធនធានមានកម្រិត កម្ពុជាបានខិតខំប្រើប្រាស់តួនាទីនេះ ដើម្បីបង្កើតកាលានុវត្តភាព និងពង្រីកកិត្យានុភាពរបស់កម្ពុជាក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើម្បីទាញយកផលប្រយោជន៍ជូនដល់ក្រុមប្រទេស LDC រួមទាំងកម្ពុជា ដែលជាសមាជិកមួយ ក្នុងចំណោមប្រទេស LDCs ចំនួន ៤៨ ដោយបានសហការយ៉ាងជិតស្និទ្ធិជាមួយលេខាធិការដ្ឋាន WTO,អង្គការ និងជំនាញការអន្តរជាតិពាក់ព័ន្ធ ហើយបានដឹកនាំនិងជំរុញក្រុមប្រទេស LDC ឱ្យមានសេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីរបស់ប្រទេស LDCs នៅសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១១ ក្នុងចុងឆ្នាំ២០១៧ នៅទីក្រុង Buenos Aires ប្រទេសអាហ្សង់ទីន ដែលបានអំពាវនាវឱ្យសមាជិក WTO យកចិត្តទុកដាក់លើការអនុវត្តឱ្យបានពេញលេញនូវសេចក្តីសម្រេច និងការសន្យាពាក់ព័ន្ធនឹងភាពបត់បែន និងអត្ថប្រយោជន៍ ដែលត្រូវផ្តល់ជូនប្រទេស LDCs ដែលក្នុងនោះមានប្រព័ន្ធអនុគ្រោះទីផ្សារដោយមិនជាប់ពន្ធគយនិងមិនជាប់កូតា និងប្រព្រឹត្តកម្មពិសេស និងដោយឡែក ជាដើម។"

**ឯកឧត្តម ពេជ ឫទ្ធី**
រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាអតីតអគ្គរាជទូតនិងប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍
នៃ ព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការ WTO និងអង្គការអន្តរជាតិ
ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស
(ឆ្នាំ២០១៧-២០១៨)

**១១.** ទាក់ទងនឹងការចងកាតព្វកិច្ចផ្នែកពន្ធគយ ក្រោយពីបានចូលជាសមាជិក WTO កម្ពុជាបានចរចាអំពីអត្រាពន្ធគយលើកចុងក្រោយ ដោយជាមធ្យមមានចំនួនអត្រា ២៨,១% សម្រាប់វិស័យកសិកម្ម និង ១៧,៧% សម្រាប់ផលិតផលមិនមែនកសិកម្ម និងអត្រាពន្ធគយទូទៅចំនួន ១៩,៩%។ កម្ពុជាបានចងកាតព្វកិច្ចលើពន្ធគយ និងថ្លៃបន្ទុកដទៃទៀតក្នុងអត្រា 0%។ កម្ពុជាបានកត់សម្គាល់ថា ខ្លួនមិនបានអនុវត្តកូតាអត្រាពន្ធគយណាមួយឡើយ និងបានប្តេជ្ញាចិត្តអនុវត្តការលើកលែងពន្ធគយ ដោយអនុលោមតាមបទប្បញ្ញត្តិរបស់ WTO និងអនុវត្តពន្ធក្នុងស្រុកដោយមិនរើសអើងចំពោះការនាំចូលនានា ដោយមិនគិតពីប្រភពដើមមកពីប្រទេសណាឡើយ។ កម្ពុជាក៏បានសន្យាផងដែរ ក្នុងការលុបបំបាត់ការរឹតត្បិតការនាំចូលក្នុងបរិមាណ រួមទាំងការហាមឃាត់កូតា និងប្រព័ន្ធអាជ្ញាប័ណ្ណ មិនឱ្យលើសពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥។ កម្ពុជាមិនបានផ្តល់ឧបត្ថម្ភធនសម្រាប់ការនាំចេញផលិតផលកសិកម្មនោះទេ និងចងត្រឹមកម្រិតសូន្យ នៅក្នុងតារាងសន្យារបស់ខ្លួន។ កម្ពុជាបានអនុវត្តការសន្យាយ៉ាងជាក់លាក់ នៅក្នុងអនុវិស័យសេវាកម្មទាំង ៩៤ ស្របតាមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវា (GATS)។

១២. ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីបានចូលជាសមាជិក កម្ពុជាកំពុងមមាញឹកក្នុងការអនុវត្តការសន្យារបស់ខ្លួនចំពោះ WTO ដែលមិនទាន់បានសម្រេច។ ក្នុងន័យនេះ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់ WTO ទាក់ទងនឹងបទប្បញ្ញត្តិស្តីពីគយ កម្ពុជាបានអនុម័តច្បាប់ស្តីពីគយថ្មីមួយ នៅខែកក្កដា ឆ្នាំ២០០៧ និងក្រោយមក បានអនុម័តបទប្បញ្ញត្តិគាំទ្រចំនួន ២៥ ទៀត ដើម្បីអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព។ បទប្បញ្ញត្តិនៃការអនុវត្ត រួមបញ្ចូលបញ្ញត្តិនានានៃវិស័យជាច្រើន ដែលរួមមាន ការវាយតម្លៃគយ នីតិវិធីប្រកាសពន្ធគយ ពន្ធគយ ការធ្វើចំណាត់ថ្នាក់ពន្ធទំនិញ ការបង្វិលសងប្រាក់ពន្ធគយ ការអនុញ្ញាតបណ្តោះអាសន្ន ដើងសារគយ ការដឹកជញ្ជូនទំនិញឆ្លងកាត់ និងបញ្ញត្តិដទៃទៀត។ ទាំងនេះបានអនុញ្ញាតឱ្យកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ អាចអនុវត្តបានមុនកាលបរិច្ឆេទដែលបានកំណត់។ វិស័យដទៃទៀតដែលត្រូវបានធ្វើកំណែទម្រង់ក្នុងស្រុកក្រោយពេលចូលជាសមាជិកនឹងត្រូវបានពិពណ៌នានៅខាងក្រោម។

១៣. ក្រៅពីការចូលរួមយ៉ាងសកម្មនៅក្នុង WTO កម្ពុជាបានគោរពតាមការសន្យា និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងអង្គការនេះបានយ៉ាងឆាប់រហ័ស។ ដើម្បីឆ្លុះបញ្ចាំងអំពីការអនុវត្តនេះ កម្ពុជាបានធ្វើសេចក្តីផ្តល់ព័ត៌មានចំនួន ១៣៧ ទៅកាន់គណៈកម្មាធិការក្រោម WTO ចាប់តាំងពេលចូលជាសមាជិក ក្នុងឆ្នាំ២០០៤ រហូតដល់ចុងខែមិថុនា ឆ្នាំ២០២៤។ ក្នុងចំណោមការធ្វើសេចក្តីផ្តល់ព័ត៌មានទាំងនោះ មានសេចក្តីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងរបាំងបច្ចេកទេសក្នុងការធ្វើពាណិជ្ជកម្ម (២៣), វិស័យកសិកម្ម (១៨), ប្រឆាំងនឹងការលក់បង្ខូចថ្លៃ (១៨), វិធានការតបត (១១), ការផ្តល់អាជ្ញាប័ណ្ណនាំចូល (២៣) និងការធ្វើសេចក្តីផ្តល់ព័ត៌មានដទៃទៀត។ មកទល់ពេលនេះ សមាជិក/អ្នកសង្កេតការណ៍ មិនទាន់បានបង្ហាញអំពីកង្វល់ពាណិជ្ជកម្មជាក់លាក់ (STCs) ណាមួយ ទាក់ទងនឹងការប្រើប្រាស់របាំងផ្នែកបច្ចេកទេសរបស់កម្ពុជាក្នុងការធ្វើពាណិជ្ជកម្ម ឬវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) ទៅកាន់គណៈកម្មាធិការ TBT និង SPS នោះទេ។ ម៉្យាងវិញទៀត កម្ពុជាមិនបានបង្ហាញនូវ STC ណាមួយ ទៅកាន់សមាជិក WTO នោះទេ ចាប់តាំងពីពេលចូលជាសមាជិក។

១៤. គិតត្រឹមខែកក្កដា ឆ្នាំ២០២៤ កម្ពុជាមិនបានជាប់ពាក់ព័ន្ធនឹងវិវាទណាមួយ នៅក្នុង WTO នោះទេ ទាំងក្នុងនាមដើមបណ្តឹង ឬជាចុងចោទ។ កម្ពុជាក៏មិនបានចូលរួមក្នុងជម្លោះណាមួយ ជាភាគីទីបីនោះទេ។ ចាប់តាំងពីក្លាយជាសមាជិកមក កម្ពុជាបានធ្វើការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម (TPR) ចំនួនពីរលើក ពោលគឺក្នុងឆ្នាំ២០១១ និងឆ្នាំ២០១៧។ TPR លើកទី ៣ របស់កម្ពុជា គ្រោងនឹងធ្វើឡើងនៅថ្ងៃទី២៦ និងទី២៨ ខែមីនា ឆ្នាំ២០២៥។

១៥. ក្នុងរយៈពេល ២០ឆ្នាំ ចាប់តាំងពីក្លាយជាសមាជិក WTO កម្ពុជាបានបង្ហាញសំណើជាច្រើនទៅកាន់គណៈកម្មាធិការផ្សេងៗក្រោម WTO ក្នុងនាមបុគ្គល ឬរួមជាមួយសមាជិក WTO ដទៃទៀត។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានចែករំលែកជាផ្លូវការអំពីបទពិសោធន៍របស់កម្ពុជាក្នុងការត្រៀមខ្លួនជាស្រេចចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងបញ្ហាប្រឈម ផលប៉ះពាល់ផ្នែកប្រព័ន្ធអនុគ្រោះ

ពាណិជ្ជកម្ម (GSP) ក្រោយការចាកចេញពីឋានៈ LDCs និងវិធានបូកបន្ថែម៖ ករណីកម្ពុជា និងសារៈសំខាន់នៃការកំណត់ភាពខុសគ្នានៃការទាញប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា។

**១៦.** នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៣ របស់ WTO នៅទីក្រុង Abu Dhabi ដែលប្រព្រឹត្តទៅក្នុងខែកុម្ភៈ ឆ្នាំ ២០២៤ កម្ពុជាបានរំលឹកឡើងវិញអំពីសារៈសំខាន់នៃ MTS ដែលផ្អែកលើច្បាប់ និងការធានាឱ្យបាននូវ WTO ដែលប្រកបដោយភាពរឹងមាំ ចាំបាច់ ប្រសិទ្ធភាព និងសមស្របតាមគោលបំណង។ កម្ពុជាបានរំឭកឡើងវិញនូវតម្រូវការក្នុងការផ្តោតការអភិវឌ្ឍជាគោលបំណងស្នូលរបស់ WTO និងគោលការណ៍ណែនាំអំពីគោលជំហរនៃការចរចាទាំងអស់ និងការយករបៀបវារៈរបស់សមាជិកដែលជា LDCs ទៅកាន់ជួរមុខនៃកិច្ចពិភាក្សាទាំងអស់។ កម្ពុជាបានសម្តែងសេចក្តីពេញចិត្តចំពោះសេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា WTO ស្តីពីការបន្តការអនុគ្រោះ DFQF ជាឯកតោភាគី ដែលអំណោយផលដល់ប្រទេសដែលបានចាកចេញពីឋានៈ LDC ដែលបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ និងបានសង្កត់ធ្ងន់ថា វាមានភាពចាំបាច់ក្នុងការបន្តពិភាក្សាលើសេចក្តីសម្រេចដែលផ្តល់ផលប្រយោជន៍ដល់ LDCs នៅក្នុងវិស័យនេះ និងការលើកលែងសេវាកម្ម (Services Waivers) និងវិធានដើមកំណើតទំនិញ ។ កម្ពុជាបានលើកឡើងអំពីសារៈសំខាន់នៃការលើកកម្ពស់ពាណិជ្ជកម្មរបស់ LDCs ដែលអនុញ្ញាតឱ្យប្រទេសទាំងនេះមានឥទ្ធិពលយ៉ាងពេញលេញនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងប្រើប្រាស់ពាណិជ្ជកម្មដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព។ ក្រុម LDC ត្រូវបានកត់សម្គាល់ថា បានផ្តោតសារៈសំខាន់យ៉ាងខ្លាំងលើដំណើរការកំណែទម្រង់ WTO ដែលគួរតែអនុវត្តចំពោះប្រព័ន្ធដោះស្រាយវិវាទ ដោះស្រាយបញ្ហាកសិកម្មសំខាន់ៗ ដោះស្រាយបញ្ហាដែលទាក់ទងនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPS) គិតគូរពីបញ្ហាបរិស្ថាន ជំរុញគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ថ្មី និងលើកកម្ពស់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថលសម្រាប់ពេលអនាគតប្រកបដោយបរិយាបន្ន។ កម្ពុជាបានចាត់ទុកជំហានទាំងនេះថាមានសារៈសំខាន់ក្នុងការធានាឱ្យមានប្រព័ន្ធពាណិជ្ជកម្មប្រកបដោយសមធម៌ មានតុល្យភាព និងបរិយាបន្ន ដែលមិនត្រឹមតែលើកកម្ពស់កំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារបរិស្ថាន សុខភាពសាធារណៈ និងសហគ្រាសធុនតូច និងមធ្យមផងដែរ។[5]

5 ឯកសារ WT/MIN(២៤)/ST/៤៩ របស់អង្គការពាណិជ្ជកម្មអន្តរជាតិ

# សក្ខីកម្ម

តើឯកឧត្តមយល់ឃើញថាអង្គការពាណិជ្ជកម្មពិភពលោក (WTO) មានការវិវឌ្ឍយ៉ាងដូចម្ដេចហើយតួនាទីរបស់អង្គការ WTO នឹងទៅជាយ៉ាងណានៅពេលអនាគត?

"នៅពេលបច្ចុប្បន្នអង្គការពាណិជ្ជកម្មពិភពលោក (WTO) កំពុងតែស្ថិតក្នុងដំណាក់កាលមួយ ដែលទាមទារឱ្យមានការគិតគូរឡើងវិញ អំពីតួនាទី និងភាពពាក់ព័ន្ធទៅនឹងបរិបទសេដ្ឋកិច្ចបច្ចុប្បន្ននិងបញ្ហាប្រឈមថ្មីៗ អង្គការ WTO ចាំបាច់ត្រូវធ្វើកំណែទម្រង់មួយចំនួន ជាពិសេសលើមុខងារចរចា ដើម្បីបង្កើតជាយន្តការ ចរចាមួយ ដែលអាចឱ្យសមាជិកទាំងអស់ចូលរួម និងសម្រេចបានលទ្ធផល។ ក្រៅពីនោះអង្គការ WTO ចាំបាច់ត្រូវតែដាក់ឱ្យដំណើរការឡើងវិញនូវប្រព័ន្ធដោះស្រាយវិវាទមួយពេញលេញ មានប្រសិទ្ធភាព និងងាយស្រួលប្រើប្រាស់ ដោយប្រព័ន្ធដោះស្រាយវិវាទជាសសរស្តម្ភមួយដ៏សំខាន់របស់អង្គការ WTO។ ជាមួយគ្នានេះ អង្គការ WTO ត្រូវធានាបានថា លទ្ធផលនៃការចរចាកិច្ចព្រមព្រៀងផ្តល់ផលប្រយោជន៍ដល់គ្រប់សមាជិក ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួច។ នាពេលអនាគត ស្របតាមសេចក្តីត្រូវការរបស់សមាជិកឆ្លើយតបទៅនឹងបញ្ហាសកល អង្គការ WTO គួរតែពង្រឹងស្មារតីពហុភាគី ធានាឱ្យបាននូវការធ្វើវិសោធនកម្ម និង បង្កើតឱ្យមានគោលនយោបាយពហុភាគីដែលការពារនិងផ្តល់ប្រយោជន៍លើយេនឌ័រ បរិស្ថាន ពាណិជ្ជកម្មអេឡិចត្រូនិកនិងការវិនិយោគ។"

**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា**
ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

"អង្គការ UNIDO មានមោទនភាពដោយបានសហការជាមួយប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ តាមរយៈកម្មវិធីភាពជាដៃគូរបស់ប្រទេស។ ជាមួយគ្នានេះ យើងបានបង្កើតយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មដ៏ទូលំទូលាយមួយ និងបានគាំទ្រដល់ប្រទេសកម្ពុជាក្នុងការបង្កើនតម្លៃបន្ថែមក្នុងស្រុក និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព ដើម្បីកែលម្អលទ្ធភាពចូលទៅកាន់ទីផ្សារសកល។ យើងនៅតែប្តេជ្ញាចិត្តក្នុងការជំរុញ ការធ្វើពិពិធកម្មសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់កម្ពុជា និងគាំទ្រដល់អាទិភាពគន្លឹះនៃរបៀបវារៈសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាល។"

**ឯកឧត្តម Gerd Müller,**
អគ្គនាយកនៃអង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃអង្គការសហប្រជាជាតិ (UNIDO)

# សក្ខីកម្ម

"នៅក្រោមកិច្ចព្រមព្រៀង វិធាន និងបទប្បញ្ញត្តិជាច្រើនរបស់អង្គការពាណិជ្ជកម្មពិភពលោក តែងមានភ្ជាប់នូវគោលការណ៍គ្រឹះសម្រាប់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដូចជា គោលការណ៍ប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ប្រព្រឹត្តកម្មដោយមិនរើសអើងក្នុងចំណោមនិងដោយបណ្តាប្រទេសជាសមាជិក និងការសន្យាជានាឱ្យមានតម្លាភាពក្នុងសកម្មភាពពាណិជ្ជកម្មនានារបស់បណ្តាប្រទេសជាសមាជិក។ ក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាមិនទាន់មានលទ្ធភាពអនុវត្តគោលការណ៍ទាំងនេះបានពេញលេញនៅឡើយទេ ប៉ុន្តែកម្ពុជាត្រូវបានផ្តល់ឱ្យនូវភាពបត់បែន ភាពអនុគ្រោះពាណិជ្ជកម្ម និងប្រព្រឹត្តិកម្មពិសេសនិងដោយឡែក ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនានានៃអង្គការនេះ។ ភាពបត់បែន និងអនុគ្រោះទាំងនោះ រួមមាន ការកំរិតមិនឱ្យបណ្តាសមាជិកដទៃទៀត លើកយកបញ្ហាមកចោទប្រកាន់ក្រោមវិធាននៃការដោះស្រាយវិវាទប្រឆាំងនឹងប្រទេសអភិវឌ្ឍន៍តិចតួចដូចជាកម្ពុជា ព្រមទាំងការពន្យារពេលសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងការអនុវត្តកាតព្វកិច្ចនានានៅក្រោមកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ជាដើម។ ទោះបែបនេះក៏ដោយ កាតព្វកិច្ចដែលកម្ពុជាមានបញ្ហាប្រឈមក្នុងការអនុវត្ត គឺការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គម និងការកែទម្រង់ច្បាប់ និងលិខិតបទដ្ឋានច្បាប់នានា ឱ្យមានសង្គតិភាពជាមួយនឹងកិច្ចព្រមព្រៀងក្រោមអង្គការ WTO និងការសន្យានានារបស់កម្ពុជាពេលចូលជាសមាជិកនៃអង្គការនេះ។ ទោះបីជាអង្គការ WTO ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កម្ពុជា ហើយកម្ពុជាក៏មិនត្រូវបានតម្រូវឱ្យកាត់បន្ថយពន្ធនាំចូល កំឡុងពេលចូល និងក្រោយពេលចូលជាសមាជិកនៃអង្គការនេះក៏ដោយ រាជរដ្ឋាភិបាលនៅតែយល់ឃើញថា ការរៀបចំឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងដៃគូពាណិជ្ជកម្មមានសក្តានុពលនានា គឺជាកត្តាលីករ ដ៏មានស្ថិរភាព និងមាននិរន្តរភាព ដើម្បីបន្តទទួលផលប្រយោជន៍ពាណិជ្ជកម្មបន្ថែមទៀតសម្រាប់រយៈពេលពេលវែង។ ការរៀបចំបែបនេះ ក៏ត្រូវបានជំរុញកត្តាមួយចំនួនទៀត ដូចជា លទ្ធភាពនៃការបាត់បង់នូវភាពអនុគ្រោះនានា និងភាពបត់បែនដែលធ្លាប់ទទួលបានក្រោមក្របខណ្ឌអង្គការ WTO, ឥទ្ធិពលនៃការដណ្តើមយកទីផ្សារពីកម្ពុជា ដោយប្រទេសជាសមាជិកដទៃទៀតដែលបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយគ្នាគេ ព្រមទាំងការរងឥទ្ធិពលពីការធ្វើសមាហរណកម្មកម្រិតតំបន់ ដែលមានលក្ខណៈទូលំទូលាយជាងសមាហរណកម្មក្រោមអង្គការ WTO។ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រាជរដ្ឋាភិបាលកម្ពុជាក៏អាចកំណត់នូវអាទិភាពនៃផលិតផលរបស់ខ្លួនដែលមានលទ្ធភាពប្រកួតប្រជែងសំដៅនាំចេញទៅកាន់ទីផ្សារដែលមានសក្តានុពលទាំងនោះទៀតផង៕"

**ឯកឧត្តម សុខ សុភ័ក្ត្រ**
រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

# ៣. កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ និងទ្វេភាគី ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

១៧. ការបើកចំហរទីផ្សារដែលបានកើតចេញពីសមាជិកភាព WTO របស់កម្ពុជាត្រូវបានជួយ និងពង្រឹងដោយកិច្ចខិតខំប្រឹងប្រែងផ្នែកសេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងតំបន់។ កម្ពុជាបានចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ហើយអាស៊ានគឺជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយការបរទេសរបស់កម្ពុជា ចាប់តាំងពីពេលនោះមក។ តាមរយៈអាស៊ាន កម្ពុជាបានចូលរួមក្នុងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងតំបន់ សុខដុមរមនីយកម្មនៃគោលនយោបាយ និងវិធានការ ដែលទាក់ទងនឹងពាណិជ្ជកម្ម និងការបន្តធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មជាមួយប្រទេសដៃគូសន្ទនារបស់អាស៊ាន។

១៨. បន្ថែមពីគោលនយោបាយសុខដុមនីយកម្មដូចមានរៀបរាប់ខាងលើនេះ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដោយផ្តោតលើទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងនៅក្នុងតំបន់ដែលមានការប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មពេញលេញទៅក្នុងសេដ្ឋកិច្ចពិភពលោក។ នាពេលបច្ចុប្បន្ន សមាហរណកម្មសេដ្ឋកិច្ចត្រូវបានដឹកនាំដោយ AEC Blueprint ឆ្នាំ២០២៥។ ផែនការមេស្តីពីការភ្ជាប់ទំនាក់ទំនងអាស៊ាន ឆ្នាំ២០២៥ កំណត់តំបន់យុទ្ធសាស្ត្រចំនួនប្រាំ ហើយកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ឆ្នាំ២០២១) បានជួយសម្រួលដល់ពាណិជ្ជកម្មអេឡិចត្រូនិករវាងសមាជិកអាស៊ានផងដែរ។ កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងអាស៊ានលើសេវាកម្មតាមរយៈកញ្ចប់ការសន្យាចំនួន ១០ ត្រូវបានជំនួសដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន (ATISA) ដែលបានចូលជាធរមានកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២១។

១៩. កម្ពុជាបានអនុវត្តលើសពីការសន្យារបស់ខ្លួនក្រោម WTO ធៀបនឹងសមាជិកអាស៊ានដទៃទៀតក្នុងវិស័យសេវាកម្ម ដូចជាការជួលគ្រឿងចក្រសំណង់ សេវាបកប្រែ និងបកប្រែ សេវារចនាទំព័រ និងសេវាទន្តសាស្ត្រ។ ការសន្យាលើ GATS បន្ថែម ត្រូវបានរួមបញ្ចូលនៅក្នុងកញ្ចប់ទីប្រាំបី (២០១០) និងទីប្រាំបួន (២០១៤) សម្រាប់សេវាកម្មអាជីវកម្មកុំព្យូទ័រ និងសេវាកម្មពាក់ព័ន្ធ សេវាជួល/ជួលដោយគ្មានប្រតិបត្តិករ និងសេវាកម្មអាជីវកម្មផ្សេងទៀត។ កម្ពុជាបានកាត់បន្ថយពន្ធលើទំនិញដែលមានប្រភពពីដៃគូអាស៊ានរបស់ខ្លួនជាជំហ៊ានបន្តបន្ទាប់ ដោយឈានដល់សេរីភាវូបនីយកម្មពេញលេញនៅឆ្នាំ ២០១៨។

២០. កម្ពុជាគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន ដែលផ្តោតលើការលុបបំបាត់ជាបណ្តើរៗនូវការរឹតត្បិតលើការវិនិយោគនៅក្នុងសមាជិកអាស៊ាន ដែលប៉ះពាល់ដល់វិស័យផលិតកម្ម

កសិកម្ម នេសាទ ព្រៃឈើ និងការជីកយករ៉ែ និងសេវាកម្មដែលកើតឡើងចំពោះវិស័យទាំងនេះ។ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការលើកកម្ពស់ការវិនិយោគទ្វេភាគីជាមួយ ២៧ ប្រទេស (ទោះបីជាកិច្ចព្រមព្រៀងមួយចំនួនមិនទាន់បានចូលជាធរមានក៏ដោយ)។ ជាទូទៅ កិច្ចព្រមព្រៀងទាំងនេះ ផ្តល់ប្រព្រឹត្តកម្មជាតិទៅវិញទៅមក និងរារាំងមិនឱ្យដកហូតកម្មសិទ្ធិ លើកលែងតែធ្វើឡើងក្នុងលក្ខណៈមិនរើសអើងសម្រាប់គោលបំណងតាមផ្លូវច្បាប់ ឬគោលបំណងជាសាធារណៈ និងមានសំណងភ្លាមៗ គ្រប់គ្រាន់ និងមានប្រសិទ្ធភាព។ ការផ្ទេរប្រាក់ចំណេញវិនិយោគទៅកាន់ប្រទេសដើមវិញ គឺត្រូវបានធានា ហើយវិវាទពាក់ព័ន្ធវិនិយោគគឺអាចបញ្ជូនទៅដោះស្រាយក្រោមមជ្ឈត្តកម្មផងដែរ។

២១. សមាជិកអាស៊ានបានរកឃើញពីភាពងាយស្រួលក្នុងការប្រើប្រាស់វេទិការួមមួយ ក្នុងការចរចាជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និងបានបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) អាស៊ានជាមួយប្រទេសចិន ឥណ្ឌា ជប៉ុន សាធារណរដ្ឋកូរ៉េ អូស្ត្រាលី និងនូវែលសេឡង់ និងហុងកុងនៃប្រទេសចិន។ អាស៊ាន និងដៃគូ FTA របស់ខ្លួនបានចាប់ផ្តើមធ្វើការចរចា ដើម្បីបង្កើតកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ក្នុងឆ្នាំ២០១២។ កិច្ចព្រមព្រៀង RCEP បានចូលជាធរមានសម្រាប់កម្ពុជា និងប្រទេសដៃគូភាគច្រើន នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។

២២. កិច្ចព្រមព្រៀង RCEP ធ្វើឱ្យការចូលរួមរវាងប្រទេសសមាជិកអាស៊ាន និងដៃគូ FTA របស់អាស៊ាន (ដកឥណ្ឌា) មានភាពទូលំទូលាយ និងកាន់តែស៊ីជម្រៅ និងរួមបញ្ចូលវិស័យថ្មីៗ ដូចជា លទ្ធកម្មរដ្ឋាភិបាលជាដើម។ ជារួម ក្នុងចំណោមជំពូកទាំង ២០ បទប្បញ្ញត្តិ RCEP ទាក់ទងនឹងពាណិជ្ជកម្មទំនិញ ដែលពាក់ព័ន្ធនឹងការលុបបំបាត់ពន្ធគយ និងការកាត់បន្ថយពន្ធ ការចូលទំនិញជាបណ្តោះអាសន្នដោយមិនបង់ពន្ធ ការលុបបំបាត់ទូទៅនៃការរឹតត្បិតបរិមាណ និងការពង្រឹងតម្លាភាព (ការផ្តល់អាជ្ញាប័ណ្ណនាំចូល វិធានការមិនមែនពន្ធ ថ្លៃសេវា និងទម្រង់បែបបទនានា)។ ជំពូកសេវាកម្មដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិក្នុងស្រុក គឺត្រូវបានសន្យាលើសពីក្នុង FTAs ដែលមានស្រាប់ ហើយការដកចេញជាទូទៅនៃវិធានការរឹតត្បិត និងការរើសអើងត្រូវបានដាក់បញ្ចូលក្នុងបញ្ជីអវិជ្ជមានក្នុងតារាងសន្យាផ្នែកសេវាកម្ម (Negative Lists for the Scheduling of Services Commitments)។ សេរីភាវូបនីយកម្មបន្ថែមទៀតនៃសេវាហិរញ្ញវត្ថុ សេវាទូរគមនាគមន៍ និងសេវាវិជ្ជាជីវៈត្រូវបានដោះស្រាយនៅក្នុងឧបសម្ព័ន្ធជាក់លាក់។ កិច្ចព្រមព្រៀង RCEP ក៏គ្របដណ្តប់លើការចូលបណ្តោះអាសន្ន និងការស្នាក់នៅរបស់រូបវន្តបុគ្គល ដែលចូលរួមនៅក្នុងពាណិជ្ជកម្មទំនិញ សេវាកម្ម ឬសកម្មភាពវិនិយោគផងដែរ។ ជំពូកវិនិយោគ ត្រូវបានបង្កើតឡើងនៅលើសសរស្តម្ភចំនួនបួន គឺ ការការពារ សេរីភាវូបនីយកម្ម ការជំរុញ និងការសម្រួល។ បទប្បញ្ញត្តិស្តីពីកម្មសិទ្ធិបញ្ញា ជាពិសេសទាក់ទងនឹងវិធានការការពារផ្នែកបច្ចេកវិទ្យា និងការអនុវត្តនៅក្នុងមជ្ឈដ្ឋានឌីជីថល គឺមានលើសពីកិច្ចព្រមព្រៀង TRIPS របស់ WTO។ បទប្បញ្ញត្តិស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផ្តោតលើបញ្ហាដូចជា ការការពារសិទ្ធិអ្នកប្រើប្រាស់ ការការពារព័ត៌មានអ្នកប្រើប្រាស់ ទីតាំងឧបករណ៍កុំព្យូទ័រ និងការបញ្ជូនព័ត៌មានឆ្លងដែន។ ផ្នែកផ្សេងទៀតដែលគ្របដណ្តប់ក្រោមកិច្ចព្រមព្រៀង RCEP រួមមាននីតិវិធីគយ កិច្ចសម្រួលពាណិជ្ជកម្ម វិធានដើម

កំណើតទំនិញ TBT និង SPS ឧបាស្រ័យពាណិជ្ជកម្ម គោលនយោបាយប្រកួតប្រជែង និងសហគ្រាសធុនតូច និងមធ្យម។

២៣. ក្របខណ្ឌអាស៊ានសម្រាប់ការចរចាពាណិជ្ជកម្មជាមួយភាគីទីបី មិនរារាំងសមត្ថភាពរបស់កម្ពុជាក្នុងការបន្តផលប្រយោជន៍ជាតិបន្ថែមទៀតទេ ហើយយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់សមាហរណកម្មក្នុងតំបន់តាមរយៈអាស៊ាន និងRCEP គឺត្រូវបានធ្វើឱ្យឆ្ពោះទៅមុខ និងបំពេញបន្ថែមដោយកិច្ចព្រមព្រៀង និងក្របខណ្ឌទ្វេភាគី។ ខណៈពេលដែលយន្តការទ្វេភាគីបង្កើននូវឱកាសទីផ្សារសម្រាប់ផលិតផលសំខាន់ៗដែលកម្ពុជានាំចេញនាពេលបច្ចុប្បន្ននេះ វាក៏ជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើពិពិធកម្មមូលដ្ឋានដែលមានស្រាប់ ជាពិសេសក្នុងវិស័យកសិកម្ម។

២៤. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ និងបានចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ CCFTA មាន ១៦ជំពូក ដែលគ្របដណ្តប់លើវិស័យសំខាន់ៗ ដូចជា៖ តម្លាភាពក្នុងនីតិវិធីគយនិងគោលនយោបាយពាណិជ្ជកម្ម និងការតម្រង់កិច្ចសម្រួលពាណិជ្ជកម្មរបស់កម្ពុជាឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ; កិច្ចសហប្រតិបត្តិការដើម្បីលើកកម្ពស់ស្តង់ដារអនាម័យ និងភូតគាមអនាម័យរបស់កម្ពុជា; កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការកសាងសមត្ថភាព ជាពិសេសក្នុងវិស័យកសិកម្ម; ការទាញប្រយោជន៍ពីគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវរបស់ចិនសម្រាប់ការសម្របសម្រួល និងការតភ្ជាប់គោលនយោបាយ; និងធ្វើការសិក្សារួមគ្នា ការចែករំលែកព័ត៌មាន និងការបង្កើតក្របខណ្ឌច្បាប់ដែលសមស្រប ដើម្បីសម្រួលដល់ពាណិជ្ជកម្មអេឡិចត្រូនិក។ ទាក់ទងនឹងពន្ធគយ កម្ពុជានឹងលុបចោល ឬកាត់បន្ថយពន្ធលើទំនិញ ៩០% នៃទំនិញទាំងអស់ សម្រាប់ការនាំចូលពីប្រទេសចិន ខណៈប្រទេសចិនលុបចោល ឬកាត់បន្ថយពន្ធលើទំនិញ ៩៧,៥៣% នៃទំនិញទាំងអស់ សម្រាប់ការនាំចូលពីកម្ពុជា (៩៤,៣៧% ក្រោម FTA អាស៊ាន-ចិន)។ ទំនិញដែលទទួលបានអត្ថប្រយោជន៍ពីពន្ធសូន្យភ្លាមៗរួមមានទំនិញកសិកម្មជាច្រើនប្រភេទ ដែលជាទំនិញនាំចេញសំខាន់របស់កម្ពុជា ក៏ដូចជាវាយនភណ្ឌ ស្បែកជើង គ្រឿងបន្លាស់អេឡិចត្រូនិក ម៉ូទ័រអេឡិចត្រូនិកនិងម៉ាស៊ីន កង់ និងខ្សែកាប។ CCFTA ក៏គ្របដណ្តប់លើការលើកកម្ពស់ការវិនិយោគ ហើយសម្រាប់ពាណិជ្ជកម្មផ្នែកសេវាកម្ម ភាគីទាំងពីរបានយល់ព្រមក្នុងការផ្តល់នូវកម្រិតខ្ពស់បំផុតនៃការទទួលបានដល់ដៃគូ FTA ផ្សេងទៀតរបស់ខ្លួន។

២៥. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA) ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ បានចូលជាធរមាននៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។ CKFTA មាន ១០ ជំពូកដែលបញ្ជាក់ពីការប្រកាន់ខ្ជាប់នូវច្បាប់ជាមូលដ្ឋាន និងលក្ខខណ្ឌតម្រូវរបស់ WTO ដែលគ្រប់ដណ្តប់លើពាណិជ្ជកម្មទំនិញ និងសេវាកម្ម រួមជាមួយបទប្បញ្ញត្តិបន្ថែម សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី ការត្រួតពិនិត្យ និងមជ្ឈត្តកម្ម។ សាធារណរដ្ឋកូរ៉េ សន្យាលុបបំបាត់ពន្ធ ៩៥,៦% នៃបន្ទាត់ពន្ធរបស់ខ្លួនសម្រាប់ទំនិញពីកម្ពុជា។ ពន្ធភាគច្រើនត្រូវបានលុបចោលភ្លាមៗ។ CKFTA ត្រូវបានគេរំពឹងថានឹងជំរុញការនាំចេញរបស់កម្ពុជានូវទំនិញវាយន

ភណ្ឌនិងកាត់ដេរ ស្បែកជើង កាបូប និងគ្រឿងបន្លាស់ ឧបករណ៍អេឡិចត្រូនិក កៅស៊ូ ផលិតផលវារីវប្បកម្ម និងទំនិញកសិកម្មជាច្រើនប្រភេទ (សាច់ ពោត ដំឡូង កាហ្វេ ផ្លែឈើ ម្ទេស គ្រាប់ស្វាយចន្ទី មៀន ថ្នាំជក់ជាដើម)។

**២៦.** កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយកម្ពុជា-អារ៉ាប់រួម (CEPA) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ និងចូលជាធរមាននៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ។ វិស័យសំខាន់ៗដែលមាននៅក្នុងជំពូក ១៨ នៃ CEPA ជាមួយប្រទេសអារ៉ាប់រួមគឺការលុបបំបាត់ពន្ធគយ (៩៧,៧% នៃខ្សែបន្ទាត់ពន្ធគយទាំងអស់) នីតិវិធីពន្ធគយដែលមានលក្ខណៈសាមញ្ញនិងរហ័ស វិធានការ TBT និង SPS ការផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ការពង្រឹងលទ្ធភាពទទួលបានទីផ្សារសម្រាប់អ្នកផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កម្មសិទ្ធិបញ្ញា និងការលើកកម្ពស់ការវិនិយោគទ្វេភាគីលើវិស័យនានាដូចជា ភស្តុភារ ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើដំណើរ និងថាមពលកកើតឡើងវិញ។ កម្ពុជារំពឹងថា CEPA នឹងផ្តល់ឱកាសបន្ថែមក្នុងការនាំចេញសាច់ គ្រាប់ធញ្ញជាតិ ផ្លែឈើ អាហារកែច្នៃ សម្លៀកបំពាក់ ស្បែកជើង និងទំនិញស្បែក។

**២៧.** កម្ពុជាគឺជាអ្នកទទួលផលប្រយោជន៍ក្រោមគម្រោង GSP របស់ប្រទេស អូស្ត្រាលី កាណាដា សហភាពអឺរ៉ុប អ៊ីស្លង់ ជប៉ុន កាហ្សាក់ស្ថាន នូវែលសេឡង់ ន័រវែស សហព័ន្ធរុស្ស៊ី ស្វ៊ីស តួកគី និងសហរដ្ឋអាម៉េរិក។ សម្រាប់ចក្រភពអង់គ្លេស ប្រព័ន្ធពាណិជ្ជកម្មប្រទេសអភិវឌ្ឍន៍ (DCTS) កំពុងជំនួសក្របខណ្ឌ GSP ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជាផងដែរ។ ប្រព័ន្ធអនុគ្រោះបន្ថែម (កាត់បន្ថយពន្ធគយ ឬពន្ធគយស្មើសូន្យ) សម្រាប់ការនាំចេញរបស់កម្ពុជា ត្រូវបានផ្តល់ដោយប្រទេសចិន ចិនតៃប៉ិ សាធារណរដ្ឋកៀហ្ស៊ីស៊ីស្ថាន តាជីគីស្ថាន សាធារណរដ្ឋកូរ៉េ និងប្រទេសឈីលី។

**២៨.** ការចូលទៅកាន់ទីផ្សារសហភាពអឺរ៉ុបដោយមិនបង់ពន្ធ និងគ្មានកូតាត្រូវបានផ្តល់ទៅឱ្យ LDCs រួមទាំងកម្ពុជាផងដែរ ស្របតាមគំនិតផ្តួចផ្តើមអ្វីៗគ្រប់យ៉ាងលើកលែងអាវុធ ចាប់តាំងពីឆ្នាំ២០០១។ ប៉ុន្មានឆ្នាំកន្លងមកនេះ កម្ពុជាបានក្លាយជាអ្នកទទួលផលពី EBA ដ៏សំខាន់បំផុតទីពីរ ។ ដោយសារការនាំចេញរបស់កម្ពុជាភាគច្រើន (៨៤%) ទទួលបានការព្យួរពន្ធក្រោមក្របខណ្ឌ EBA ហើយអត្រានៃការប្រើប្រាស់ប្រព័ន្ធអនុគ្រោះគឺមានកម្រិតខ្ពស់ (ប្រហែល ៩១%) ការនាំចេញរបស់កម្ពុជាមួយចំនួនក្នុងចំណោមបីភាគបួនកំពុងចូលទៅកាន់ទីផ្សារសហភាពអឺរ៉ុបដោយមិនបង់ពន្ធនាំចូល។

**២៩.** កិច្ចព្រមព្រៀងក្របខណ្ឌពាណិជ្ជកម្ម និងការវិនិយោគ (TIFA) ត្រូវបានចុះហត្ថលេខាជាមួយសហរដ្ឋអាម៉េរិកក្នុងឆ្នាំ២០០៦ ។ TIFA ជំរុញពាណិជ្ជកម្ម និងការវិនិយោគទៅវិញទៅមក និងផ្តល់វេទិកាទ្វេភាគីដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងគយ កិច្ចសម្របសម្រួលពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា។ ប្រទេសទាំងពីរបន្តទំនាក់ទំនងក្រោមក្របខណ្ឌនេះ។ កម្ពុជាបានក្លាយជាអ្នកទទួលផលប្រយោជន៍ក្រោមប្រព័ន្ធ GSP

របស់សហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៧ និងបានទទួលការអនុគ្រោះពន្ធរហូតត្រូវបានផុតកំណត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ការបន្តប្រព័ន្ធ GSP បាននិងកំពុងរង់ចាំការធ្វើសេចក្តីសម្រេចនៅក្នុងសភាអាមេរិក ចាប់តាំងពីពេលនោះមក។ ក្នុងឆ្នាំ២០២០ ការនាំចូលរបស់សហរដ្ឋអាមេរិក ពីកម្ពុជាក្រោមក្របខណ្ឌ GSP មានចំនួនសរុប ២,០៣ ពាន់លានដុល្លារអាមេរិក (ធៀបនឹងការនាំចូលសរុបចំនួន ៦,៦១ ពាន់លានដុល្លារអាមេរិក) ដែលធ្វើឱ្យកម្ពុជាក្លាយជាអ្នកទទួលផលប្រយោជន៍ពីប្រព័ន្ធ GSP ធំជាងគេទីបួន។

៣០. កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើកដំបូងរបស់ខ្លួនសម្រាប់ការលុបបំបាត់ការយកពន្ធត្រួតគ្នាជាមួយប្រទេសសិង្ហបុរី និងប្រទេសចិន ក្នុងឆ្នាំ២០១៦។ ចាប់តាំងពីពេលនោះមក កិច្ចព្រមព្រៀងលុបបំបាត់ការយកពន្ធត្រួតគ្នា បានចូលជាធរមានជាមួយសមាជិកអាស៊ានដទៃទៀត (ប្រទេសប្រ៊ុយណេដារូសាឡឹម ប្រទេសឥណ្ឌូណេស៊ី ប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសម៉ាឡេស៊ី) ផងដែរ ក៏ដូចជាសាធារណរដ្ឋកូរ៉េ និងហុងកុងប្រទេសចិន។ ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងជាមួយតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន (Macau SAR) និងតួកគី កំពុងដំណើរការ ហើយកម្ពុជាកំពុងពិចារណាលើការចរចាកិច្ចព្រមព្រៀងជាមួយហ្វីលីពីន ឡាវ មីយ៉ាន់ម៉ា បារាំង ជប៉ុន ម៉ារ៉ុក និងអារ៉ាប់រួម។

# សក្ខីកម្ម

"UNCTAD គឺជាទីភ្នាក់ងារដំបូងគេ ក្នុងការអនុវត្តកម្មវិធីជំនួយបច្ចេកទេសរយៈពេល ៥ឆ្នាំ ដើម្បីគាំទ្រដល់ការអនុវត្តការសន្យារបស់កម្ពុជា ក្នុងការចូលជាសមាជិក WTO ដែលខ្ញុំមានសេចក្តីរីករាយក្នុងការដឹកនាំកម្មវិធីនេះភ្លាមៗ បន្ទាប់ពីការចូលជាសមាជិក WTO របស់កម្ពុជា។ ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះកម្ពុជាបានកៀរគរយ៉ាងជោគជ័យនូវធនធានជំនួយសម្រាប់ពាណិជ្ជកម្មជពិសេសតាមរយៈ Trade SWAp។ កម្ពុជាអាចទាញយកប្រយោជន៍ពីបទពិសោធន៍ខ្លួនពាក់ព័ន្ធនឹង WTO តាមរយៈការបណ្តុះបណ្តាលអ្នកចរចានិងអ្នកបង្កើតគោលនយោបាយជំនាន់ក្រោយ ដោយហ្វឹកហ្វឺនពួកគេឱ្យចេះដោះស្រាយក្នុងការចរចាបច្ចុប្បន្ន និងអនាគត រួមទាំងការធ្វើសមាហរណកម្មនៃ AI។ ទីបំផុត ធុរជនគឺជាអ្នកធ្វើពាណិជ្ជកម្ម និងឈរជើងដើម្បីទទួលបានផលចំណេញច្រើនបំផុត ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការបន្តក្នុងការចូលរួមជាមួយវិស័យឯកជន ក្នុងការបង្កើតកម្មវិធី និងការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មនាពេលអនាគតក្នុងលក្ខណៈបរិយាបន្ន និងនិរន្តរភាព។"

**ឯកឧត្តម** Sven Callebaut,
ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម

"កម្ពុជាតែងតែជាអ្នកនាំមុខដែលគិតគូរជាមុន និងជាអ្នកអនុវត្តដ៏លេចធ្លោ ចំពោះការប្រើប្រាស់ជំនួយពីអង្គភាពពង្រឹងក្របខណ្ឌសមាហរណកម្មពាណិជ្ជកម្ម (EIF) ដោយបានបង្ហាញសមត្ថភាពរបស់ខ្លួនក្នុងការបញ្ជ្រាបពាណិជ្ជកម្មក្នុងផែនការអភិវឌ្ឍជាតិរបស់ខ្លួន និងអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)។ភស្តុតាងបានបង្ហាញឱ្យឃើញថាកម្ពុជាបានអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវជំនួយកសាងសមត្ថភាពដ៏មានផលិតភាពពី EIF ដើម្បីពង្រឹងវិស័យ អង្ករ សូត្រ នេសាទ ដំឡូងមី និងទេសចរណ៍ ក្នុងនោះ វិស័យអង្ករមានភាពលេចធ្លោ ដោយការនាំចេញអង្ករបានកើនឡើងពី ១៤០ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៥ ដល់ ៤១៤ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ ដែលធ្វើឱ្យកម្ពុជាជាប់លំដាប់ថ្នាក់ជាប្រទេសនាំចេញអង្ករកំពូលទាំង១០ លើពិភពលោក។ ជាចុងក្រោយ ភាពជាអ្នកដឹកនាំរបស់កម្ពុជាលើពាណិជ្ជកម្មឌីជីថល មិនបានកំណត់ត្រឹមតែការបង្កើតវេទិកាពាណិជ្ជកម្មអេឡិចត្រូនិក និងភ្ជាប់ប្រព័ន្ធប្រតិវេទន៍គយ និងប្រៃសណីយ៍ក្នុងការជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មលើកញ្ចប់បញ្ញើប៉ុណ្ណោះទេ ថែមទាំងបានផ្តល់នូវជំនួយកសាងសមត្ថភាពដល់អាជីវកម្មខ្នាតតូចដើម្បីប្រើប្រាស់ឱកាសនេះ ហើយ EIF ក៏មានមោទនភាពដែលបានចូលរួមចំណែកក្នុងការងារនេះ។"

**លោក** Ratnakar Adhikari,
នាយកប្រតិបត្តិ នៃអង្គភាពពង្រឹងក្របខណ្ឌសមាហរណកម្មពាណិជ្ជកម្ម (EIF)

# ៤. យុទ្ធសាស្ត្រនៃកំណើនរបស់កម្ពុជា

៣១. វឌ្ឍនភាពត្រូវបានដឹកនាំ និងពង្រឹងបន្តបន្ទាប់តាមរយៈផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរយៈពេល ៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៨។ ផែនការ៥ឆ្នាំដំបូងចំនួន២ ត្រូវបានអនុវត្តក្រោមយុទ្ធសាស្ត្រត្រីកោណ (១៩៩៨-២០០៣) ដោយសង្កត់ធ្ងន់ទៅលើ៖ (i) សន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ; (ii) សមាហរណកម្មទៅក្នុងសហគមន៍តំបន់ និងអន្តរជាតិ និង (iii) ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ។ សមាជិកភាពក្នុងអាស៊ាន (១៩៩៩) និង WTO (២០០៤) និងការទទួលបានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប គឺជាលទ្ធផលសំខាន់នៃយុទ្ធសាស្ត្រត្រីកោណ។

៣២. គោលដៅយុទ្ធសាស្ត្រចំនួន៤ នៃយុទ្ធសាស្ត្រចតុកោណ (២០០៤-២០២៣) គឺកំណើនការងារ សមធម៌ និងប្រសិទ្ធភាព។ ដោយអនុវត្តជាបួនដំណាក់កាលផ្សេងគ្នា ផ្លូវ ទឹក ភ្លើង និងប្រជាជន គឺជាវិស័យអាទិភាព ដែលកំណត់របៀបវារៈសម្រាប់ការអភិវឌ្ឍ។ ចំណែកឯហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសការសាងសង់ និងការកែលម្អផ្លូវថ្នល់ គឺជាចំណុចសំខាន់ក្នុង២ដំណាក់កាលដំបូង និងប្រជាជន ពោលគឺការអភិវឌ្ឍធនធានមនុស្ស បានក្លាយជាអាទិភាពចម្បងនៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀត។ ក្នុងដំណាក់កាលទី៤ ការអភិវឌ្ឍធនធានមនុស្ស (ចតុកោណទី១) ផ្តោតលើការលើកកម្ពស់គុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា; ការបណ្តុះបណ្តាលវិជ្ជាជីវៈ; ការលើកម្ពស់សុខភាពនិងអាហារូបត្ថម្ភ; និងពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ កត្តាជំរុញសំខាន់ៗនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច (ចតុកោណទី ២) គឺការកែលម្អផ្នែកដឹកជញ្ជូន និងការតភ្ជាប់ (ការដឹកជញ្ជូន ថាមពល និងវេទិកាឌីជីថល) ការអភិវឌ្ឍប្រភពសំខាន់ៗ និងថ្មីនៃកំណើនសេដ្ឋកិច្ច ការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម៤.០ និងការលើកកម្ពស់សេវាកម្មហិរញ្ញវត្ថុ និងធនាគារ។ ការអភិវឌ្ឍវិស័យឯកជន និងការងារ (ចតុកោណទី៣) ពាក់ព័ន្ធនឹងការលើកកម្ពស់ទីផ្សារការងារ សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព ភាពជាដៃគូសាធារណៈនិងឯកជន និងការលើកកម្ពស់ការប្រកួតប្រជែង។ ចតុកោណទី៤ - ការអភិវឌ្ឍរួម និងនិរន្តរភាព - មានធាតុផ្សំដូចជា (i) ការជំរុញការអភិវឌ្ឍកសិកម្ម និងជនបទ (ii) ការពង្រឹងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ និងវប្បធម៌ (iii) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង (iv) ការធានានិរន្តរភាពបរិស្ថាន និងការត្រៀមខ្លួនសម្រាប់ការប្រែប្រួលអាកាសធាតុ។

៣៣. យុទ្ធសាស្ត្របញ្ចកោណ គឺជាគម្រោងរយៈពេលវែងដែលត្រូវអនុវត្តជា ៥ដំណាក់កាល ក្នុងរយៈពេល ២៥ ឆ្នាំជាមួយនឹងអភិបាលកិច្ច និងទំនើបកម្មនៃស្ថាប័នរដ្ឋជាស្នូល។ ការជំរុញគោលនយោបាយចម្បងនៃដំណាក់កាលទី១ (២០២៤-២០២៨) គឺជាការអភិវឌ្ឍធនធានមនុស្ស។ ជាតុផ្សំបន្ថែមគឺ៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់ការប្រកួតប្រជែង (បញ្ចកោណទី២) ការអភិវឌ្ឍវិស័យឯកជន និងការងារ

(បញ្ញកោណទី៣) ការអភិវឌ្ឍប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន (បញ្ញកោណទី៤) និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល (បញ្ញកោណទី៥)។

៣៤. យុទ្ធសាស្ត្របញ្ញកោណមានគោលដៅជាយុទ្ធសាស្ត្រចំនួនប្រាំ ហើយវិស័យអាទិភាពទី៥ បច្ចេកវិទ្យា ត្រូវបានបន្ថែមទៅអាទិភាពចំនួន៤ ដែលបានកំណត់ពីមុន (មនុស្ស ផ្លូវថ្នល់ ទឹក និងភ្លើង)។ គោលបំណងរួមគឺដើម្បីធានានូវកំណើនសេដ្ឋកិច្ចដែលធន់នឹងវិបត្តិឱ្យបានក្នុងរង្វង់ ៧% ជាមធ្យមក្នុងមួយឆ្នាំ។ ការធ្វើឱ្យកើនឡើង និងប្រសើរឡើងនៃការងារ ជាពិសេសសម្រាប់យុវជន គួរតែត្រូវបានបង្កើតតាមរយៈការអប់រំប្រកបដោយគុណភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមតម្រូវការទីផ្សារ។ ភាពក្រីក្រនឹងត្រូវកាត់បន្ថយបន្ថែមទៀត មកត្រឹមតិចជាង ១០% នៃចំនួនប្រជាជន ជាមួយនឹងវិសមភាពសេដ្ឋកិច្ចតិចជាងមុន និងប្រព័ន្ធគាំពារសង្គម ចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃទាបជាងមុន និងសេវាសាធារណៈកាន់តែប្រសើរ។ បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងពាណិជ្ជកម្ម នឹងត្រូវបានគាំទ្រដោយស្ថាប័នសាធារណៈជាមួយនឹងការពង្រឹងសមត្ថភាព និងអភិបាលកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអភិបាលកិច្ចផ្នែកឯកជនកាន់តែរឹងមាំ។ កម្ពុជាក៏មានគោលដៅអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយនិរន្តរភាព កាន់តែមានភាពធន់ និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សមភាពយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការពង្រឹងការវិនិយោគសាធារណៈពាក់ព័ន្ធនឹងការបញ្ចេញសារធាតុកាបូនទាប និងលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកសេដ្ឋកិច្ចបៃតងថ្មី។

៣៥. ដោយអនុលោមតាមក្របខណ្ឌ ដែលបានកំណត់ដោយផែនការសេដ្ឋកិច្ច-សង្គមរយៈពេល៥ឆ្នាំ និងយុទ្ធសាស្ត្រ រយៈពេលវែង កម្ពុជាបានបង្កើត និងអនុវត្តគោលនយោបាយជាក់លាក់មួយចំនួននៅក្នុងវិស័យអាទិភាព។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ គឺសំដៅស្វែងរកការពង្រីកមូលដ្ឋានឧស្សាហកម្មរបស់កម្ពុជា និងប្រែក្លាយពីការពឹងផ្អែកលើកម្លាំងពលកម្ម ទៅជាការពឹងផ្អែកលើជំនាញនិងចំណេះដឹង ដែលរួមបញ្ចូលកម្រិតតំបន់ជាមួយនឹងការតភ្ជាប់ទៅកាន់ខ្សែច្រវាក់តម្លៃសកល។ វិធានការរួមមានការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស (SEZs) និងតំបន់ឧស្សាហកម្មដើម្បីទាក់ទាញការវិនិយោគ ការលើកទឹកចិត្តសម្រាប់អាជីវកម្មខ្នាតតូចនិងមធ្យមដើម្បីធ្វើឱ្យមានលក្ខណៈផ្លូវការ និងទំនើបកម្ម; ការពង្រឹងនូវបទប្បញ្ញត្តិឱ្យកាន់តែរឹងមាំនិងអំណោយផលដល់កំណើនឧស្សាហកម្ម; និងការសម្របសម្រួលនៃផ្នែកការអភិវឌ្ឍជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងហិរញ្ញវត្ថុពាក់ព័ន្ធ។ គោលនយោបាយនេះក៏ចង្អុលបង្ហាញពីតួនាទីនៃឧស្សាហកម្ម ក្នុងការលើកកម្ពស់វិស័យផ្សេងទៀតដូចជា កសិកម្ម និងសេវាកម្មជាដើម។ ច្បាប់ស្តីពីការវិនិយោគ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ផ្តល់សម្បទានពន្ធ និងការលើកទឹកចិត្តពិសេសៗដល់វិនិយោគិនក្នុងស្រុក និងបរទេសដូចៗគ្នា សម្រាប់គ្រប់សកម្មភាពឧស្សាហកម្ម និងសេវាកម្មជាច្រើន រួមទាំងវិស័យដែលកំពុងរីកចម្រើនដូចជា ថាមពលបៃតង ហេដ្ឋារចនាសម្ព័ន្ធ សុខភាព អេឡិចត្រូនិក/គ្រឿងម៉ាស៊ីន ផ្នែកឧស្សាហកម្ម និងការកែច្នៃកសិផល។

៣៦. តាមរយៈក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ កម្ពុជាជំរុញភាពជាសហគ្រិន និងការច្នៃប្រឌិតឌីជីថល ដើម្បីលើកកម្ពស់និរន្តរភាពសេដ្ឋកិច្ច។ ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ បច្ចេកវិទ្យាឌីជីថលបានក្លាយជាផ្នែកសំខាន់មួយនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមបង្កើតឱកាសសម្រាប់អាជីវកម្មប្រកបដោយភាពច្នៃប្រឌិត បង្កើនប្រសិទ្ធភាព និងផលិតភាព និងការកែលម្អបរិយាកាសប្រកួតប្រជែង។ ជំងឺរាតត្បាតសកលកូវីដ-១៩ បានពង្រឹងនិន្នាការនេះ។ រាជរដ្ឋាភិបាលមើលឃើញថាឌីជីថលភាវូបនីយកម្ម និងបរិវត្តកម្មឌីជីថល ពោលគឺការបង្កើតរាជរដ្ឋាភិបាលសេដ្ឋកិច្ច និងសង្គមឌីជីថលរួម ដែលជាឧបករណ៍ក្នុងការជំរុញវិស័យដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយភាពធន់។ ក្នុងន័យនេះ ក្របខណ្ឌនេះមានភាពប្រទាក់ក្រឡាជាមួយគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២-២០៣៥ ជាមួយនឹងចក្ខុវិស័យនៃ"ការបង្កើតរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាពលរដ្ឋ និងកសាងទំនុកចិត្តរបស់ពួកគេ តាមរយៈការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ"។ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវបានប្រគល់នូវភារកិច្ចសម្របសម្រួលទូទាំងប្រទេស និងអនុវត្តគោលនយោបាយនេះ។

៣៧. កម្ពុជាគឺជាអ្នកនាំមុខមួយ និងជាអ្នកប្រើប្រាស់ដ៏សកម្មនូវភាពជាដៃគូនៃកម្មវិធីក្របខណ្ឌពង្រឹងសមាហរណកម្មពាណិជ្ជកម្ម (EIF) សម្រាប់ LDCs។ ការសិក្សាវិភាគសមាហរណកម្មពាណិជ្ជកម្ម (DTIS) ជាលើកដំបូងរបស់កម្ពុជា ដែលជាមូលដ្ឋានគ្រឹះនៃ IF និង EIF នៅក្នុងសមាហរណកម្មពហុភាគី និងការបញ្ជ្រាបបញ្ហាពាណិជ្ជកម្មទៅក្នុងផែនការអភិវឌ្ឍជាតិ មានតាំងពីខែវិច្ឆិកា ឆ្នាំ២០០១ និងត្រួសត្រាយផ្លូវសម្រាប់ការចូលជាសមាជិក WTO របស់កម្ពុជា។ ដូចគ្នានឹងអ្នកទទួលផលប្រយោជន៍ដទៃទៀតពី EIF គម្រោងជំនួយដើម្បីពាណិជ្ជកម្មបន្តបន្ទាប់របស់កម្ពុជា បានកើតមកពី DTIS និងគោលនយោបាយ និងផែនការសកម្មភាពពាក់ព័ន្ធ។ DTIS របស់កម្ពុជាត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០០៧ ដោយកំណត់ពាណិជ្ជកម្មគឺជាក្បាលម៉ាស៊ីនសំខាន់កំណើនយ៉ាងសំខាន់ និងការធ្វើពិពិធកម្មការនាំចេញ ដើម្បីគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច (យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា-CTIS ២០០៧)។ ការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨ (CTIS ២០១៤) - ត្រូវបានកំណត់ថាជាវិស័យអាទិភាព៖ ការធ្វើពិពិធកម្មទីផ្សារ និងពាណិជ្ជកម្ម; កិច្ចសម្រួលពាណិជ្ជកម្ម; វិធានការ TBT និង SPS; បរិយាកាសវិនិយោគសម្រាប់សកម្មភាពនាំចេញ; និងកម្មសិទ្ធិបញ្ញា។ ការវិភាគ SWOT ត្រូវបានអនុវត្តលើខ្សែច្រវាក់តម្លៃនាំចេញសំខាន់ៗ (សម្លៀកបំពាក់ ស្បែកជើង កម្មន្តសាល និងគ្រឿងបង្គុំផុនស្រាល អាហារកែច្នៃ ផលិតផលជលផល អង្ករ ដំឡូងមី កៅស៊ូ ទេសចរណ៍ និងផលិតផលសូត្រ) ដើម្បីកំណត់បញ្ហាប្រឈម និងឱកាស។

៣៨. រាជរដ្ឋាភិបាលបានបំពេញតួនាទីកាន់តែរឹងមាំជាបណ្តើរៗក្នុងការធ្វើឱ្យលម្អិតនៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម ហើយ CTISU ២០១៩ ដែលគ្របដណ្តប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ គឺជាការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រពេញលេញដំបូងបង្អស់ដែលដឹកនាំដោយរដ្ឋាភិបាល និងគ្រប់គ្រងដោយ

រដ្ឋាភិបាល។ ក្រសួងពាណិជ្ជកម្មបច្ចុប្បន្នកំពុងបង្កើតក្របខណ្ឌគោលនយោបាយពាណិជ្ជកម្មកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០។ អភិក្រមថ្មីនេះបានដាកចេញពីទស្សនទានរបស់ DTIS ដែលកម្ពុជាត្រៀមខ្លួនសម្រាប់ការចាកចេញពីឋានៈ LDC និងអនុវត្តឱ្យបានពេញលេញស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីធានាបាននូវភាពធន់ផ្នែកសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព។

៣៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានចាប់ផ្តើមយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច (EDS) នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងភាពមិនច្បាស់លាស់ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ ការប្រកួតប្រជែងរវាងមហាអំណាចសេដ្ឋកិច្ចពិភពលោកដែលបង្ហាញពីភាពផុយស្រួយនៃប្រព័ន្ធសេដ្ឋកិច្ចប្រទាក់ក្រឡាជាសកល និងការបាត់បង់ផលប្រយោជន៍នៃភាពអនុគ្រោះពាណិជ្ជកម្មដោយសារហេតុផលមិនមែនពាណិជ្ជកម្ម។ EDS គឺជាឧបករណ៍បុរេសកម្មក្នុងការធ្វើសមាហរណកម្មកម្ពុជាបន្ថែមទៀតនៅក្នុងសេដ្ឋកិច្ចតំបន់និងសកល ធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ពង្រីកសក្តានុពលសេដ្ឋកិច្ចរបស់កម្ពុជា និងទាញយកអត្ថប្រយោជន៍ពេញលេញពីកាលានុវត្តភាពថ្មីៗ ទន្ទឹមនឹងការការពារ និងលើកកម្ពស់ផលប្រយោជន៍ជាតិសំខាន់ៗរបស់កម្ពុជា ដើម្បីទទួលបានវិបុលភាព និងការអភិវឌ្ឍសង្គម។

៤០. EDS តភ្ជាប់គោលនយោបាយការបរទេសនិងការទូត ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយសារយុទ្ធសាស្ត្រនេះសំដៅលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការលើកកម្ពស់ការផ្លាស់ប្តូរផ្នែកទេសចរណ៍ វប្បធម៌ និង កីឡា។ ជំនាញខាងការទូតសេដ្ឋកិច្ចត្រូវបានប្រមូលផ្តុំ និងបណ្តុះបណ្តាល; អាទិភាពសំខាន់នៃពាណិជ្ជកម្មគឺការធ្វើពិពិធកម្មការនាំចេញ (ផលិតផល និងទីផ្សារ) ការកំណត់ផលិតផល និងសេវាកម្មថ្មីៗ និងការប្រើប្រាស់ FTAs ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងតំបន់។ ការបង្កើនការយល់ដឹងអំពីឱកាសវិនិយោគ និងការលើកទឹកចិត្ត ដែលមានការរៀបចំបេសកកម្ម និងទស្សនកិច្ចសម្រាប់វិនិយោគិន និងភាពជាដៃគូសាធារណៈ និងឯកជនដ៏មានសក្តានុពល គឺជាធាតុផ្សំនៃយុទ្ធសាស្ត្រដើម្បីបង្កើនលំហូរនៃ FDI។ លទ្ធផលដែលសម្រេចបានក្នុងអំឡុងពេល៣ឆ្នាំដំបូង គឺជាធាតុចូលសម្រាប់យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ២០២៤-២០២៨ នាពេលខាងមុខ។

# សក្ខីកម្ម

"ខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពជោគជ័យ ដែលជំរុញដោយវិស័យពាណិជ្ជកម្ម ចាប់តាំងចូលជាសមាជិក WTO ក្នុងខែតុលា ឆ្នាំ២០០៤។ ចាប់តាំងពីឆ្នាំ ២០០៥ ផលិតផលសរុបក្នុងស្រុករបស់កម្ពុជាក្នុងន័យចារឹក (nominal terms) កើនឡើងជិត ៦ដង ខណៈ ផលិតផលសរុបក្នុងស្រុកក្នុងមនុស្សម្នាក់ បានកើនឡើងជិត ៤ដង គឺចាប់ពី ៥៥០ ដុល្លារ ទៅ ២,៤៦០ ដុល្លារអាម៉េរិក។ ពាណិជ្ជកម្មគឺជាកត្តាជំរុញដ៏សំខាន់នៃកំណើននេះ៖ ក្នុងរយៈពេលដូចគ្នានេះ បរិមាណពាណិជ្ជកម្មទំនិញ និងសេវាកម្មរបស់កម្ពុជា បានកើនឡើងជិត ៦៧០%។ ការនាំចេញទំនិញគើនឡើងច្រើនជាង ៧ដង ខណៈដែល ការនាំចេញសេវាពាណិជ្ជកម្មកើនឡើងជិត ៤ដង។ ឥលូវនេះ កម្ពុជាកំពុងរំពឹងថានឹងចាកចេញពីឋានៈប្រទេស អភិវឌ្ឍន៍ តិចតួចនៅឆ្នាំ២០២៧។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមក្នុងលក្ខណៈស្ថាបនារបស់កម្ពុជានៅក្នុង WTO ជាពិសេសក្នុងនាមជាអ្នកដឹកនាំក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ហើយសូមលើកទឹកចិត្តកម្ពុជាឱ្យបន្តភាពជា អ្នកដឹកនាំរបស់ខ្លួនក្នុងការគាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគី ក្នុងអំឡុងពេលដ៏លំបាកនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តមអគ្គរាជទូត សួន ប្រសិទ្ធ ព្រមទាំងក្រុមការងារ ចំពោះការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការគាំទ្រ WTO និងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។"

**លោកជំទាវបណ្ឌិត Ngozi Okonjo Iweala,**
អគ្គនាយិកានៃអង្គការពាណិជ្ជកម្មពិភពលោក

"វិស័យវាយនភ័ណ្ឌរបស់យើងទទួលបានច្រកទីផ្សារអន្តរជាតិជាច្រើន និងផ្តល់ជូនអ្នកទិញអន្តរជាតិនូវទំនុកចិត្តខ្ពស់លើការផ្គត់ផ្គង់ និងការអនុវត្តការធ្វើពាណិជ្ជកម្មស្តង់ដារអន្តរជាតិរបស់យើងផងដែរ។ វិស័យនេះក៏មានការរីកចម្រើនយ៉ាងមហិមា ដោយក្រុមហ៊ុនដែលមានតែប្រមាណប្រហែល ១០ នៅឆ្នាំ១៩៩៦ ពេលនេះបានរីកដល់ជាង ២០០០ ដែលអាចនាំចេញក្នុងទឹកប្រាក់ប្រមាណ ១២ ប៊ីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ និងផ្តល់ការងារជូនប្រជាពលរដ្ឋកម្ពុជាប្រមាណជា ១ លាននាក់ ដែលអាចមានចំណូលផ្គត់ផ្គង់មនុស្សបានប្រហែល ៤ លាននាក់"។

**ឯកឧត្តមឧកញ៉ា វ៉ាន់ ស៊ូអៀង**
ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធានកិត្តិយសនៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

# ៥. សមិទ្ធកម្មសេដ្ឋកិច្ច

៤១. កម្ពុជាបានបង្ហាញអំពីកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង ចាប់តាំងពេលចូលជាសមាជិកWTO។ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ពិត បានឈានដល់កម្រិតខ្ពស់នៅឆ្នាំបន្ទាប់ពីការចូលជាសមាជិក ដោយឈានដល់ ១៤,១% ក្នុងឆ្នាំ២០០៥ ដោយសារការចូលជាសមាជិកបានផ្តល់ការជំរុញដល់ទំនុកចិត្ត និងនាំឱ្យមានការកើនឡើងនៃការវិនិយោគឯកជន ខណៈដែលការអនុវត្តកំណែទម្រង់បានជំរុញការវិនិយោគសាធារណៈ។ រយៈពេលប៉ុន្មានឆ្នាំក្រោយការចូលជាសមាជិក រហូតដល់វិបត្តិហិរញ្ញវត្ថុពិភពលោក គឺជាពេលវេលាដែលអត្រាកំណើនយ៉ាងលឿននៃផ.ស.ស.ដែលលើសពី ៩% ក្នុងមួយឆ្នាំ។ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក កំណើនបានធ្លាក់ចុះខ្លះក្នុងឆ្នាំ២០០៩ និង ២០១០ ប៉ុន្តែនៅពេលដែលកំណែទម្រង់នៅតែបន្ត កម្ពុជានៅតែអាចរក្សាអត្រាកំណើនផ.ស.ស.ពិតលើស ៥%។ អត្រាកំណើនប្រចាំឆ្នាំដែលបន្ទាប់មកបានកើនឡើងចន្លោះពី ៥,៨% ទៅ ៩,១% នៅឆ្នាំ២០១១-២០១៩។ សេដ្ឋកិច្ចកម្ពុជា បានទទួលរងផលប៉ះពាល់ដោយជំងឺរាតត្បាតកូវីដ១៩ ដែលនាំឱ្យផ.ស.ស.ពិតធ្លាក់ចុះ ៣% ក្នុងឆ្នាំ២០២០ ប៉ុន្តែការធ្លាក់ចុះនេះគឺស្ថិតក្នុងកម្រិតគួរឱ្យកត់សម្គាល់ដូចប្រទេសផ្សេងទៀតទេ ប៉ុន្តែបានងើបឡើងវិញយ៉ាងឆាប់រហ័សរហូតដល់២,៩% និង ៥,១% នៅឆ្នាំ២០២១ និង ២០២២ យោងតាមទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ (តារាងទី១) ។ សម្រាប់ឆ្នាំ២០២៣ កំណើន ផ.ស.ស. របស់កម្ពុជាត្រូវបានព្យាករណ៍ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ថានឹងសម្រេចបាននូវកំណើន ៥% ហើយត្រូវបានរំពឹងថានឹងកើនឡើងដល់ ៦% នៅឆ្នាំ២០២៤។

គំនូសតាងគំនូសតាងទី១ កំណើន ផ.ស.ស ពិត ឆ្នាំ២០០៣-២០២៣




**ប្រភព៖** វិទ្យាស្ថានជាតិស្ថិតិ https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia/១៥0-national-account-new

៤២. អត្រាកំណើនផ.ស.ស.ពិតជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេល២០ឆ្នាំ ចាប់តាំងពីការចូលជាសមាជិក WTO គឺ ៧,១%។ ផ.ស.ស ពិត បានកើនឡើង ២៩២% ចន្លោះឆ្នាំ២០០៤ និង ២០២៣; ដែលមានន័យថា ក្នុងរយៈពេលត្រឹមតែ២០ឆ្នាំ ទំហំសេដ្ឋកិច្ចបានកើនឡើងបីដង ក្នុងតម្លៃពិត ។ នៅក្នុងតម្លៃចារឹក (nominal) ផ.ស.ស បានកើនឡើង ៧ ដងក្នុងអំឡុងពេលនោះ។[6]

# សក្ខីកម្ម

តើការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់កម្ពុជាក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ បានកែប្រែការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា យ៉ាងដូចម្ដេច?

"សមាជិកភាពរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) តាំងពីឆ្នាំ ២០០៤ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមចំណែកពន្លឿនដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់រឹងមាំ និងក្លាំងក្លាតាមរយៈការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើច្បាប់ ក៏ដូចជាអត្ថប្រយោជន៍ទទួលបានពីភាពអនុគ្រោះសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច។ សមាជិកភាពនេះ បានក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ជាមួយបណ្ដាប្រទេស និងស្ថាប័នជាដៃគូ ជាពិសេសការចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី និងទ្វេភាគីរបស់កម្ពុជា សំដៅជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងផ្សារភ្ជាប់កម្ពុជាឱ្យកាន់តែខ្លាំងទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកល។ ជាមួយគ្នានេះ កម្ពុជាក៏មានកាតព្វកិច្ចធ្វើកំណែទម្រង់គោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្ម ស្របតាមបទប្បញ្ញត្តិរបស់ WTO និងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ដែលបានចូលរួមចំណែកបង្កើតបរិយាកាសធុរៈកិច្ច និងវិនិយោគអំណោយផល និងព្យាករបាន ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងជំរុញពាណិជ្ជកម្ម សំដៅធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់ ក៏ដូចជាលើកកម្ពស់ការត្រៀមលក្ខណៈសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្នុងឆ្នាំ២០២៩ និងឈានទៅសម្រេចបាននូវចក្ខុវិស័យក្នុងការក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ខាងមុខ។"

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

6 វិទ្យាស្ថានជាតិស្ថិតិ នៅ https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia/១៥០-national-account-new

៤៣. កម្លាំងដ៏សំខាន់ជំរុញកំណើន គឺការនាំចេញទំនិញដ៏សម្បើម ដែលបានកើនឡើងយ៉ាងខ្លាំង បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកWTO។ ការនាំចេញទំនិញបានកើនឡើងក្នុងអត្រាកំណើនជាមធ្យម១២% ក្នុងតម្លៃពិត ហើយបានកើនឡើងស្ទើរតែ៩ដងក្នុងតម្លៃចារឹកពី ២.៧៩៨ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០០៤ ដល់ ២៣.៤៧០ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣ (តារាងទី ២)។ ដោយសារការធ្វើសមាហរណកម្មយ៉ាងរហ័សរបស់ខ្លួននៅក្នុងសេដ្ឋកិច្ចសកល និងការមើលឃើញពីសារៈសំខាន់នៃសមាហរណកម្មនេះ កំណើននាពេលអនាគតរបស់កម្ពុជា គឺពឹងផ្អែកទៅលើវិសាលភាពដ៏ធំមួយលើការរក្សានូវសន្ទុះពាណិជ្ជកម្ម និងការវិនិយោគ។ យោងតាមបុគ្គលិក IMF ដែលបានកត់សម្គាល់នៅក្នុងឯកសារថ្មីៗនេះ ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចអាចនាំឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ចសម្រាប់កម្ពុជា ដោយសារការបើកចំហទីផ្សារពាណិជ្ជកម្មរបស់ខ្លួន។[7]

៤៤. ការវិនិយោគគឺជាចលករដ៏សំខាន់មួយផ្សេងទៀតដែលនៅពីក្រោយសមិទ្ធកម្ម ផ.ស.ស. ដ៏រឹងមាំ ហើយអត្រាកំណើនរបស់វាក៏ហាក់បីដូចជាត្រូវបានពន្លឿនដោយសមាជិកភាព WTO នេះផងដែរ៖ ចំណែក ផ.ស.ស.នៃការបង្កើតមូលធនសរុបបានកើនឡើងពី ២១,៤% នៅឆ្នាំ២០០៤ ដល់ ៣៤,៣% នៅឆ្នាំ ២០២២[8]។ នេះជាលទ្ធផលនៃអត្រាកំណើនពិតជាមធ្យមប្រចាំឆ្នាំប្រហែល ១០% ក្នុងអំឡុងពេលនោះ។ លទ្ធផលនេះគឺមានសារៈសំខាន់បំផុត ព្រោះវាផ្តល់នូវមូលដ្ឋានសម្រាប់កំណើននាពេលអនាគត។ សមិទ្ធកម្មដ៏គួរឱ្យចាប់អារម្មណ៍នៃវិនិយោគបានដើរទន្ទឹមគ្នាជាមួយនឹងការកើនឡើងយ៉ាងខ្លាំងនៃការនាំចូលទំនិញ និងសេវាកម្ម ដែលបានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំជាមធ្យម ១១% ក្នុងអំឡុងឆ្នាំ ២០០៤-២០២២។ ការប្រើប្រាស់ក្នុងគ្រួសារបានកើនឡើងជាមធ្យមប្រចាំឆ្នាំ ៥,៦% អត្រាពិតក្នុងរយៈពេលនេះ។

7 IMF (ឆ្នាំ២០២៤), ប្រទេសកម្ពុជា ឆ្នាំ២០២៣ ប្រការ IV ការប្រឹក្សាយោបល់—សេចក្តីប្រកាសព័ត៌មាន និងរបាយការណ៍បុគ្គលិក, ឧបសម្ព័ន្ធទី VII. ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច៖ ផលប៉ះពាល់សម្រាប់ប្រទេសកម្ពុជា។ របាយការណ៍របស់ប្រទេសនៃ IMF លេខ ២៤/៣៦ ចុះខែមករា ឆ្នាំ២០២៤ សូមមើលនៅ៖https://www.imf.org/en/Publications/CR/Issues/២០២៤/០១/២៩/Cambodia-២០២៣-Article-IV-Consultation-Press-Release-and-Staff-Report-៥៤៤២៧៦

8 ការគណនាដោយផ្អែកលើទិន្នន័យដែលទទួលបានពីវិទ្យាស្ថានជាតិស្ថិតិ នៅ https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia/150-national-account-new

**គំនូសតាងទី២ សមិទ្ធកម្មនៃការនាំចេញ និងនាំចូលទំនិញ ឆ្នាំ២០០៤-២០២៣**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia/១៥០-national-account-new.

**៤៥.** ចាប់តាំងពីការចូលជាសមាជិកWTOមក កម្ពុជាបានក្លាយជាសេដ្ឋកិច្ចបើកចំហរជាងមុនដូចដែលបានឃើញក្នុងចំណែកនៃផ.ស.ស. ដែលតំណាងដោយពាណិជ្ជកម្មទំនិញ ដោយបានឈានដល់ ១៣២% ក្នុងឆ្នាំ២០២២ ធៀបនឹង ១០០% នៅពេលចូលជាសមាជិក (ឆ្នាំ ២០០៤)។ ដោយឆ្លុះបញ្ចាំងអំពីភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃការវិនិយោគ ហើយបើទោះបីជាការនាំចេញកើនឡើងយ៉ាងឆាប់រហ័សក៏ដោយ កម្ពុជានៅមានឱនភាពតុល្យភាពពាណិជ្ជកម្មទំនិញ៖ ឱនភាពនេះឈានដល់ចំនួន ២,៨ ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣ ឬប្រហែល៨,៦% នៃផ.ស.ស. ខណៈឱនភាពនេះមានរហូត ៨,៨ ពាន់លានដុល្លារអាម៉េរិក កាលពីឆ្នាំ២០២២។ ការថយចុះឱនភាពនេះកើតឡើង បណ្តាលមកពីការថយចុះយ៉ាងខ្លាំងនៃការនាំចូល ក្រោយពីប្រក្រតីភាពនៃបរិយាកាសសេដ្ឋកិច្ច បន្ទាប់ពីជំងឺរាតត្បាតនៅឆ្នាំ២០២១ និងឆ្នាំ២០២២ បានថយចុះ។ ការនាំចេញបានកើនឡើង ១,៧% ក្នុងឆ្នាំ២០២៣ ខណៈការនាំចូលថយចុះ ១៧,៧% ក្នុងនោះការនាំចូលយានយន្តថយចុះ ៣៥,៩% ផលិតផលប្រេង ៥,៣% និងសម្ភារៈកាត់ដេរ ៧% ។

**៤៦.** ការនាំចេញទំនិញបានឈានដល់ ២៣.៥៦៤ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៣ ដែលនេះគឺខ្ពស់ជាង ១,៧% ក្នុងឆ្នាំ២០២២។ ផលិតផលនាំចេញសំខាន់ៗគឺសម្លៀកបំពាក់ ដែលតំណាងឱ្យមួយភាគបីនៃចំនួនសរុប (៧.៨៦៩ លានដុល្លារអាម៉េរិក) ប៉ុន្តែបានធ្លាក់ចុះមកត្រឹម ១២,៩% បើធៀបនឹងឆ្នាំមុន។ ផលិតផលសម្លៀកបំពាក់នេះ ត្រូវបាននាំមុខលើការនាំចេញគ្រឿងបន្លាស់អគ្គិសនី ដែលមានចំនួន ១២,៣% (២.៨៩៨ លានដុល្លារអាម៉េរិក) ហើយជាចំណែកនៃការនាំចេញមានសន្ទុះខ្លាំងបំផុត ដែលបានកើនឡើង ៦៦,៣% ធៀបនឹងឆ្នាំ២០២២។ ការនាំចេញសំខាន់ៗផ្សេងទៀតគឺ៖ វាយនភណ្ឌ (២.០៤៧ លានដុល្លារអាម៉េរិក) ស្បែកជើង (១.៣៦៥ លានដុល្លារអាម៉េរិក) កៅស៊ូ (៥២៨ លានដុល្លារអាម៉េរិក) កង់ (៤៩១

លានដុល្លារអាមេរិក) និងអង្ករ (៤៦៨ លានដុល្លារអាមេរិក)។ ទីផ្សារនាំចេញសំខាន់ៗរបស់ប្រទេសកម្ពុជា រួមមាន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្សិក បារាំង ហូឡង់ វៀតណាម អ៊ីតាលី និងតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។ ការនាំចូលមានទឹកប្រាក់សរុប ២៦.៣២៦ លានដុល្លារអាមេរិក។ សមាសភាគសំខាន់ៗ រួមមាន សម្ភារៈកាត់ដេរ (៤.៧០៧លានដុល្លារអាមេរិក) ផលិតផលប្រេង (៤.២៦២លានដុល្លារអាមេរិក) សម្ភារៈសំណង់ (២.០០០លានដុល្លារអាមេរិក) អាហារ និងភេសជ្ជៈ (១.៤៥៦លានដុល្លារអាមេរិក) និងយានជំនិះ (១.២៤៧លានដុល្លារអាមេរិក)។[9]

**៤៧.** គណនីចរន្តរបស់កម្ពុជានៃតុល្យភាពចំណាយបង្ហាញពីឱនភាពជាប្រចាំ ដែលជាស្ថានភាពធម្មតានៃប្រទេសកំពុងអភិវឌ្ឍន៍ដែលកំពុងមានការវិនិយោគគួរឱ្យកត់សម្គាល់ និងរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបណ្តាលឱ្យមានតម្រូវការយ៉ាងខ្លាំងទាក់ទងនឹងការនាំចូលទំនិញ និងសេវាកម្ម។ ឱនភាពទាំងនេះមានចន្លោះពី ៦,៣% ទៅ ៩,២% នៃ ផ.ស.ស.ក្នុងចន្លោះឆ្នាំ២០១៤-២០២០។ ជំងឺរាតត្បាតបណ្តាលឱ្យមានការកើនឡើងយ៉ាងខ្លាំងនៃការនាំចូលទាំងទំនិញ និងសេវាកម្ម ហើយនាំឱ្យមានឱនភាពគណនីចរន្តហូតដល់ជិត ៤០% នៃផ.ស.ស. ក្នុងឆ្នាំ២០២១ និង ២៥% នៅឆ្នាំ២០២២។ ការផ្លាស់ប្តូរដ៏សំខាន់មួយបានកើតឡើងនៅឆ្នាំ ២០២៣ នៅពេលដែលគណនីចរន្ត និងគណនីមូលធនបានបង្ហាញពីអតិរេកស្មើនឹង ២,៩% នៃផ.ស.ស.។ ការផ្លាស់ប្តូរពីឱនភាពទៅជាអតិរេកសម្រាប់គណនីចរន្ត និងមូលធន ដោយសារការថយចុះនៃឱនភាពពាណិជ្ជកម្មទំនិញ និងការកើនឡើងនៃអតិរេកគណនីសេវាកម្មដែលភាគច្រើនបណ្តាលមកពីឥណទានសេវាកម្មមានចរន្តខ្ពស់ រួមផ្សំជាមួយឱនភាពប្រាក់ចំណូលបឋមទាបជាងមុន និងអតិរេកនៃប្រាក់ចំណូលបន្ទាប់បន្សំខ្ពស់ (ប្រហែល ៣,១ ពាន់លានដុល្លារអាមេរិក)។[10]

**៤៨.** កម្ពុជាគឺជាប្រទេសនាំចូលមូលធន ដែលចាំបាច់ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងន័យនេះ សមតុល្យគណនីហិរញ្ញវត្ថុបង្ហាញពីលំហូរចូលសុទ្ធដែលបានកើនឡើងជាអតិបរមារហូតដល់ ៤៩,១ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ និង ២៦,៥ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះមកត្រឹម ២,៧ ពាន់លានដុល្លារ ក្នុងឆ្នាំ២០២៣។ លំហូរចូលភាគច្រើន គឺជា FDI និងការវិនិយោគផ្សេងទៀត។ លំហូរនៃការវិនិយោគគឺភាគច្រើនស្ថិតក្នុងវិស័យផលិតកម្ម ជាពិសេសក្នុងវិស័យកាត់ដេរ និងស្បែកជើង ផលិតផលធ្វើដំណើរ និងការវេចខ្ចប់ ផលិតផលបន្ទះសូឡា និងសំណង់។ ទុនបម្រុងអន្តរជាតិមានចំនួន

---

[9] ធនាគារជាតិកម្ពុជា(ឆ្នាំ២០២៤) របាយការណ៍ប្រចាំឆ្នាំ២០២៣ និង គោលដៅសម្រាប់ឆ្នាំ២០២៤. សូមមើល https://www.nbc.gov.kh/download_files/publication/annual_rep_eng/NBC%២០Annual%២០Report%២០២០២៣%២០Eng.pdf

[10] ធនាគារជាតិកម្ពុជា (ឆ្នាំ២០២៤) ការត្រួតពិនិត្យស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣. សូមមើល https://www.nbc.gov.kh/download_files/publication/fsr_eng/FSR%២០២០២៣%២០ENG%២០Publish.pdf

ប្រហែល ២០ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ដែលចំនួនទឹកប្រាក់នេះស្មើនឹងការនាំចូលទំនិញ និងសេវាកម្ម ក្នុងរយៈពេលប្រាំពីរខែ។

## សក្ខីកម្ម

តើការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់កម្ពុជាក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ បានលើកកម្ពស់បរិយាកាសវិនិយោគរបស់ប្រទេសកម្ពុជា យ៉ាងដូចម្ដេច?

"សមាជិកភាពរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា តាមរយៈ១)ការពន្លឿនការកែទម្រង់របៀបរបបពាណិជ្ជកម្មកម្ពុជា ២)ការបង្កើតក្របខ័ណ្ឌគតិយុត្ត អំណោយផលដល់ការធ្វើធុរកិច្ច និងវិនិយោគ ៣)ភាពអនុគ្រោះផ្សេងៗ ដែលកម្ពុជាទទួលបានក្នុងនាមជាសមាជិកអភិវឌ្ឍន៍តិចតួច និង ៤) ការចូលរួមរបស់កម្ពុជាក្នុងទីផ្សារពិភពលោក។ ការវិនិយោគទាំងនោះបានជំរុញឧស្សាហូបនីយកម្ម បង្កើនការប្រើប្រាស់បច្ចេកវិទ្យា លើកកម្ពស់ការកសាងហេដ្ឋារចនាសម្ព័ន្ធភស្តុភារកម្ម និងការអភិវឌ្ឍជំនាញនៅកម្ពុជា។ ជាលទ្ធផល កត្តាទាំងនេះធ្វើឱ្យការប្រកួតប្រជែងរបស់កម្ពុជាមានភាពរឹងមាំ បង្កើតការងារ និងចំណូលកើនឡើងសម្រាប់ប្រជាពលរដ្ឋ។ ដើម្បីធានាបាននូវភាពទាក់ទាញក្នុងវិស័យវិនិយោគ និងការវិនិយោគបន្ថែមក្នុងវិស័យអាទិភាពសំខាន់ៗ កម្ពុជាបានបន្តធ្វើកំណែទម្រង់ និងធ្វើឱ្យប្រសើរឡើងនៃបរិយាកាសវិនិយោគ តាមរយៈការដាក់ចេញនូវច្បាប់ស្ដីពីវិនិយោគថ្មីនៅឆ្នាំ ២០២១។"

**ឯកឧត្តម សុខ ចិន្តាសោភា**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជា

៤៩. ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សជាមួយតម្រូវការខ្ពស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ កម្ពុជាបានបង្ហាញពីឱនភាពសារពើពន្ធជាមធ្យម ១,៨% នៃផ.ស.ស.ក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០១០-២០១៩។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ អតិរេកសារពើពន្ធបានឆ្លុះបញ្ចាំងពីសេដ្ឋកិច្ចរឹងមាំ និងការកើនឡើងនៃការប្រមូលចំណូលរបស់កម្ពុជា។ ជំងឺរាតត្បាតបានផ្លាស់ប្ដូរស្ថានភាពនេះ ហើយបាននាំឱ្យមានឱនភាពប្រហែល ៤,៩% នៃផ.ស.ស.ក្នុងឆ្នាំ២០២០ និង ៧,២% ក្នុងឆ្នាំ២០២១។ ឱនភាពបានបន្តក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ប៉ុន្តែមិនបានធ្វើឱ្យបំណុលកើនឡើងខ្លាំងនោះទេ ដោយសារទទួលបានហិរញ្ញប្បទានតាមបែបប្រពៃណី តាមរយៈប្រាក់សន្សំសុទ្ធនៃវិស័យឯកជនក្នុងស្រុកដ៏ធំ[11] និងប្រាក់សន្សំសុទ្ធក្រៅស្រុក ដោយសារអតិរេកនៃសមតុល្យ ជាពិសេសលំហូរវិនិយោគ

[11] លើកលែងតែនៅឆ្នាំ២០២១ និង ២០២២ នៅពេលដែលប្រាក់សន្សំសុទ្ធរបស់វិស័យឯកជនមានភាពអវិជ្ជមានដោយសារឥទ្ធិពលនៃជំងឺរាតត្បាតសកល កូវីដ-១៩ វាមានកម្រិតខ្ពស់ ធៀបនឹងភាគរយនៃផលិតផលក្នុងស្រុកសរុប ដែល IMF បានប៉ាន់ស្មានថាមានចំនួន ១៨% នៃ

សុទ្ធធំៗពីបរទេស។ បំណុលសាធារណៈសរុបតំណាងឱ្យប្រហែល ៣៥% នៃផ.ស.ស. ក្នុងឆ្នាំ ២០២៣ បើប្រៀបធៀបជាមធ្យម ៣០% សម្រាប់រយៈពេលចាប់ពីឆ្នាំ២០១០-២០១៨ ។[12] ការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅរបស់កម្ពុជាទៅក្នុងសេដ្ឋកិច្ចសកល បានក្លាយជារនាំងការពារដ៏សំខាន់ប្រឆាំងនឹងផលប៉ះពាល់ដែលកើតឡើងពីកត្តាខាងក្រៅ ដូចជាជំងឺរាតត្បាតកូវីដ-១៩ ជាដើម។

៥០. ធនាគារជាតិនៃកម្ពុជា អនុវត្តរបបអត្រាប្តូរប្រាក់អណ្តែត ពោលគឺការសម្របសម្រួលនៅក្នុងទីផ្សារប្តូរប្រាក់បរទេស ដើម្បីរក្សាអត្រាប្តូរប្រាក់ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ។ អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានកំណត់ជាប្រចាំ ហើយវាជាអត្រាប្តូរប្រាក់គោលសម្រាប់វិស័យឯកជនផងដែរ។ អត្រាប្តូរប្រាក់នៅតែមានស្ថិរភាពក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មួយផ្នែកដោយសារតែការសម្របសម្រួលរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងទីផ្សារប្តូរប្រាក់បរទេស។ អត្រាប្តូរប្រាក់រៀលគឺ ៤.១១១ រៀលក្នុងមួយដុល្លារអាម៉េរិកជាមធ្យមក្នុងឆ្នាំ២០២៣ ធ្លាក់ចុះត្រឹមតែ ១,៥% បើធៀបនឹងឆ្នាំ២០១៩ ហើយបានឡើងថ្លៃក្នុងតម្លៃពិត។ ចំពោះអត្រាប្តូរប្រាក់នៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០២៤ នៅតែមានភាពដូចគ្នាទៅនឹងឆ្នាំ២០២៣។

៥១. អតិផរណាស្ថិតក្នុងកម្រិតគ្រប់គ្រងបានជាមធ្យមក្នុងរយៈពេល ២០ឆ្នាំ ចុងក្រោយនេះ។ ធនាគារជាតិនៃកម្ពុជាអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងគោលបំណងរក្សាស្ថិរភាពតម្លៃ ដើម្បីសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងក្របខណ្ឌទូលំទូលាយនៃគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកម្ពុជា។ ទោះបីមិនអនុវត្តគោលនយោបាយកំណត់គោលដៅអតិផរណាក៏ដោយ ក៏ធនាគារជាតិនៃកម្ពុជាព្យាយាមរក្សាអតិផរណានៅជាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលអាចចាត់ទុកថាមានភាពសមរម្យសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយការប្រុងប្រយ័ត្ន។ បច្ចុប្បន្ននេះ ឧបករណ៍គោលនយោបាយរូបិយវត្ថុសំខាន់ៗដែលប្រើប្រាស់ដើម្បីសម្រេចបាននូវស្ថិរភាពថ្លៃគឺ អត្រាតម្រូវសម្រាប់ទុនបម្រុង និងការអន្តរាគមនៅក្នុងទីផ្សារប្តូរប្រាក់បរទេស។ ក្នុងឆ្នាំ២០២៤នេះ អត្រាតម្រូវសម្រាប់ទុនបម្រុងរបស់ធនាគារសម្រាប់រូបិយប័ណ្ណបរទេសគឺ ១២,៥% ខណៈពេលដែលតម្រូវការសម្រាប់រូបិយប័ណ្ណក្នុងស្រុកគឺ ៨%។ ធនាគារជាតិនៃកម្ពុជាបង់ការប្រាក់ក្នុងអត្រា ៤,៥% នៃតម្រូវការបម្រុងជារូបិយប័ណ្ណបរទេស ប៉ុន្តែមិនមែនទៅលើ ៨% ដែលនៅសល់ ឬលើតម្រូវការបម្រុងជាប្រាក់រៀលនោះទេ។ សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកខ្លាំងលើរូបិយបណ្ណដុល្លារអាម៉េរិក ដែលការណ៍នេះធនាគារជាតិនៃកម្ពុជា ចាត់ទុកថាអាចរារាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពរបស់ខ្លួន

ផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២៣។ សូមមើល៖ IMF (ឆ្នាំ២០២៤), ប្រទេសកម្ពុជា ឆ្នាំ២០២៣ ប្រការ IV ការប្រឹក្សាយោបល់—សេចក្តីប្រកាសព័ត៌មាន និងរបាយការណ៍បុគ្គលិក របាយការណ៍របស់ប្រទេសនៃ IMF លេខ ២៤/៣៦ ចុះខែមករា ឆ្នាំ២០២៤. សូមមើលនៅ https://www.imf.org/en/Publications/CR/Issues/2024/01/29/Cambodia-2023-Article-IV-Consultation-Press-Release-and-Staff-Report-544276

[12] ព័ត៌មានអំពីធនាគារពិភពលោកនៅលើប្រព័ន្ធអ៊ីនធឺណិតប្រទេសកម្ពុជាសូមមើលនៅ៖ https://thedocs.worldbank.org/en/doc/b991970a7f5096ab093720e27d5f0b68-0500012021/related/data-khm.pdf

ក្នុងការដើរតួជាអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាកំពុងដំណើរការដាក់ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុដូចជា ការចេញវិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចចរាចរបាន (NCDs) ការអភិវឌ្ឍអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ និងការលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណរៀលជាតិ។[13]

**៥២.** ដោយពិចារណាលើលក្ខណៈនៃសេដ្ឋកិច្ចដែលមានប្រាក់ដុល្លារអាម៉េរិកកម្រិតខ្ពស់ ការបើកចំហសេដ្ឋកិច្ចដែលកើតចេញពីសមាជិកភាព WTO ក៏បានរួមចំណែករក្សាអតិផរណាផងដែរ ដោយសារការធ្លាក់ចុះនៃសម្ពាធដែលបណ្តាលមកពីការនាំចូល មកលើតម្លៃក្នុងស្រុក ដោយបង្កើនការប្រកួតប្រជែង និងធ្វើឱ្យទំនិញ និងសេវាកម្មមានតម្លៃល្អបំផុត។ ទោះបីក្នុងនាមជាប្រទេសនាំចូលវត្ថុធាតុដើមក៏ដោយ ក៏កម្ពុជាបានទទួលរងនូវបម្រែបម្រួលតម្លៃ ជាពិសេសក្នុងអំឡុងពេលនៃការងើបឡើងវិញបន្ទាប់ពីជំងឺរាតត្បាត ហើយការកើនឡើងនៃផលិតភាពនៅពីក្រោយអត្រាកំណើនដ៏លឿនរបស់ខ្លួនបានជួយទប់ស្កាត់ឥទ្ធិពលនេះ។ ដូច្នេះហើយ កម្ពុជាទទួលបានអត្រាអតិផរណាប្រចាំឆ្នាំជាមធ្យម ដែលវាស់វែងជាបរិត្តផរណានៃផ.ស.ស. គឺ ៤% ក្នុងរយៈពេល ២០ឆ្នាំ ចាប់តាំងពីការចូលជាសមាជិក WTO ក្រោមកម្រិតអតិបរិមា ដែលធនាគារជាតិចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់។ ដោយមិនរាប់បញ្ចូលរយៈពេល ៥ ឆ្នាំដំបូងបន្ទាប់ពីការចូលជាសមាជិក ដែលត្រូវបានកំណត់ដោយការកើតឡើងនៃវិបត្តិហិរញ្ញវត្ថុពិភពលោក អតិផរណាជាមធ្យមប្រចាំឆ្នាំធ្លាក់ចុះដល់២,៨% ជាមួយនឹងកម្រិតខ្ពស់បំផុត ៦,៧% នៅក្នុង ២០១៤ និងទាប -0,៧% ក្នុងឆ្នាំ ២០២០ (តារាងទី ៣)។ តម្លៃបានធ្លាក់ចុះក្នុងអំឡុងពេលជំងឺរាតត្បាត ហើយក្រោយមកបានកើនឡើង ជាពិសេសនៅឆ្នាំ២០២២ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ២០២៣ អតិផរណាគឺស្ថិតនៅក្រោម ៣% ហើយនៅតែបន្តស្ថិតក្រោមកម្រិតនេះនៅឆ្នាំ ២០២៤។

[13] ធនាគារជាតិនៃកម្ពុជា គោលនយោបាយសាច់ប្រាក់ ទិដ្ឋភាពទូទៅ សូមមើលនៅ៖ https://www.nbc.gov.kh/english/monetary_policy/overview.php

### គំនូសតាងទី ៣៖ អត្រាអតិផរណា (ការប្រែប្រួលនៃអតិផរណា GDP) ឆ្នាំ២០០៣-២០២៤




**ប្រភព៖** វិទ្យាស្ថានជាតិស្ថិតិ នៅ https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia/១៥0-national-account-new.

## សក្ខីកម្ម

"មុនពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក យើងសង្កេតឃើញថា សកម្មភាពពាណិជ្ជកម្ម និង វិនិយោគនៅកម្ពុជា នៅមានកម្រិតនៅឡើយ។ ចាប់តាំងពីកម្ពុជាចូលជាសមាជិក WTO រហូតមកដល់បច្ចុប្បន្ន វិស័យឯកជនទទួលបានផលប្រយោជន៍ជារួមតាមរយៈ កាលានុវត្តភាពធុរកិច្ចធំធេងជាងមុន និង បរិយាកាសធុរកិច្ចល្អប្រសើរជាលំដាប់។ វិស័យឯកជនមានលទ្ធភាពរកទីផ្សារទូលំទូលាយជាងមុន និងងាយស្រួលធ្វើលទ្ធកម្មវត្ថុធាតុដើមសម្រាប់ផលិតកម្ម។ ធុរកិច្ចក្នុងវិស័យសំខាន់ៗ ជាពិសេស វិស័យកាត់ដេរ វិស័យកសិកម្ម និង ទេសចរណ៍ ទទួលបានផលប្រយោជន៍សំបូរបែប។ ទន្ទឹមនឹងនេះ ការវិនិយោគដោយផ្ទាល់ពីបរទេស កាន់តែមានកំណើនជាងមុន ស្របពេលនិងកំណែទម្រង់ក្របខណ្ឌគតិយុត្តិ និងការការពារកម្មសិទ្ធិបញ្ញា។ ការណ៍នេះបាន និងកំពុងជំរុញនិងទាក់ទាញវិនិយោគិន បរទេសបណ្តាក់ទុនបន្ថែមជាបន្តបន្ទាប់នៅកម្ពុជា

ដោយឡែក សកម្មភាពធុរកិច្ចនិងវិនិយោគ ជាមួយបណ្តាប្រទេសនានាក្នុងតំបន់និងសកល គឺកាន់តែសកម្មជាងមុន។ ជារៀងរាល់ឆ្នាំ សភាពាណិជ្ជកម្មកម្ពុជា ទទួលជួបធុរជនដែលមានចំណាប់អារម្មណ៍ទីផ្សារកម្ពុជា និងរៀបចំព្រឹត្តិការណ៍ធុរកិច្ច ជាច្រើនលើកច្រើនសារ។ និន្នាការនេះ បន្តកើនឡើងជាលំដាប់ ដែលជួយផ្សារភ្ជាប់ធុរជនបរទេសនិងធុរជនក្នុងស្រុក។ គិតត្រឹមឆ្នាំ២០២៤ សភាពាណិជ្ជកម្មកម្ពុជា បានចុះអនុស្សរណៈយោគយល់ជាមួយដៃគូបរទេសជាង ១០០ ស្ថាប័ន។ នេះបង្ហាញអំពីទំនុកចិត្ត និង ចំណាប់អារម្មណ៍របស់វិនិយោគិនបរទេសចំពោះកម្ពុជា។"

**អ្នកឧកញ៉ា គិត ម៉េង**

ប្រធានសភាពាណិជ្ជកម្មកម្ពុជា និង ជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា

# សក្ខីកម្ម

"ចាប់តាំងពីកម្ពុជាចូលជាសមាជិក WTO ក្នុងឆ្នាំ២០០៤ សមាជិកភាពនេះបានដើរតួនាទីជាកាតាលីករដើម្បីសម្រេចបាននូវបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច បង្កើតការងារ និងឱកាសធុរកិច្ច ទន្ទឹមនឹងនោះក៏បានធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជាគួរឱ្យកត់សម្គាល់ ដែលទាំងអស់នេះបាននិងកំពុងរួមចំណែកដល់កំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង។ សមាជិកភាពដ៏សំខាន់នេះ ក៏បានអនុញ្ញាតឱ្យកម្ពុជាលើកកម្ពស់ធនធានមនុស្ស និងសមត្ថភាពផលិតកម្ម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកំណែទម្រង់ច្បាប់ និងស្ថាប័នផងដែរ។ ការកាត់បន្ថយអត្រាភាពក្រីក្រ និងការកើនឡើងគួរឱ្យកត់សម្គាល់នៃប្រាក់ចំណូលជាតិសរុបក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ និងផែនការរបស់កម្ពុជាក្នុងការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ ជាសក្ខីភាពនៃការចូលជាសមាជិកនេះ។ សមាជិកភាព WTO របស់កម្ពុជា គឺមានសារៈសំខាន់ធ្វើឱ្យសមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅទៅក្នុងសេដ្ឋកិច្ចសកល និងតំបន់ ទន្ទឹមនឹងការត្រួសត្រាយផ្លូវឆ្ពោះទៅរកអនាគតដ៏រុងរឿង ខណៈដែលកម្ពុជាបន្តបំពេញគោលដៅនៃការប្រែក្លាយជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។"

**ឯកឧត្តម សួន ប្រសិទ្ធ**

អគ្គរាជទូត និងជាប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការ WTO
និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

"ព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល២ទស្សវត្សរ៍កន្លងមកនេះ។ ផលិតផលសរុបក្នុងស្រុករបស់កម្ពុជាកើនឡើងជាង ៣ដង ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ជាមួយនឹងការថយចុះគួរឱ្យកត់សម្គាល់នៃកម្រិតភាពក្រីក្រ។ ការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងពាណិជ្ជកម្មអន្តរជាតិបានត្រួសត្រាយផ្លូវសម្រាប់អនាគតដ៏ល្អប្រសើរ និងនិរន្តរភាព។ ទន្ទឹមនឹងនេះ ស្ថាប័ន UNCTAD នឹងបន្តការចូលរួមដំណើរជាមួយកម្ពុជាក្នុងការឆ្ពោះទៅរកគោលដៅទាំងនេះ។"

**លោកជំទាវ Rebeca Grynspan,**

អគ្គលេខាធិការ, សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍

# ៦. សមាជិកភាព WTO និងកំណែទម្រង់ក្នុងស្រុក

៥៣. ប៉ុន្មានឆ្នាំមកនេះ កម្ពុជាបាននិងកំពុងអនុវត្តវិធានការនានា ដើម្បីជួយពង្រឹងការចូលទៅក្នុងសេដ្ឋកិច្ចសកល និងលើកកម្ពស់ការប្រកួតប្រជែងរបស់ខ្លួន។ នៅក្នុងវិស័យគោលនយោបាយពាណិជ្ជកម្ម រាជរដ្ឋាភិបាលបានដាក់ចេញវិធានការតាមកាលកំណត់ ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា និងកាត់បន្ថយថ្លៃចំណាយពាណិជ្ជកម្ម។

៥៤. មុនពេលចូលជាសមាជិក WTO និងដោយពិចារណាឃើញអំពីភាពចាំបាច់នៃការធ្វើកំណែទម្រង់ក្នុងការបង្កើតបទប្បញ្ញត្តិក្នុងស្រុកឱ្យស្របតាមកិច្ចព្រមព្រៀង WTO កម្ពុជាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់រយៈពេល៥ឆ្នាំ ក្នុងឆ្នាំ២០០៣ ដែលផ្ដោតលើការសម្រួល និងធ្វើបច្ចុប្បន្នភាពនីតិវិធីពន្ធគយ និងកិច្ចសម្រួលពាណិជ្ជកម្ម។ បន្ទាប់ពីការចូលជាសមាជិក WTO វិធានការជាច្រើនត្រូវបានដាក់ឱ្យដំណើរការ រួមទាំងការដាក់ឱ្យប្រើប្រាស់ច្បាប់ស្ដីពីគយថ្មី ក្នុងឆ្នាំ២០០៧ ជាមួយនឹងការអនុម័តលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីជានាអនុលោមភាពនៃច្បាប់ ព្រមទាំងកំណែទម្រង់គយមួយចំនួនទៀត។ ផែនការកំណែទម្រង់គយលើកទី២ សម្រាប់ការធ្វើទំនើបកម្ម និងកិច្ចសម្រួលពាណិជ្ជកម្មនៃនីតិវិធីគយ ត្រូវបានរៀបចំឡើងសម្រាប់ឆ្នាំ២០០៩-២០១៣។ ផែនការនេះរួមមានការបញ្ចប់ការអនុវត្តប្រព័ន្ធស្វ័យប្រវត្តកម្មទិន្នន័យគយ (ASYCUDA) នៅគ្រប់បញ្ជរពន្ធគយ ដែលបានសម្រេចក្នុងឆ្នាំ២០១១; ការដាក់ចេញប្រព័ន្ធគយស្វ័យប្រវត្តិ; ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិនៅកម្ពុជា; ការដាក់ចេញនូវប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធ Post-Clearance Audits; ការអនុវត្តក្របខណ្ឌសុវត្ថិភាពស្តង់ដាររបស់អង្គការគយពិភពលោក (WCO) អនុសញ្ញាទីក្រុងក្យូតូដែលត្រូវបានកែសម្រួល; និងការពង្រឹងសមត្ថភាពអនុវត្តរបស់អាជ្ញាធរ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរអាវុធ និងគ្រឿងញៀនខុសច្បាប់។

៥៥. សមិទ្ធផលសំខាន់មួយទៀត គឺការអនុវត្តវិធីសាស្ត្រតម្លៃប្រតិបត្តិការ និងកិច្ចព្រមព្រៀងវាយតម្លៃពន្ធគយ (CVA) របស់ WTO។ ដើម្បីសម្រេចកិច្ចការនេះ អង្គភាពគ្រប់គ្រងតម្លៃប្រតិបត្តិការត្រូវបានបង្កើតឡើង។ នៅពេលចូលជាសមាជិក WTO កម្ពុជាត្រូវបានទុករយៈពេល ៥ឆ្នាំ ដើម្បីលុបបំបាត់តម្លៃគយអប្បបរមា។ កម្ពុជាបានអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩ សម្រាប់វិធីសាស្ត្រពាដំបូងនៃការវាយតម្លៃពន្ធគយ ដែលបានចុះបញ្ជីនៅក្នុង CVA គឺ៖ តម្លៃប្រតិបត្តិការ ទំនិញដូចគ្នា និងទំនិញស្រដៀងគ្នា។ ការអនុវត្តពេញលេញនៃ CVA បានចាប់ផ្ដើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១១ ជាមួយនឹងការបញ្ចប់នៃការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃតារាងតម្លៃសម្រាប់ក្រុមទំនិញដែលងាយរងគ្រោះ និងមានហានិភ័យខ្ពស់ ដែលក្នុងនោះរួមមាន យានយន្តប្រើប្រាស់រួច និងផលិតផលប្រេង។ ចាប់តាំងពីពេលនោះមក កំណើនភាគរយនៃ Customs Clearance មានការកើនឡើងដោយប្រើប្រាស់វិធីសាស្ត្រប្រតិបត្តិការតម្លៃ។

៥៦. សមាជិក WTO បានកត់សម្គាល់នូវវឌ្ឍនភាពរបស់កម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្នុងការឆ្ពោះទៅរកការធ្វើសមាហរណកម្មពេញលេញទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ក្នុងដំណាក់កាលត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មលើកទី១ របស់កម្ពុជា (TPR) ក្នុងឆ្នាំ ២០១១ សមាជិកនានាបានកត់សម្គាល់ថា កម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញការសន្យារបស់ខ្លួនចំពោះ WTO តាមរយៈការអនុម័តច្បាប់សំខាន់ៗមួយចំនួន រួមមានច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិល (ច្បាប់ទាំងពីរនេះអនុម័តនៅក្នុងឆ្នាំ២០០៨) ច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ស្តីពីក្ស័យធន និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទេកពាណិជ្ជកម្ម (ក្នុងឆ្នាំ ២០០៩)។ ក្នុងអំឡុងពេល TPR លើកទីពីររបស់ខ្លួនក្នុងឆ្នាំ ២០១៧ កម្ពុជាទទួលបានការកោតសរសើរចំពោះការបន្តខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបញ្ចប់ការអនុវត្តការសន្យារបស់ខ្លួនចំពោះ WTO។ នៅទីបំផុត កម្ពុជាបានអនុម័តច្បាប់មួយចំនួនបន្ថែមទៀតដែលរួមមាន ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលបានអនុម័តក្នុងខែមករា ឆ្នាំ២០១២ ហើយនៅឆ្នាំបន្តបន្ទាប់ទៀត ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ឆ្នាំ២០១២); ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រ (ឆ្នាំ២០១៤), ច្បាប់ស្តីពីការធានារ៉ាប់រង (ឆ្នាំ ២០១៤) ច្បាប់ស្តីពីទូរគមនាគមន៍ (ឆ្នាំ២០១៥) និង ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ (ឆ្នាំ ២០១៦) ក្នុងចំណោមច្បាប់ដទៃទៀត។ គួរឱ្យកត់សម្គាល់ផងដែរថា កម្ពុជាបានយល់ព្រមលើអនុសញ្ញាអន្តរជាតិស្តីពីកម្មសិទ្ធិបញ្ញាជាច្រើន រួមទាំង អនុសញ្ញាក្យូតូដែលត្រូវបានកែសម្រួល (ឆ្នាំ២០១៤) ដែលផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ពិធីសារម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកសញ្ញាអន្តរជាតិ (ឆ្នាំ២០១៥) សន្ធិសញ្ញាសហប្រតិបត្តិការប៉ាតង់ (ឆ្នាំ២០១៦) និងកិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម (ឆ្នាំ២០១៧)។ សមាជិកបានស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងកំណែទម្រង់គយ និងការអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ WTO លើ TBTs ដូចដែលបានព្រមព្រៀង នៅពេលចូលជាសមាជិក។ កម្ពុជាសន្យាធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកទាំងអស់ ដើម្បីបន្តកែលម្អបរិយាកាសធុរកិច្ចរបស់ខ្លួន និងបំពេញកាតព្វកិច្ចអន្តរជាតិ ក្នុងគោលបំណងទាក់ទាញវិនិយោគិនបន្ថែមទៀត លើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ។

៥៧. ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ច្បាប់ និងបទប្បញ្ញត្តិជាច្រើន ត្រូវបានធ្វើសេចក្តីព្រាងដើម្បីកែលម្អបរិយាកាសសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។ ច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈអនុញ្ញាតឱ្យកម្ពុជាអនុវត្តវិសោធនកម្មកិច្ចព្រមព្រៀង TRIPS ទាក់ទងនឹងសុខភាពសាធារណៈ ដែលបានចូលជាធរមានក្នុងឆ្នាំ២០១៨។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានអនុម័តនៅឆ្នាំ២០១៩ និងចូលជាធរមាននៅឆ្នាំ២០២០។ ច្បាប់ស្តីពីការប្រកួតប្រជែង បានចូលជាធរមាននៅក្នុងខែតុលា ឆ្នាំ២០២២ ហើយអនុវត្តចំពោះបុគ្គលទាំងអស់ដែលធ្វើសកម្មភាពអាជីវកម្ម ឬសកម្មភាពណាមួយដែលគាំទ្រសកម្មភាពអាជីវកម្ម ដែលរារាំង រឹតត្បិត ឬបង្ខូចតម្លៃនៃការប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងកម្ពុជា ដោយមិនគិតពីកន្លែងដែលសកម្មភាពនេះកើតឡើងឡើយ។ ច្បាប់នេះមានរៀបរាប់ពីសកម្មភាពខុសច្បាប់

ដែលរារាំង រឹតត្បិត ឬបង្ខូចការប្រកួតប្រជែង ដែលរួមមាន ការព្រមព្រៀងខ្សែដេក (ការកំណត់តម្លៃ និងកិច្ចព្រមព្រៀងកំណត់បរិមាណ ការបែងចែកតំបន់ និងអតិថិជន។ល។) និងការព្រមព្រៀងខ្សែឈរ (ការលក់តាមលក្ខខណ្ឌ) ក៏ដូចជាសកម្មភាពលើការគ្រប់គ្រងទីផ្សារដោយខុសច្បាប់។ ច្បាប់នេះហាមឃាត់ការរួមផ្សំអាជីវកម្មដែលមាន ឬអាចមានឥទ្ធិពលក្នុងការទប់ស្កាត់ រឹតត្បិត ឬបង្ខូចតម្លៃនៃការប្រកួតប្រជែងនៅក្នុងទីផ្សារ។ ច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅក្នុងខែឧសភា ឆ្នាំ ២០២២ និងបានជូនដំណឹងទៅ WTO ក្នុងខែឧសភា ឆ្នាំ២០២៤។[14] ច្បាប់នេះមានគោលបំណងគ្រប់គ្រងសុខភាពរុក្ខជាតិ ជានាសន្តិសុខស្បៀង និងការថែរក្សាគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម។ ច្បាប់នេះក៏មានគោលបំណងក្នុងការសម្របសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូនរុក្ខជាតិនិងផលិតផលរុក្ខជាតិឆ្លងកាត់ ព្រមទាំងធ្វើឱ្យមានសុខដុមនីយកម្មនៃបទប្បញ្ញត្តិអនាម័យ ទៅតាមស្តង់ដារអន្តរជាតិដែលបានអនុម័តដោយអនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ។

**៥៨.** ការអភិវឌ្ឍថ្មីៗដ៏សំខាន់មួយដើម្បីលើកកម្ពស់ការវិនិយោគ និងកំណើននោះគឺ ច្បាប់ស្តីពីវិនិយោគថ្មី ដែលត្រូវបានអនុវត្តនៅក្នុងខែតុលា ឆ្នាំ២០២១។ អនុក្រឹត្យលេខ ១៣៩ ដែលត្រូវបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០២៣ បានអនុញ្ញាតឱ្យមានការអនុវត្តពេញលេញនៃច្បាប់ ជាពិសេសពន្ធលើប្រាក់ចំណូល និងកាតព្វកិច្ចផ្ទាល់ខ្លួន ក៏ដូចជាការជំរុញការលើកទឹកចិត្តផ្នែករំលស់ សម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថ្មី (QIPs) ដូចមានចែងនៅក្នុងច្បាប់។ QIPs គឺជាគម្រោងដែលជំរុញឱ្យមានការកើនឡើងនៃការនាំចេញ ឬសកម្មភាពគាំទ្រដែលអាចបណ្តាលឱ្យមានការនាំចេញខ្ពស់ជាងមុន។ គម្រោងតម្រង់ទិសក្នុងស្រុកមួយចំនួន អាចត្រូវបានចាត់ទុកថាជា QIPs ផងដែរ។ ការលើកលែងពន្ធលើប្រាក់ចំណូលអាចត្រូវបានផ្តល់ទៅឱ្យ QIPs រហូតដល់ទៅប្រាំបួនឆ្នាំ ជាមួយនឹងរយៈពេលលើកលែងអាស្រ័យលើវិស័យនៃសកម្មភាព និងថាតើសកម្មភាពវិនិយោគ QIPs ស្ថិតក្នុងវិស័យបច្ចេកវិទ្យាខ្ពស់/មធ្យម ឬទាប។ បន្ទាប់ពីរយៈពេលលើកលែងត្រូវបានបញ្ចប់ ប្រាក់ចំណូលត្រូវបានបង់ពន្ធក្នុងអត្រាកាត់បន្ថយ ប៉ុន្តែកើនឡើងបន្តិចម្តងៗសម្រាប់រយៈពេលប្រាំមួយឆ្នាំបន្ថែម។ ក្នុងអំឡុងពេលនៃការលើកលែងនោះ QIPs ដែលត្រូវបានតម្រង់ទិសសម្រាប់ការនាំចេញក៏ត្រូវបានលើកលែងពីពន្ធគយ និងអាករលើការនាំចូលជាតុចូល សម្ភារៈសំណង់ និងឧបករណ៍ផលិតកម្មសម្រាប់ប្រើប្រាស់ក្នុងខ្សែច្រវាក់ផលិតកម្ម។ QIPs ដែលត្រូវបានតម្រង់ទិសក្នុងស្រុក ត្រូវបានលើកលែងពីកាតព្វកិច្ចពន្ធលើសម្ភារៈសំណង់ និងឧបករណ៍ផលិតកម្ម។ QIP ក៏ទទួលបានអត្ថប្រយោជន៍ពីអាករអត្រាសូន្យលើវត្ថុធាតុដើមសម្រាប់ផលិតកម្មក្នុងស្រុក ដែលប្រើសម្រាប់ការអនុវត្ត QIP។ ប្រកាសលេខ ៣១៣ សហវ.ប្រក.អពដ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២៤ ផ្តល់នូវការលើកទឹកចិត្តបន្ថែមសម្រាប់ QIP ដែលពង្រីកសកម្មភាពវិនិយោគរបស់ខ្លួនក្នុងទម្រង់ណាមួយ (EQIP)។ ការលើកទឹកចិត្តពន្ធចាប់ផ្តើមនៅពេលដែល EQIP បង្កើតប្រាក់ចំណូល EQIP ដំបូងរបស់ខ្លួន ហើយមានអត្រាលើកលែងជាភាគរយ ពីអត្រាពន្ធលើ

[14] ឯកសារ G/SPS/N/KHM/១ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤ របស់ WTO

ប្រាក់ចំណូល ដែលបានគណនាជាសមាមាត្រនៃដើមទុន EQIP ដែលបានបណ្តាក់ទុន ចែកឱ្យដើមទុនសរុប ដែលបានវិនិយោគ ដែលការលើកទឹកចិត្តត្រូវបានផ្តល់តែលើការវិនិយោគថ្មីប៉ុណ្ណោះ។

៥៩. នៅឆ្នាំ ២០១៩ វិធានការបន្ថែមទៀតដើម្បីសម្រួលពាណិជ្ជកម្ម និងបង្កើនការប្រកួតប្រជែងត្រូវបានប្រកាសដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី**។ វិធានការទាំងនោះរួមមានការលុបចោលភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" ការដកតួនាទីអធិការកិច្ចរបស់អគ្គនាយកដ្ឋានកាំកុងត្រូលចេញពីតំបន់ត្រួតពិនិត្យនាំចេញនាំចូល ការបញ្ឈប់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រទេសប្រភពដើមនៃទំនិញ (CO) សម្រាប់ការនាំចេញទំនិញ លុះត្រាតែប្រទេសនាំចូលទាមទារ និងការកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃសេវាទាំងនៅកំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែក្រុងព្រះសីហនុ។[15]

៦០. នៅខែកក្កដា ឆ្នាំ២០១៩ កម្ពុជាបានចាប់ផ្តើមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (CNSW) របស់ខ្លួនដើម្បីអនុញ្ញាតឱ្យពាណិជ្ជករអាចដាក់ស្នើឯកសារតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការនាំចូល និងនាំចេញក្នុងការទទួលបានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារផ្សេងៗទៀត។ CNSW ត្រូវបានភ្ជាប់ទៅប្រព័ន្ធគយ ASYCUDA។ ដំណាក់កាលអនុវត្តដំបូងនៃ CNSW គ្របដណ្តប់លើទីភ្នាក់ងារអន្តរក្រសួងចំនួនប្រាំ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ក្រសួងពាណិជ្ជកម្ម (MOC) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រសួងសុខាភិបាល (MOH) និងអតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH); ភ្នាក់ងាររដ្ឋាភិបាលទាំងនេះចាប់ផ្តើមដំណើរការ និងអនុម័តកម្មវិធីនៅក្នុងគេហទំព័រដូចគ្នា។ រាជរដ្ឋាភិបាលបាននិងកំពុងពង្រីកការគ្របដណ្តប់ដល់ភ្នាក់ងាររដ្ឋាភិបាលដែលមានបទប្បញ្ញត្តិផ្សេងទៀត។ បច្ចុប្បន្ន CNSW កំពុងស្ថិតក្នុងដំណាក់កាលទី៣។ ជាមួយនឹងវិសាលភាពនៃការសម្រួលពាណិជ្ជកម្មជាមួយបណ្តាប្រទេសអាស៊ាន កម្ពុជាក៏បានចូលរួមក្នុងប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW) ដែលអាចឱ្យការបញ្ជូនក្នុងរយៈពេលតែមួយនូវទិន្នន័យដំណើរការព័ត៌មាន និងការសម្រេចចិត្តសម្រាប់ជម្រះបញ្ជីនិងប្រកាសពន្ធគយ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន។ តាមរយៈ ASW កម្ពុជាបាននិងកំពុងផ្លាស់ប្តូរជាមួយរដ្ឋសមាជិកអាស៊ាននូវឯកសារតាមប្រព័ន្ធអេឡិចត្រូនិកដូចជា វិញ្ញាបនបត្រនៃដើមកំណើតទំនិញ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) ទម្រង់ D ចាប់តាំងពីខែកក្កដា ឆ្នាំ ២០១៩ ក៏ដូចជាឯកសារប្រកាសគយអាស៊ាន (ACDD) ចាប់តាំងពីខែធ្នូ ឆ្នាំ ២០២០។ រាជរដ្ឋាភិបាលគ្រោងធ្វើ សមាហរណកម្ម CNSW ជាមួយ ASW។

៦១. វឌ្ឍនភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ត្រូវបានដាក់ឱ្យអនុវត្ត។ នៅខែមេសា ឆ្នាំ២០២៣ កម្ពុជាបានដាក់ចេញនូវបទប្បញ្ញត្តិដើម្បីដាក់ឱ្យដំណើរការកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ច

---

[15] ថ្លៃសេវាទាំងនោះ រួមមាន ថ្លៃសេវាគ្រប់គ្រងស្ថានីយ (THC) ដែលត្រូវបានកាត់បន្ថយមកត្រឹម ៥ ដុល្លារអាមេរិក/TEU ថ្លៃបន្ទុកអតុល្យភាពកុងតឺន័រ (CIC) មកត្រឹម ១០០ ដុល្លារអាមេរិក ចាប់ពី ១២០ ដុល្លារអាមេរិក សម្រាប់កុងតឺន័រកង់ ២០ និងមកត្រឹម ២០០ ដុល្លារអាមេរិក ចាប់ពី ២៤០ ដុល្លារអាមេរិក សម្រាប់កុងតឺន័រកង់ កង់ ៤០ ថ្លៃដឹកជញ្ជូនតាមមហាសមុទ្រ (OFC) ត្រូវបានកាត់បន្ថយ ៥០% និងថ្លៃបន្ទុក Bunker នៅគ្រាអាសន្ន (EBC) ត្រូវបានលុបចោល។

(AEO)។ កម្មវិធី AEO ផ្តល់អត្ថប្រយោជន៍មួយចំនួនដល់ AEOs រួមទាំងប្រព្រឹត្តកម្មជាអាទិភាពទាំងក្នុងការរៀបចំឯកសារ និងនីតិវិធីជម្រះបញ្ជីគយ ប៉ុន្តែត្រូវធ្វើតាមគោលការណ៍ចូលមុន-ចេញមុន ក្នុងចំណោម AEOs; ការលើកលែងនីតិវិធីផ្ទៀងផ្ទាត់ជាមុន មុនពេលជម្រះបញ្ជីគយ ដូចជាការវាយតម្លៃចំណាត់ថ្នាក់ពន្ធ ឬប្រភពដើម; ការបញ្ចប់ការជម្រះបញ្ជីគយមុនពេលការមកដល់នៃទំនិញ លទ្ធភាពនៃការជម្រះបញ្ជីទំនិញនៅគោលដៅ ឧទាហរណ៍ នៅឃ្លាំងដែលជាប់ពន្ធគយ កន្លែងស្តុកទុកបណ្តោះអាសន្ន ឬកន្លែងផ្ទាល់ខ្លួនរបស់ក្រុមហ៊ុន; លទ្ធភាពនៃការស្នើសុំការអនុញ្ញាតឱ្យនាំចូល នាំចេញ ឬឆ្លងកាត់ដោយផ្ទាល់នៅច្រកត្រួតពិនិត្យគយ ជំនួសឱ្យទីស្នាក់ការកណ្តាលនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ (GDCE); អាទិភាពក្នុងនីតិវិធីជម្រះបញ្ជីគយផ្សេងទៀតដែលកំណត់ដោយGDCE; ការលើកលែងពីកាតព្វកិច្ចស្តែនកុងតឺន័រ និងកាត់បន្ថយការត្រួតពិនិត្យផ្ទាល់ដោយអនុលោមតាមគោលការណ៍គ្រប់គ្រងហានិភ័យ; ការអនុញ្ញាតឱ្យជម្រះទំនិញមុនពេលទូទាត់ពន្ធគយ។ អ្នកទទួលផលពីកម្មវិធី AEO ក៏អាចទទួលបានអត្ថប្រយោជន៍ផ្សេងៗពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកជាមួយរដ្ឋបាលគយរបស់ប្រទេសផ្សេងៗទៀតផងដែរ។

**៦២.** គិតត្រឹមចុងខែមិថុនា ឆ្នាំ២០២៤ កម្ពុជាបានអនុវត្តវិធានការកិច្ចសម្រួលពាណិជ្ជកម្មចំនួន ៣៣ ដែលឆ្លើយតបទៅនិងចំនួន ៩២,៩% នៃការសន្យាក្នុងប្រភេទ A, B និង C ជាមួយនឹងការកំណត់ពេលវេលាចាប់ពីខែកុម្ភៈ ឆ្នាំ ២០១៧ ដល់ខែធ្នូ ឆ្នាំ ២០២៥។ វិធានការមានចំនួន ៥ ដែលស្ថិតក្នុងដំណាក់កាលកំពុងអនុវត្តដែលទាំងអស់នោះនៅក្នុងប្រភេទ C ដែលមានដូចជា៖ ការបង្កើតបញ្ជរតែមួយសម្រាប់ការនាំចូលនិងការនាំចេញ ការដឹកទំនិញឆ្លងកាត់ ទំនិញដែលអាចឆាប់ខូចគុណភាព ដំណើរការនីតិវិធីមុនពេលទំនិញមកដល់ និងកិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារតាមព្រំដែន។ ការសន្យាទាំងនេះត្រូវបានរំពឹងថា នឹងត្រូវបានអនុវត្តយ៉ាងពេញលេញត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។[16]

**៦៣.** លំហូរពាណិជ្ជកម្ម និងព័ត៌មានក៏ត្រូវបានទទួលអត្ថប្រយោជន៍ផងដែរពីការបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលជាការផ្លាស់ប្តូរទិន្នន័យរួម និងប្រកបដោយវិមជ្ឈការរវាងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការផ្តល់សេវាតាមស្តង់ដារ និងសុវត្ថិភាព ដែលធានាឱ្យមានអន្តរប្រតិបត្តិការរវាងភាគីផ្លាស់ប្តូរទិន្នន័យផ្សេងៗគ្នា។ CamDX មានគោលដៅអនុញ្ញាតឱ្យមានភាពងាយស្រួលក្នុងការចូលប្រើទិន្នន័យនៃប្រព័ន្ធរបស់រាជរដ្ឋាភិបាល ខណៈពេលដែលធានាបាននូវសុវត្ថិភាព និងភាពជាម្ចាស់នៃទិន្នន័យ។ កម្ពុជាក៏បានបង្កើត និងកែលម្អការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ពាណិជ្ជសញ្ញាផងដែរ។ កំណែទម្រង់ផ្សេងទៀតដើម្បីកែលម្អបរិយាកាសធុរកិច្ចរួមមាន ការអនុវត្តផែនការសកម្មភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ (ACU) ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈសកម្មភាពអប់រំ ការពារ និងអនុវត្តច្បាប់ ស្របតាម

[16] WTOមូលដ្ឋានទិន្នន័យអំពីការជួយសម្រួលពាណិជ្ជកម្ម.បានបើកមើល(ថ្ងៃទី០១ខែកក្កដាឆ្នាំ២០២៤) នៅ https://www.tfadatabase.org/en/members/cambodia/implementation-schedule.

ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយកំណត់ដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយដែលអង្គភាពទាំងពីរនេះត្រូវបានបង្កើតឡើងដោយច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០។

**៦៤.** ដំណើរការកំណែទម្រង់ក្នុងស្រុកក៏បានរួមបញ្ចូលនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដែលបានអនុវត្តក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ និងរហូតមកដល់បច្ចុប្បន្នផងដែរដូចជា ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដែលជាការវិនិយោគរួមគ្នារវាងសាធារណៈនិងឯកជន ដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដោយចំណាយសរុបជិត ១,៩ ពាន់លានដុល្លារអាមេរិក ដែលរួមមាន ផ្លូវល្បឿនលឿនមានបួនគន្លងពីទិសខាងលិចនៃរាជធានីភ្នំពេញតភ្ជាប់នឹងផ្លូវក្រវ៉ាត់ក្រុង និងរត់ពីទិសនិរតីរហូតដល់ខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ១៨៧ គីឡូម៉ែត្រ។ គម្រោងដទៃទៀត ដែលស្ថិតក្នុងដំណាក់កាលផ្សេងគ្នានៃការអនុវត្តរួមមាន តំបន់សេដ្ឋកិច្ចពិសេសបៃតង (SEZ ដែលមានតម្លៃប៉ាន់ស្មាន ចំនួន ៣០០ លានដុល្លារអាមេរិក)[17] កំពង់ផែទេសចរណ៍អន្តរជាតិកំពត បរិវេណកស្តុភារក្រុងព្រះសីហនុ (២៦៤ លានដុល្លារអាមេរិក) ព្រែកជីកហ្វូណន-តេជោ (១,៧ ពាន់លានដុល្លារអាមេរិក) មជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ (២២០ លានដុល្លារអាមេរិក) ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត (១,៣៨ ពាន់លានដុល្លារអាមេរិក) និងការអភិវឌ្ឍអាកាសយានដ្ឋានក្នុងតំបន់ថ្មីនៅភាគខាងកើតនៃខេត្តមណ្ឌលគិរី។

**៦៥.** ក្នុងគោលបំណងជំរុញផលិតភាព និងលើកកម្ពស់កម្រិតជីវភាពរស់នៅកាន់តែខ្ពស់ ការពិគ្រោះអំពីប្រាក់ឈ្នួលអប្បបរមាត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាជាតិស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលមានតំណាងមកពីរដ្ឋាភិបាល និយោជក និងនិយោជិត។ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាគឺធ្វើឡើងដោយការព្រមព្រៀង ប៉ុន្តែប្រសិនបើការព្រមព្រៀងមិនត្រូវបានសម្រេចជាឯកច្ឆន្ទបន្ទាប់ពីកិច្ចប្រជុំពីរដង ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយផ្អែកលើសន្លឹកឆ្នោតមតិភាគច្រើនដោយសម្ងាត់ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទីពីរ។ បន្ទាប់មក ក្រុមប្រឹក្សាផ្តល់អនុសាសន៍ដំឡើងប្រាក់ឈ្នួលអប្បបរមាដល់រដ្ឋាភិបាល។ ច្បាប់ការងារកម្ពុជាចែងថា ធាតុដែលត្រូវយកមកពិចារណានៅពេលកំណត់ប្រាក់ឈ្នួលអប្បបរមារួមមានកត្តាសង្គម និងសេដ្ឋកិច្ច រួមមានអតិផរណា ផលិតភាព ការប្រកួតប្រជែង ប្រាក់ចំណេញ និងស្ថានភាពទីផ្សារការងារ។ សម្រាប់ឆ្នាំ ២០២៤ ក្រុមប្រឹក្សាជាតិស្តីពីប្រាក់ឈ្នួលអប្បបរមាបានកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងមួយខែសម្រាប់កម្មករ/និយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ស្បែកជើង ទំនិញធ្វើដំណើរ និងកាបូប

---

[17] តំបន់សេដ្ឋកិច្ចពិសេសបៃតងមានបំណងចូលរួមចំណែកនៅក្នុងយុទ្ធសាស្ត្រមន្ទីរបញ្ចកោណរបស់ប្រទេសកម្ពុជា ដំណាក់កាលទី ១ គោលដៅនៃ "ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង" តាមរយៈការលើកកម្ពស់សេដ្ឋកិច្ចបៃតង ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ Green SEZ មានគោលបំណងប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងធាតុវង្វង់ ដើម្បីលើកកម្ពស់កម្ពុជាជាមជ្ឈមណ្ឌលផលិតកម្មឧស្សាហកម្មបៃតងក្នុងវិស័យអាទិភាពដូចជា រថយន្ត គ្រឿងអេឡិចត្រូនិក និងវាយនភណ្ឌកម្រិតខ្ពស់។ គម្រោងនេះក៏ព្យាយាមកែប្រែហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មរបស់កម្ពុជា ពីការប្រើប្រាស់កម្លាំងពលកម្ម ទៅជាការជំរុញជំនាញ។ ព័ត៌មានអំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភាពជាដៃគូសាធារណៈ និងឯកជន សូមមើលនៅ https://ppp.mef.gov.kh/detail/green-special-economic-zone?currentProjectListPid=200&cHash=b8c8afc49a7d00e915c325ebbe28065f

ចំនួន ២០៤ ដុល្លារអាម៉េរិកក្នុងមួយខែ។ នៅខែកញ្ញា ឆ្នាំ ២០២៤ ប្រាក់ឈ្នួលអប្បបរមានេះត្រូវបានកំណត់ឱ្យកើនឡើងដល់ ២០៨ ដុល្លារអាម៉េរិកក្នុងមួយខែសម្រាប់ឆ្នាំ ២០២៥ ដែលក្នុងនោះទឹកប្រាក់ចំនួន ២ ដុល្លារអាម៉េរិក ត្រូវបានបន្ថែមដោយរាជរដ្ឋាភិបាល។

**៦៦.** បន្ទាប់ពីបានដាក់ចេញនូវកំណែទម្រង់ជាច្រើន កម្ពុជាសម្រេចបាននូវដំណើរការសេដ្ឋកិច្ចដ៏រឹងមាំចាប់តាំងពីការចូលជាសមាជិក ដែលបានធ្វើឱ្យប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗកើនឡើងលើសពីរដង និងបាននាំឱ្យមានការថយចុះយ៉ាងខ្លាំងនៃអត្រាភាពក្រីក្រ។ ជាលទ្ធផលនៃកំណែទម្រង់របស់ខ្លួន កម្ពុជាបច្ចុប្បន្នមានសេដ្ឋកិច្ចបើកចំហ ដែលបង្ហាញឱ្យឃើញដោយអនុបាតពាណិជ្ជកម្មទំនិញ និងសេវាកម្មប្រហែល ១៥០% ហើយគោលនយោបាយពាណិជ្ជកម្មគឺជាផ្នែកសំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការលើកកម្ពស់ការអភិវឌ្ឍ និងកម្រិតជីវភាពរស់នៅ។ កម្ពុជាបានប្រើប្រាស់យ៉ាងល្អនូវសមាជិកភាព WTO របស់ខ្លួន ដើម្បីបន្តសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកល។ រចនាសម្ព័ន្ធពន្ធគយយ៉ាងសាមញ្ញ និងកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ និងបង្កើតបរិយាកាសធុរកិច្ចដែលមានតម្លាភាព និងអាចព្យាករណ៍បានកាន់តែច្រើនឡើង បានរួមចំណែកដល់ការជំរុញកំណើនកាន់តែលឿន។ ក្នុងរយៈពេល ២០ ឆ្នាំចាប់តាំងពីការចូលជាសមាជិក កម្ពុជាបានបន្តធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មដោយកាត់បន្ថយពន្ធនៅកម្រិត MFN និងតាមរយៈការធ្វើសមាហរណកម្មក្នុងតំបន់។ នៅឆ្នាំ ២០២៣ អត្រាពន្ធមធ្យមដែលអនុវត្តសម្រាប់ MFN គឺ ៩,៤% ទាបជាង (២០២៣) ១៩,៣% អត្រាអតិបរមាជាមធ្យម ។ MFN ជាមធ្យមដែលអនុវត្តពន្ធលើផលិតផលកសិកម្ម (និយមន័យ WTO) គឺ ១១,៩% (បើប្រៀបធៀបទៅនឹងអត្រាអតិបរមាឆ្នាំ ២០២៣ ដែលមាន ២៨%) ខណៈដែលអត្រាមធ្យមសម្រាប់ផលិតផលមិនមែនកសិកម្មគឺ ៩% (ធៀបនឹង អត្រាអតិបរមា ១៧,៩%) ។ យោងតាមការគណនារបស់លេខាធិការដ្ឋាន WTO ពាណិជ្ជកម្មដែលមានពន្ធគយមធ្យមទាបជាងគឺ ៧,៩% សម្រាប់ទំនិញទាំងអស់ ១១,៨% សម្រាប់ទំនិញកសិកម្ម និង ៧,៦% សម្រាប់ផលិតផលមិនមែនកសិកម្ម។[18] ពន្ធទាបបានដើរស្របគ្នាជាមួយនឹងកំណើនផ.ស.ស.ខ្ពស់ លំហូរពាណិជ្ជកម្មកាន់តែធំ និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន ។

[18] ព័ត៌មានអំពី WTO នៅ https://www.wto.org/english/thewto_e/countries_e/cambodia_e.htm

## សក្ខីកម្ម

"ការចូលជាសមាជិក WTO ជាជំហានតែមួយដ៏សំខាន់បំផុតដែលកម្ពុជាបានអនុវត្តក្នុងការចាប់យកគោលដៅរបស់ខ្លួន ដើម្បីក្លាយជាប្រទេសអភិវឌ្ឍន៍។ សមាជិកភាពបានធានាថា ផលិតផលកម្ពុជាអាចដាក់លក់បានគ្រប់ទីកន្លែងក្នុងពិភពលោក ប្រកបដោយតម្លាភាព និងអាចព្យាករណ៍បាន; ក្របខណ្ឌអនុគ្រោះពាណិជ្ជកម្មក្រោយក្របខណ្ឌ WTO មានផ្តល់ជូនប្រទេសកម្ពុជា; ហើយនិងរាល់ច្បាប់និងបទប្បញ្ញត្តិរបស់កម្ពុជាពាក់ព័ន្ធពាណិជ្ជកម្ម ត្រូវស្របតាមបទដ្ឋានអន្តរជាតិ។ ជាលទ្ធផល ពាណិជ្ជកម្មនិងវិនិយោគ ដែលមានលក្ខណៈអំណោយផលគឺជាមូលដ្ឋាននៃការរីកចម្រើននិងការអភិវឌ្ឍសង្គមដ៏អស្ចារ្យរបស់កម្ពុជា ក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ។ សូមអបអរសាទរខួប ២០ឆ្នាំ នៃបង្គោលចរដ៏មានសារៈសំខាន់នេះ។"

**លោក** Roger C. Lawrence,
អតីតអគ្គលេខាធិការរងនៃ
សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (UNCTAD)

# ៧. ភាពលទ្ធភាព និងបញ្ហាប្រឈមនៅពេលខាងមុខ

៦៧. កម្ពុជាត្រូវបានបញ្ចូលក្នុងបញ្ជីនៃ LDCs របស់អង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៩១។ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីគោលនយោបាយអភិវឌ្ឍន៍ ក្នុងអំឡុងពេលការត្រួតពិនិត្យរយៈពេលបីឆ្នាំម្តងនៅឆ្នាំ២០២១ បានកំណត់ថាកម្ពុជាបានបំពេញលក្ខខណ្ឌលើកទី១ ក្នុងការចាកចេញពីចំណាត់ថ្នាក់ LDCs ដោយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមលក្ខណៈវិនិច្ឆ័យទាំងបីសម្រាប់ការចាកចេញ។ សេចក្តីសន្និដ្ឋានរបស់គណៈកម្មាធិការត្រូវបានបញ្ជាក់ឡើងវិញថា កម្ពុជាបំពេញលក្ខខណ្ឌលើកទី២ ក្នុងអំឡុងពេលការត្រួតពិនិត្យរយៈពេលបីឆ្នាំម្តង នៅខែមីនា ឆ្នាំ ២០២៤។ គណៈកម្មាធិការបានស្វាគមន៍ចំពោះការសន្យាដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការឆ្ពោះទៅរកការចាកចេញ និងបានគាំទ្រសំណើរបស់កម្ពុជា សម្រាប់រយៈពេលត្រៀមបន្ថែមចំនួនប្រាំឆ្នាំ ដើម្បីធានាបាននូវការផ្លាស់ប្តូរដោយរលូន។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (ECOSOC) បានអនុម័តលើអនុសាសន៍នេះ ដែលត្រូវបញ្ជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីអនុម័ត។ កម្ពុជាត្រូវបានរំពឹងថានឹងចាកចេញពីចំណាត់ថ្នាក់ LDCs នៅឆ្នាំ២០២៩។

៦៨. នៅក្នុងការត្រួតពិនិត្យ គណៈកម្មាធិការបានសង្កេតឃើញថា កម្ពុជាបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវវិធានការគាំទ្រអន្តរជាតិ ជាពិសេសការទទួលបានទីផ្សារអនុគ្រោះ និងការរៀបចំកម្មសិទ្ធិបញ្ញា

ដែលបានរួមចំណែកដល់កំណើនដ៏ខ្ពស់របស់ស្ត្រីក្នុងកម្លាំងពលកម្ម។ កម្ពុជានឹងត្រូវការកសាងសមត្ថភាពផលិតកម្មបន្ថែម និងបន្តការធ្វើពិពិធកម្មផលិតផល និងទីផ្សារ ដើម្បីរក្សាភាពធន់នឹងការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ច ដើម្បីធានាបាននូវការប្រកួតប្រជែងរបស់ខ្លួន នៅពេលមិនមានវិធានការគាំទ្រដែលអនុវត្តចំពោះ LDCs ។ កម្ពុជានឹងត្រូវបង្កើនទំហំសារពើពន្ធរបស់ខ្លួន ហើយគួរតែផ្តោតលើឱកាសដែលកើតចេញពីអន្តរកម្មនៃការប្រើប្រាស់ថាមពល និងពង្រឹងសមត្ថភាពរបស់ខ្លួន (វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) ដើម្បីបង្កើនទៅខ្សែច្រវាក់តម្លៃ និងផលិតភាព និងដំណើរអភិវឌ្ឍន៍បច្ចេកវិទ្យា។ ការបន្តគាំទ្រពីដៃគូពាណិជ្ជកម្មនឹងត្រូវការជាចាំបាច់ ដើម្បីជួយដល់កម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកសាងភាពធន់នឹងអាកាសធាតុ។

៦៩. ដូចបានកត់សម្គាល់ខាងលើ ដោយមានកត្តាអំណោយផលនៃតម្លៃពលកម្មទាបរបស់កម្ពុជា និងច្រកទីផ្សារដោយមានភាពអនុគ្រោះទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប និងដោយការបើកចំហរចំពោះការធ្វើពាណិជ្ជកម្ម និងវិនិយោគ ការវិនិយោគផ្ទាល់ពីបរទេសជាពិសេសពីប្រទេសអាស៊ីផ្សេងទៀតបានហូរចូលទៅក្នុងឧស្សាហកម្មកាត់ដេរ ស្បែកជើង និងកាបូបធ្វើដំណើរ។ វិស័យនេះបានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្ន ផលិតផលទាំងនេះគឺជាផលិតផលនាំចេញចម្បងរបស់កម្ពុជា និងបានរួមចំណែកក្នុងការរកប្រាក់ចំណូលក្នុងប្រទេស។ ឧស្សាហកម្មនេះគឺជាប្រភពការងារផ្លូវការសម្រាប់កម្មករស្ត្រីវ័យក្មេង ដែលបានធ្វើចំណាកស្រុកទៅកាន់ទីក្រុង ដើម្បីជួយផ្គត់ផ្គង់គ្រួសាររបស់ពួកគេនៅតំបន់ជនបទ។ ក្រុមហ៊ុនជាច្រើននៅក្នុងឧស្សាហកម្មនេះ គឺជាអ្នកម៉ៅការបន្តនៃម៉ាកល្បីយ៉ាងច្រើន។ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រថ្មីសម្រាប់វិស័យកាត់ដេរ ស្បែកជើង និងទំនិញធ្វើដំណើរក្នុងឆ្នាំ២០២២ ដោយផ្តោតលើការលើកកម្ពស់ជំនាញរបស់កម្មករ ដើម្បីឆ្លើយតបទៅនឹងបរិយាកាសស្វ័យប្រវត្តិកម្ម និងឌីជីថល និងផ្តល់ការអប់រំកម្រិតឧត្តមសិក្សាលើផ្នែកវាយនភណ្ឌ រចនា និងវិស្វកម្មឧស្សាហកម្ម ការបញ្ជាទិញ ភស្តុភារកម្ម និងការគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់។ ជាមួយនឹងការបន្តវិនិយោគផ្ទាល់ពីបរទេស និងការទទួលបានហិរញ្ញប្បទានសម្រាប់អ្នកផលិតក្នុងស្រុក គោលបំណងគឺដើម្បីបង្កើនចំនួនក្រុមហ៊ុនផលិតដែលមានសមត្ថភាព អាចសម្រេចបាននូវរាល់កិច្ចការទាំងអស់រាប់ចាប់ពីការរៀបចំផលិតកម្ម និងគំរូ រហូតដល់ការដឹកជញ្ជូននៃទំនិញដែលមានការបញ្ជាទិញទៅកាន់អតិថិជននៅក្រៅប្រទេស។ ប្រសិនបើជោគជ័យ យុទ្ធសាស្ត្រនេះគួរតែលើកកម្ពស់និរន្តរភាពបរិស្ថាន និងធ្វើឱ្យការផលិតទំនិញមានតម្លៃខ្ពស់ជាងនេះនិងកាន់តែមានភាពធន់ទៅនឹងផលប៉ះពាល់នៃការបាត់បង់ភាពអនុគ្រោះពាណិជ្ជកម្ម បន្ទាប់ពីកម្ពុជាបានចាកចេញពីចំណាត់ថ្នាក់ LDC។

៧០. ចំពោះវិស័យទេសចរណ៍ រាជរដ្ឋាភិបាលបានរៀបចំផែនទីបង្ហាញផ្លូវមួយ ដើម្បីពន្លឿនការស្តារឡើងវិញពីផលប៉ះពាល់អវិជ្ជមាននៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងជំរុញការធ្វើឱ្យប្រសើរឡើងនូវជំនាញឌីជីថល និងជំនាញផ្សេងទៀតរបស់កម្មករ ជាពិសេសសម្រាប់ស្ត្រីដែលធ្វើការលើទីផ្សារនៃវិស័យដំណើរកម្សាន្ត។ បន្ថែមពីលើគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធទូទៅ និងបរិក្ខារហិរញ្ញប្បទាន ការអភិវឌ្ឍបន្ថែមទៀត

នៃឧស្សាហកម្មទេសចរណ៍របស់កម្ពុជា ទទួលយកបរិវត្តកម្មឌីជីថលដែលកំពុងដំណើរការ និងដំណោះស្រាយបច្ចេកវិទ្យាថ្មីៗ ដែលសម្រួលដល់អន្តរកម្មរវាងភ្ញៀវទេសចរណ៍ និងប្រតិបត្តិករអាជីវកម្ម។ នៅកម្រិតរដ្ឋាភិបាល ប្រព័ន្ធ e-arrival ថ្មីត្រូវបានដាក់ឱ្យដំណើរការនៅថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០២៤ នៅអាកាសយានដ្ឋានអន្តរជាតិទាំងបី ក្នុងគោលបំណងពង្រីកបន្តិចម្តងៗទៅកាន់ច្រកចូលផ្សេងទៀត។ ប្រព័ន្ធនេះអនុញ្ញាតឱ្យអ្នកចូលមកកាន់កម្ពុជា បំពេញបែបបទអន្តោប្រវេសន៍ទាំងអស់តាមអ៊ីនធឺណិត រួមទាំងការស្នើសុំទិដ្ឋាការ និងការបញ្ជាក់អំពីសុខភាព មុនពេលចេញដំណើរទៅកាន់ប្រទេសកម្ពុជា។ ជាងនេះទៅទៀត វិធានការបន្ថែមដែលផ្តល់ដោយរាជរដ្ឋាភិបាលគឺផ្តោតសំខាន់លើវិស័យទេសចរណ៍ក្នុងរាជធានីភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ ដែលនៅតែប្រឈមមុខនឹងបញ្ហាមួយចំនួន។ សហគ្រាសទេសចរណ៍ក្នុងខេត្តសៀមរាប ទទួលបានអត្ថប្រយោជន៍ពីការលើកលែងពន្ធផ្សេងៗ រួមទាំងពន្ធប្រចាំខែគ្រប់ប្រភេទ លើកលែងតែពន្ធលើតម្លៃបន្ថែម (VAT) និងពន្ធស្នាក់នៅចាប់ពីខែតុលា ឆ្នាំ២០២៣ រហូតដល់ចុងខែមិថុនា ឆ្នាំ២០២៤។

**៧១.** កម្ពុជាបានក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងបានកំណត់គោលដៅរបស់ខ្លួន ក្នុងការក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ (ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០) និងសេដ្ឋកិច្ចដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ (ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០) ដោយផ្តោតសំខាន់លើបរិយាប័ន្ន និងនិរន្តរភាពបរិស្ថាន។ គំរូកំណើនរបស់កម្ពុជាក្នុងរយៈកាលកន្លងមកគឺមានភាពផ្តោតខ្លាំងលើការប្រើប្រាស់ធនធាន និងសារធាតុកាបូន។ ទោះបីជាយ៉ាងណាក៏ដោយ កម្ពុជាគឺជាប្រទេសអាស៊ានដំបូងគេដែលបញ្ជាក់គោលដៅច្បាស់លាស់សម្រាប់អព្យាក្រឹតភាពកាបូននៅឆ្នាំ២០៥០ ដល់លេខាធិការដ្ឋាននៃអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ២០២១។ តម្រូវការថាមពលក្នុងស្រុកនាពេលអនាគតគឺ ត្រូវបំពេញដោយការពង្រីកវារីអគ្គិសនី និងថាមពលពន្លឺព្រះអាទិត្យ ក៏ដូចជាការសន្សំថាមពលដ៏សំខាន់នៅគ្រប់វិស័យសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានអនុម័តផែនការជាច្រើន ដើម្បីគាំទ្រការបំប្លែងកាបូនឱ្យមានកម្រិតទាប និងភាពបៃតង ជាពិសេសទាក់ទងនឹងការកែច្នៃ និងការគ្រប់គ្រងកាកសំណល់ ផលិតកម្មស្អាតនិងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិផល ការគ្រប់គ្រងការបំពុល ការបង្កើនការដាំដើមឈើ តំបន់ការពារដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព និងការពង្រឹងការអនុលោមនិងការសម្របសម្រួល។ មូលនិធិត្រូវបានប៉ាន់ស្មានសម្រាប់អន្តរកម្មនេះគឺមានចំនួន ៧,៨ ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០៣០ ហើយប្រហែលជាច្រើនដល់ទៅ ២,៥ ពាន់លានដុល្លារអាម៉េរិកជារៀងរាល់ឆ្នាំ ដើម្បីឈានដល់គោលដៅកាបូនសូន្យត្រឹមឆ្នាំ២០៥០។ ខណៈពេលដែលមូលនិធិសាធារណៈ និងជំនួយអភិវឌ្ឍន៍ក្រៅប្រទេសគួរតែត្រូវបានប្រមូលសម្រាប់សេដ្ឋកិច្ចបៃតង ហិរញ្ញប្បទានត្រូវបានរំពឹងថានឹងផ្តល់តាមរយៈការវិនិយោគពីវិស័យឯកជនក្នុងគំរូអាជីវកម្មបៃតង និងបរិយាបន្នក្នុងសង្គម។

**៧២.** ការសម្របខ្លួនដោយជោគជ័យនៃយុទ្ធសាស្ត្រកំណើនរបស់កម្ពុជា នឹងត្រូវតែភ្ជាប់មកជាមួយនូវការតាមដានយ៉ាងសកម្ម និងជាបន្តបន្ទាប់ លើបញ្ហាប្រឈម និងហានិភ័យដែលហួសពីការគ្រប់គ្រងរបស់កម្ពុជា ឧទាហរណ៍. ការកើនឡើងនៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ សង្គ្រាម ឬការវិលត្រឡប់ទៅរក

លទ្ធិគាំពារនិយមក្នុងសេដ្ឋកិច្ចធំៗ ប៉ុន្តែការត្រៀមខ្លួនជាប្រព័ន្ធជាមុន ឬការរៀបចំជាមុននៃវិធានការចាំបាច់ អាចកាត់បន្ថយផលប៉ះពាល់បានក្នុងកាលៈទេសៈបែបនេះ។ កម្ពុជាត្រូវគិតគូរពីការឆ្លើយតបទៅនឹងផលប៉ះពាល់ពាណិជ្ជកម្មដែលកើតចេញពីសេដ្ឋកិច្ចឧស្សាហូបនីយកម្ម ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ការកាប់បំផ្លាញព្រៃឈើ និងកង្វល់បរិស្ថានផ្សេងទៀត ជាឧទាហរណ៍ តាមរយៈយន្តការកំណត់តម្លៃកាបូន ឬសកម្មភាពជាក់លាក់របស់កម្ពុជា។ ជាចុងក្រោយ នៅក្នុងទីផ្សារដែលអ្នកនាំចេញកម្ពុជាទទួលបានអត្ថប្រយោជន៍ពីការអនុគ្រោះពាណិជ្ជកម្មដែលបានផ្តល់ជាឯកតោភាគី ហានិភ័យដែលការអនុគ្រោះពាណិជ្ជកម្មត្រូវបានបញ្ចប់ កំណត់លក្ខខណ្ឌ ឬកំណត់ឡើងវិញ នឹងនៅតែបន្តកើតមាន។

## សក្ខីកម្ម

"ខ្ញុំសូមចាប់ផ្តើមដោយការអបអរសាទរ រាជរដ្ឋាភិបាលកម្ពុជាក្នុងខួប ២០ឆ្នាំ នៃសមាជិកភាពរបស់អង្គការ WTO ។ នេះជាគំរូដ៏ល្អបំផុតមួយអំពី ការចូលជាសមាជិក WTO និងសមាជិកភាពនេះ មានប្រសិទ្ធភាពសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច។ សម្រាប់ខ្ញុំផ្ទាល់ នេះគឺជាសមិទ្ធផលមួយ ជាមួយនឹងការដឹងគុណរបស់ខ្ញុំនូវការរួមចំណែកជាមួយ WTO ក្នុងអាជីពការងាររយៈពេលវែង ដែលមានកិច្ចការច្រើនដែលត្រូវធ្វើជាមួយប្រទេសអភិវឌ្ឍន៍តិចតួច។ បទពិសោធន៍របស់កម្ពុជាបានផ្តល់មកខ្ញុំនូវការជឿជាក់ថាយ៉ាងមុតមាំថា WTO អាចបំពេញមុខងារប្រសិទ្ធភាពជូនប្រទេសអភិវឌ្ឍនតិចតួច។"

**លោកស្រី Maika Oshikawa,**
នាយកផ្នែកការចូលជាសមាជិក, អង្គការពាណិជ្ជកម្មពិភពលោក

# ៨. ជម្រើសគោលនយោបាយ

៧៣. កម្ពុជាមានការរីកចម្រើនយ៉ាងសម្បើមក្នុងរយៈពេល ២០ ឆ្នាំចាប់តាំងពីការចូលជាសមាជិក WTO ដោយធ្វើទំនើបកម្មសេដ្ឋកិច្ច និងបើកទូលាយដល់ពាណិជ្ជកម្ម។ យ៉ាងណាមិញ ដំណើរការនៃការធ្វើទំនើបកម្មសេដ្ឋកិច្ចនៅមិនទាន់បានបញ្ចប់នៅឡើយ។ ការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្នដែលស្ថិតនៅក្នុងគម្រោង គឺផ្អែកទៅលើមូលធនយ៉ាងខ្លាំង ក៏ដូចជាការពង្រីកវិសាលភាពរបស់ពួកគេ ដើម្បីបន្តសម្រួលពាណិជ្ជកម្ម។ នេះសំដៅដល់ការ វិនិយោគបន្ថែមលើផ្លូវថ្នល់ ការផលិតអគ្គិសនី អាកាសយានដ្ឋាន កំពង់ផែ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ហើយសំខាន់បំផុតគឺ ធនធានមនុស្ស។ ដូច្នេះ កម្ពុជាត្រូវបន្ត

ទាក់ទាញ FDI និងការផ្ទេរបច្ចេកវិទ្យាអន្តរជាតិ ដោយរក្សាបាននូវច្បាប់ និងបទប្បញ្ញត្តិវិនិយោគច្បាស់លាស់ និងស្ថិរភាព។

៧៤. ដូចដែលបានរៀបរាប់ខាងលើ ដើម្បីរក្សាសន្ទុះកំណើនសម្រាប់ឆ្នាំថ្មីៗខាងមុខនេះ កម្ពុជាចាំបាច់ត្រូវធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម និងការនាំចេញរបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលអនាគត កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័សឆ្ពោះទៅវិស័យដែលបច្ចុប្បន្នចាត់ទុកថាមានសក្តានុពលខ្លាំងជាង ដូចជា ការផលិតទំនិញ និងសេវាកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន។ ឧទាហរណ៍ តាមរយៈការលើកកម្ពស់ការផលិតសម្លៀកបំពាក់ដែលមិនប៉ះពាល់ដល់បរិស្ថាន និងទំនិញប្រើប្រាស់ផ្សេងទៀត ជំរុញទេសចរណ៍ដែលមិនប៉ះពាល់ដល់បរិស្ថាន និងការចូលរួមក្នុងសកម្មភាពនានាដែលអាចឈានទៅដល់ការសម្រេចបាននូវ eco-labels។ វិធានការគាំទ្រការបំប្លែង កាបូនទាប និងបៃតង ដូចបានរៀបរាប់ខាងលើ គឺជាចំណុចចាប់ផ្តើមដ៏ល្អ។ ជាមួយគ្នានេះ កម្ពុជាត្រូវបន្តពង្រឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ ២០២១-២០៣៥ ដោយជំរុញភាពជាសហគ្រិនឌីជីថល និងការច្នៃប្រឌិត រួមទាំងការលើកកម្ពស់ការចាប់ផ្តើមអាជីវកម្ម ដើម្បីលើកកម្ពស់និរន្តរភាពសេដ្ឋកិច្ច និងលើកកម្ពស់ការប្រកួតប្រជែង។

៧៥. ការលើកទឹកចិត្តដល់សកម្មភាពរបស់សហគ្រាសធុនតូច និងមធ្យម គឺជាចំណុចគោលនយោបាយសំខាន់មួយទៀត ដែលចាំបាច់ត្រូវមាននិរន្តរភាព និងពង្រឹងបន្ថែម តាមរយៈការសម្រួលដល់លទ្ធភាពទទួលបានឥណទាន ក៏ដូចជាការកាត់បន្ថយការចំណាយរបស់អ្នកខ្ចី និងការចំណាយលើការធ្វើអាជីវកម្ម រួមទាំងការសម្រួលដល់ក្របខណ្ឌបទប្បញ្ញត្តិ ការសម្របសម្រួលប្រតិបត្តិការពាណិជ្ជកម្មតាមរយៈការអនុវត្តពេញលេញនៃប្រព័ន្ធបញ្ជរតែមួយជាតិ និងវិធានការកិច្ចសម្រួលពាណិជ្ជកម្មដទៃទៀត។

៧៦. នៅខណៈពេលដែលការអភិវឌ្ឍច្បាប់ និងបទប្បញ្ញត្តិទំនើបមានសារៈសំខាន់បំផុត សមត្ថភាពអនុវត្ត និងការអនុវត្តច្បាប់ទាំងនោះគឺមានសារៈសំខាន់។ ដូច្នេះ ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលបន្ថែមទៀតគឺជាការជាចាំបាច់។ ក្នុងរយៈពេលមធ្យម និងវែង កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីការបង្កើនការវិនិយោគក្នុងវិស័យអប់រំ និងការកសាងសមត្ថភាព។

៧៧. នៅក្នុងវិស័យពាណិជ្ជកម្ម ច្បាប់និងគោលការណ៍របស់ WTO ផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការបន្តគោលនយោបាយដែលសំឡឹងមើលទៅខាងក្រៅ។ ខណៈពេលដែលអាស៊ាន និង RCEP ផ្តល់ឱកាសសម្រាប់សមាហរណកម្មក្នុងតំបន់កាន់តែជិតស្និទ្ធ កម្ពុជាក៏គួរតែស្វែងរកឱកាសទីផ្សារដោយការពង្រីកនូវការធ្វើ FTAs ទ្វេភាគី ដែលទាំងនេះអាចផ្តល់លទ្ធភាពទទួលបានទីផ្សារដ៏មានសក្តានុពល និងជួយដល់ដំណើរការនៃការធ្វើពិពិធកម្មទីផ្សារនាំចេញ និងផលិតផល។ កត្តានេះកាន់តែមានសារៈសំខាន់ ដោយសារកម្ពុជានឹងបាត់បង់ការអនុគ្រោះពាណិជ្ជកម្មឯកតោភាគីនៅក្នុងទីផ្សារធំៗ នៅពេលចាកចេញពីចំណាត់ថ្នាក់ LDC។

៧៨. ជាចុងក្រោយ ភាពជោគជ័យផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជា អាចធ្វើទៅបានដោយការប្រកាន់យកនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយការប្រុងប្រយ័ត្ន និងស្ថិរភាពក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ។ វាមានសារៈសំខាន់ណាស់ដែលមិនត្រូវងាកចេញពីគោលនយោបាយទាំងនេះ ដោយត្រូវផ្សារភ្ជាប់តម្រូវការដើម្បីគាំទ្រដល់កំណើនផ.ស.ស.ខ្ពស់ ខណៈពេលដែលរក្សាបាននូវអតិផរណានៅក្រោមការគ្រប់គ្រងបាន និងការបង្កើនទំហំសារពើពន្ធ។ ក្នុងន័យនេះ កម្ពុជាគួរតែផ្តោតសំខានលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ និងជំនួយបច្ចេកទេស ដើម្បីពង្រឹងការត្រៀមខ្លួនរបស់កម្ពុជា ដើម្បីអនុលោមតាមច្បាប់ពាណិជ្ជកម្មអន្តរជាតិទាំងអស់ បន្ទាប់ពីបានចាកចេញពីចំណាត់ថ្នាក់ LDC។

## សក្ខីកម្ម

"ចាប់តាំងពីបង្កើតអាជ្ញាធរអន្តរកាលនៃអង្គការសហប្រជាជាតិនៅកម្ពុជាក្នុងឆ្នាំ ១៩៩២ និងការចូលជាសមាជិក WTO ក្នុងខែតុលា ឆ្នាំ២០០៤ ស្ថាប័ន UNCTAD បានគាំទ្រគួរជាទីមោទនៈនូវកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកសាង និងពង្រឹងស្ថាប័នសេដ្ឋកិច្ចរបស់ខ្លួន។ ដំណើររបស់កម្ពុជា បានបង្ហាញយ៉ាងច្បាស់ថា គោលនយោបាយពាណិជ្ជកម្មប្រកបដោយមហិច្ឆិតា អាចផ្តល់នូវការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងនិរន្តរភាព។ ការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះវិធានពាណិជ្ជកម្មអន្តរជាតិ បានពង្រឹងស្ថានភាពរបស់ខ្លួន ក្នុងនាមជាសមាជិកដ៏គួរឱ្យទុកចិត្ត និងសកម្ម ក្នុងសហគមន៍ ពាណិជ្ជកម្មសកល។"

**លោកស្រី** Luz ma de la Mora,
នាយកផ្នែកពាណិជ្ជកម្មអន្តរជាតិ នៃសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (UNCTAD)

# ៩. សេចក្តីសន្និដ្ឋាន

៧៩. ការចូលជាសមាជិក WTO របស់កម្ពុជា ក្នុងឆ្នាំ២០០៤ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងសមាហរណកម្មសកល។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានប្រើប្រាស់សមាជិកភាពWTOរបស់ខ្លួន ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ចូលរួមយ៉ាងសកម្មនៅក្នុងប្រព័ន្ធពាណិជ្ជកម្មសកល និងកែទម្រង់ក្នុងស្រុកយ៉ាងច្រើន។ ដំណើរនេះឆ្លុះបញ្ចាំងពីការសន្យារបស់កម្ពុជាក្នុងការទទួលយកសកលភាវូបនីយកម្ម ការពង្រឹងស្ថាប័នរបស់ខ្លួន និងការរៀបចំខ្លួនជាអ្នកដើរតួយ៉ាងស្វាហាប់នៅក្នុងសេដ្ឋកិច្ចពិភពលោក។

៨០. កម្ពុជាបានក្លាយជាសមាជិកយ៉ាងសកម្មនៅក្នុង WTO ដោយបានចូលរួមក្នុងការចរចាផ្សេងៗ និងធ្វើឱ្យគោលនយោបាយពាណិជ្ជកម្មរបស់ខ្លួនស្របតាមស្តង់ដារអន្តរជាតិ។ ការចូលរួមយ៉ាងសកម្មនេះបានជួយសម្រួលដល់ការបង្កើនពាណិជ្ជកម្ម និងការវិនិយោគ ដែលរួមចំណែកដល់ដំណើរការសេដ្ឋកិច្ចដ៏គួរឱ្យចាប់អារម្មណ៍។ កំណើននៃ ផ.ស.ស. របស់ប្រទេសទទួលបានកំណើនក្នុងកម្រិតមួយខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍ ដែលជំរុញដោយការនាំចេញដ៏រឹងមាំ ជាពិសេសក្នុងវិស័យវាយនភណ្ឌ កសិកម្ម និងទេសចរណ៍។ ការធ្វើពិពិធកម្មដៃគូពាណិជ្ជកម្ម និងផលិតផលរបស់ខ្លួនក៏បានជួយកម្ពុជាកាត់បន្ថយការពឹងផ្អែកលើទីផ្សារតែមួយ ដែលជាលទ្ធផលជួយពង្រឹងនូវភាពធន់នៃសេដ្ឋកិច្ច។

៨១. កាតព្វកិច្ចក្រោមក្របខណ្ឌ WTO គឺជាកត្តាជំរុញដល់កំណែទម្រង់ក្នុងស្រុកដ៏ទូលំទូលាយនៅកម្ពុជា។ ប្រទេសនេះបានបោះជំហានយ៉ាងសំខាន់ក្នុងការកែលម្អបរិយាកាសច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនដើម្បីអនុលោមតាមច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ កំណែទម្រង់ទាំងនេះរួមមានការធ្វើទំនើបកម្មនៃនីតិវិធីគយ ការពង្រឹងការការពារកម្មសិទ្ធិបញ្ញា និងការអនុម័តច្បាប់ផ្សេងៗទាក់ទងនឹងពាណិជ្ជកម្ម។ តាមរយៈការអនុលោមតាមបទប្បញ្ញត្តិរបស់ខ្លួនជាមួយនឹងស្តង់ដារពិភពលោក កម្ពុជាបានបង្កើតបរិយាកាសធុរកិច្ចប្រកបដោយតម្លាភាព និងអាចព្យាករណ៍បានទាក់ទាញ FDI និងជំរុញកំណើនវិស័យឯកជន។

៨២. នៅពេលដែលកម្ពុជារៀបចំខ្លួនដើម្បីចាកចេញពីឋានៈ LDC រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយកាត់បន្ថយផលប៉ះពាល់ពីការបាត់បង់អត្ថប្រយោជន៍ ដែលទទួលបានពីការអនុគ្រោះពាណិជ្ជកម្មដោយផ្តោតលើការលើកកម្ពស់ការប្រកួតប្រជែងនៃឧស្សាហកម្មក្នុងស្រុក ការវិនិយោគលើធនធានមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រតម្លៃបន្ថែមខ្ពស់នៃផលិតកម្ម។ ក្នុងពេលជាមួយគ្នានេះ កម្ពុជាបាននិងកំពុងធ្វើការសិក្សាលើយុទ្ធសាស្ត្រពាណិជ្ជកម្ម ដើម្បីស្វែងរកការចាកចេញពីឋានៈ LDC ដោយរលូន និងក្រោយពេលចាកចេញ។ ជាងនេះទៅទៀត កម្ពុជាបានត្រៀមលក្ខណៈយ៉ាងល្អសម្រាប់ទប់ទល់នឹងវិបត្តិខាងក្រៅនាពេលអនាគត ដូចជាការធ្លាក់ចុះសេដ្ឋកិច្ចសកល ផលប៉ះពាល់អវិជ្ជមាននៃភាពតានតឹងភូមិសាស្ត្រនយោបាយ និងជំងឺរាតត្បាត តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសុខុមាលភាព និង

សុវត្ថិភាពសង្គម ដើម្បីធានាថាកម្ពុជានឹងដើរលើផ្លូវត្រូវ ឆ្ពោះទៅរកការផ្លាស់ប្តូរដោយរលូន។ វិធីសាស្ត្រក្នុងការកសាងភាពធន់នេះគឺមានសារៈសំខាន់ណាស់ នៅពេលដែលប្រទេសនេះក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ក៏ដូចជានឹងប្រឈមមុខនូវបញ្ហាថ្មីៗនៅក្នុងទីផ្សារពិភពលោក។ គោលនយោបាយសំឡឹងមើលទៅខាងក្រៅរបស់រាជរដ្ឋាភិបាលមានសារៈសំខាន់ក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ខ្លួន។ ប្រទេសនេះបានទទួលយកសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបានចូលទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ និងទ្វេភាគី។ គោលនយោបាយទាំងនេះបានបើកទីផ្សារថ្មីសម្រាប់ផលិតផលនិងសេវាកម្មកម្ពុជា ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកាត់បន្ថយភាពងាយរងគ្រោះចំពោះការផលប៉ះពាល់ពីខាងក្រៅ។

៨៣. ដោយសម្លឹងមើលទៅខាងមុខ កម្ពុជាបន្តអនុវត្តគោលនយោបាយដែលលើកកម្ពស់ការប្រកួតប្រជែងជាសកល រួមទាំងកំណើនដែលជំរុញដោយនវានុវត្តន៍ ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងការអភិវឌ្ឍនិងកំណើនប្រកបដោយចីរភាព។ ដោយទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីសមាជិកភាព WTO របស់ខ្លួនក្នុងរយៈពេល២០ឆ្នាំ កម្ពុជាចាំបាច់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនបន្ថែមទៀតជាមួយដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយពាក់ព័ន្ធពាណិជ្ជកម្ម ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគតរបស់ខ្លួន និងដើម្បីធានាគោលដៅយូរអង្វែងរបស់ខ្លួន ក្នុងការក្លាយជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ លើសពីនេះទៀត កម្ពុជាត្រូវទាក់ទាញ FDI បន្ថែមទៀត និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើទំនើបកម្មច្បាប់ និងបទប្បញ្ញត្តិ ដើម្បីដើរឱ្យទាន់ការវិវត្តនៃសេដ្ឋកិច្ចសកល។




សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៥នៃ WTO។
ទីក្រុង Cancún ប្រទេសម៉ិចស៊ិក

5th Ministerial Conference of the WTO.
Cancún, Mexico

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣
**11 September** 2003



**ឯកឧត្តម ចម ប្រសិទ្ធ** អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ថ្លែងសុន្ទរកថា នៅក្នុងឱកាសសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៥ នៃ WTO។
ទីក្រុង Cancún ប្រទេសម៉ិចស៊ិក

**H.E Cham Prasidh**, Former Minister of Commerce of Cambodia, delivered remarks at the 5th WTO Ministerial Conference.
Cancún, Mexico

ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០០៣
**12 September** 2003




ពិធីចុះហត្ថលេខាលើពិធីសារអំពីការចូលជាសមាជិក WTO របស់កម្ពុជា ក្នុងឱកាសសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៥ នៃ WTO។
ទីក្រុង Cancún ប្រទេសម៉ិចស៊ិក

The Signing Ceremony of the Protocol of Cambodia's Accession to the WTO during the 5th Ministerial Conference of the WTO.
Cancún, Mexico

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៣
**13 September** 2003




**លោក** J. Denis Bélisle អតីតនាយកប្រតិបត្តិនៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) និង **ឯកឧត្តម ចម ប្រសិទ្ធ** ក្នុងឱកាសសន្និសីទសារព័ត៌មានស្តីពីជំនួយរបស់ ITC ដល់កម្ពុជា។
ទីក្រុង Cancún ប្រទេសម៉ិចស៊ិក

**Mr. J. Denis Bélisle**, former Executive Director of the International Trade Centre (ITC) and **H.E Mr. CHAM Prasidh** during the press conference on the aid of ITC to Cambodia.
Cancún, Mexico

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៣
**13 September** 2003




រូបភាពរបស់**ឯកឧត្តម ចម ប្រសិទ្ធ** ផ្តល់កិច្ចសម្ភាសន៍ជាមួយ
អ្នកសារព័ត៌មាននៅក្នុងឱកាសសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៥
នៃ WTO។
ទីក្រុង Cancún ប្រទេសម៉ិចស៊ិក

**H.E. Mr. CHAM Prasidh** was being interviewed by journalists during the 5th Ministerial Conference of the WTO.
Cancún, Mexico

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៣
13 September 2003



ពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងក្របខណ្ឌពាណិជ្ជកម្ម និងវិនិយោគ
រវាងកម្ពុជានិងសហរដ្ឋអាម៉េរិក។
ស្ថានទូតកម្ពុជាប្រចាំសហរដ្ឋអាម៉េរិក

The Signing Ceremony of Trade and Investment Framework Agreement between Cambodia and USA.
Cambodian Embassy in the United States

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦
14 July 2006




ពិធីបំពាក់គ្រឿងឥស្សរិយយស សហមេត្រីថ្នាក់មហាសិរីវឌ្ឍន៍ ជូនដល់ ឯ.ឧ. Pacal Lamy អតីតអគ្គនាយក WTO។
វិមានសន្តិភាព, ប្រទេសកម្ពុជា

Ceremony of Conferment of the Grand Cross of the Royal Order of Sahametrei to **H.E. Mr. PASCAL LAMY,** former Director General of the WTO.
Peace Palace, Cambodia

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២
20 Nov 2012




ក្នុងនាមជាម្ចាស់កម្មវិធីសង្គមវប្បធម៌ កម្ពុជាបានស្វាគមន៍ភ្ញៀវអន្តរជាតិអញ្ជើញចូលរួមទស្សនាការសម្តែងរបាំប្រពៃណីខ្មែរ និងពិសាម្ហូបអាហារខ្មែរ។
អង្គការពាណិជ្ជកម្មពិភពលោក

As the host of "Socio-Cultural Program", Cambodia organized and welcomed the international guests to watch the traditional Khmer dances, cuisine, and other appetizers.
The World Trade Organization

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩
3 July 2019




**ឯកឧត្តម Roberto Azevêdo** អតីតអគ្គនាយក WTO ទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យឡើងវិញជាសកលលើកទី៧ ស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម។
អង្គការពាណិជ្ជកម្មពិភពលោក

**H.E. Mr. Roberto Azevêdo**, former DG of the WTO, welcomed **Samdech Akka Moha Sena Padei Techo HUN SEN**, former Prime Minister, Kingdom of Cambodia, at the 7th Global Review of Aid for Trade.
The World Trade Organization

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩
3 July 2019




**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្លែងសុន្ទរកថា កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យឡើងវិញជាសកលនូវជំនួយសម្រាប់ពាណិជ្ជកម្ម"។
អង្គការពាណិជ្ជកម្មពិភពលោក

**Samdech Akka Moha Sena Padei Techo HUN SEN,** former Prime Minister, Kingdom of Cambodia, delivered a keynote address at "Aid for Trade Global Review".
The World Trade Organization

៣ ខែកក្កដា ឆ្នាំ២០១៩
3 July 2019

## FOREWORD BY

# SAMDECH AKKA MOHA SENA PADEI TECHO HUN SEN,

## PRESIDENT OF THE SENATE OF THE KINGDOM OF CAMBODIA

Since the late 1990s, the people of Cambodia have been living under the umbrella of complete peace, political stability, and a fledging economy, which were the results of the efforts of the Royal Government of Cambodia in implementing vision, policies, strategies, plans and other reform programs. These were carried out under the spirit of proactiveness and high responsibility in order to ensure economic growth, promote competitiveness, reduce poverty and strengthen social development.

Based on these factors, the Royal Government began to look at integrating Cambodia into the regional and global economy, in which the decision to negotiate an accession to the World Trade Organization (WTO) in the late 1990s was a decision that is correct and forward-looking, even though Cambodia's economy at that time was not yet strong. The decision was also based on the Royal Government's careful weighing of the benefits and challenges, as well as the regulations and policies of Cambodia at that time against the requirements of accession and all the reforms that Cambodia will have to implement after becoming a full member. From a long-term perspective, Cambodia actively participated in the negotiations for accession to the World Trade Organization until its completion and become the 148$^{th}$ member of the WTO on 13 October 2004.

As a full member of the WTO, Cambodia gained access to the market under Most Favoured Nation (MFN), as well as special and differential treatment, especially preferential market access and other specific measures, offered to Cambodia as a Least Developed Country (LDC) Member, which was stipulated in various agreements and provisions of the WTO. Cambodia also benefited from various support measures in the form of capacity building and technical assistance from the WTO and from other Members and development partner institutions, which were crucial in the implementation of reform programs that Cambodia committed upon

acceding and in the achievement of various national development objectives, as well as accelerating its full integration into the multilateral trading system.

Over the past 20 years, Cambodia has achieved many tangible outcomes, including: an increase in trade volume from USD 4.5 billion in 2004 to USD 47.88 billion in 2023, with exports rising by more than 940% and reaching a target market of up to 177 countries. Foreign direct investment grew from USD 110 million in 2000 to USD 4.92 billion in 2023. The gross domestic product per capita increased from just USD 410 in 2004 to USD 1,875 in 2023. These factors contributed to reducing the poverty rate from 60% in 2000 to just 16% in 2022. Furthermore, WTO membership has facilitated Cambodia's transformation from an economy heavily reliant on agriculture to one characterized by industrialization and diversification, allowing Cambodia to export various products across multiple sectors, including agriculture, textiles, and more, such as rice, cassava, mango, rubber, garments, footwear, travel goods, bicycles, electronic components, automotive parts, and many more value-added products.

WTO membership also provided Cambodia with opportunities to enhance institutional capacity and empower officials in negotiating bilateral and regional free trade agreements to open additional markets beyond the preferential markets obtained through the WTO. These achievements reflect the success of implementing an economic policy that considers trade as the main driving force for national economic development, enabling Cambodia to achieve an average economic growth rate of 7% over the past 20 years, prior to the onset of the COVID-19 pandemic in 2019.

With Cambodia's rapid socio-economic development over the past 20 years, as a WTO member, Cambodia has also actively contributed, alongside other members, to improve multilateral trade rules and support the reform of this organization towards becoming a global trade institution that is inclusive, equitable, and effective, with development at its core. Cambodia is the first LDC Member to establish a Permanent Mission to the WTO and other International Organisations (Economic and Trade) in Geneva, Switzerland, in 2017, and has deservedly assumed the role of the Coordinator for the LDC Group that serves comprehensive interests of all LDC Members as well as playing a pivotal role in discussions and negotiations on important and beneficial topics for LDC Members. These efforts reflect the

importance Cambodia attaches to the multilateral trading system, with the WTO at its core, as well as demonstrating Cambodia's full capacity and potential in participating in discussions on various issues and contributing to solutions and improvements of the global trading framework for national benefits.

At the same time, amidst a global economic landscape that is changing and uncertain, Cambodia faces new challenges, including changes in economic structure and architecture, geopolitical competition leading to trade wars, protectionism and nationalism, as well as climate change and the rapid evolution of digital technology. In this sense, Cambodia must adapt to these global trends and strategically plan for socio-economic development by phases to achieve the visions 2030 and 2050. In line with this vision, the government has launched a Phase I strategy for "Growth, Employment, Equity, Efficiency, and Sustainability," which focuses primarily on: 1) maintaining peace and stability, economic growth, and inclusive development; and 2) building and strengthening the foundation to drive national development momentum.

Based on the achievements and key visions highlighted in the report on "Cambodia's 20-Year Journey as a WTO Member" prepared by the Ministry of Commerce, I would like to express my high appreciation and commendation to the Ministry of Commerce and relevant ministries and institutions that have participated effectively and actively under the WTO framework in fulfilling our obligations and building Cambodia's socio-economic landscape.

I would like to extend my deep appreciation to the distinguished negotiators and the Cambodian negotiation team, led by **H.E. Kitti Settha Pandita Cham Prasidh**, former Minister of Commerce, who have dedicated their utmost effort to successfully negotiate Cambodia's membership in the WTO. These achievements reflect a significant collaborative effort that relentlessness in pursuing progress and prosperity for the national benefit and the welfare of all Cambodian people.

# FOREWORD BY SAMDECH MOHA BORVOR THIPADEI HUN MANET, PRIME MINISTER OF THE KINGDOM OF CAMBODIA

Through adopting and implementing the Royal Government's Triangle Strategy and Rectangular Strategy in the past, Cambodia has integrated the trade and economy into the region and the world in order to create opportunities of the greater economic dimensions and benefit Cambodia's economy; in particular, becoming the 148$^{th}$ member of the World Trade Organization (WTO) on October 13, 2004 through Cambodia's intensive and active negotiations with the members since the 1990s under the strategic guidance and recommendation by **Samdech Akka Moha Sena Padei Techo HUN SEN, former Prime Minister of the Kingdom of Cambodia**, is a historic and strategic step with a long-term vision.

Following its accession to the WTO, the Royal Government of Cambodia (RGC) has been implementing its obligations to reform the policies and laws that Cambodia committed in its Protocol of Accession to the WTO to bring the Cambodian trade regime in line with the WTO rules. The RGC has enacted and amended a number of laws related to trade, including Law on Rules of Origin; Law on Intellectual Property; Law on Marks, Trade Names and Acts of Unfair Competition; Law on Geographical Indication Mark; Law on Commercial Enterprises; Law on Commercial Rules and Business Registration; Law on Food Safety; Law on Competition; Law on Consumer Protection; Law on Electronic Commerce; Law on Trade Remedies; Law on Investment; Law on Secured Transactions, as well as other many regulations which are the commitment of Cambodia as the member of the WTO. The government also set out many policies and strategies to further promote economic development and respond to global trends, which includes Cambodia Industrial Development Policy, Digital Economy and Society Policy Framework, Cambodia Trade Integration Strategy, E-Commerce Strategy, Strategic Plan to Maximize Benefits from the Implementation of FTAs, and specific national policy by sectors such as cashew nuts, cassava and silk.

In addition to fulfilling the obligations, as an LDC member of the WTO, Cambodia also enjoys many benefits, such as wider market access with trade

preferential system and duty-free quota-free (DFQF) treatment, Special and Differential Treatment (SDT), and other preferential measures under the WTO framework, which are an important basis for Cambodia's full integration into the multilateral trading system. All these factors have helped Cambodia achieve many significant achievements related to the trade and economy, such as high economic growth, increase in trade and investment volumes, product and market diversification and diversified production bases; significantly contributed to job creation and increased household income as well as reduced the poverty in the last 20 years.

2024 marks the 20th anniversary of Cambodia's accession to the WTO. To celebrate this great event, as well as to reflect Cambodia's roles and achievements over the past two decades, the Ministry of Commerce has prepared a brief report on “Cambodia's 20 Years as a WTO Member". The report clearly highlights Cambodia's role and activities as a WTO member, the benefits of trade preferential system, bilateral and regional trade agreements, economic growth strategies, domestic reform, opportunities and challenges, and policy options.

Finally, I would like to thank the Ministry of Commerce for leading the production of this valuable document, and I strongly believe that this report will be an important document for public awareness; the inputs into ways forward of Cambodia's economic and trade integration in the WTO; and a reference for students and researchers. In particular, this document reflects the historic and strategic steps of the integration into the global economy in the history of Cambodia, resulted from the right decision and long-term vision of **Samdech Akka Moha Sena Padei Techo HUN SEN, former Prime Minister of the Kingdom of Cambodia**.

## ACKNOWLEDGEMENTS

# HER EXCELLENCY MRS. CHAM NIMUL,

## MINISTER OF COMMERCE OF THE KINGDOM OF CAMBODIA

On behalf of the leaders, the officials of the Ministry of Commerce and on my own behalf, I would like to express my deep gratitude to **Samdech Akka Moha Sena Padei Techo HUN SEN, former Prime Minister of the Kingdom of Cambodia** and the Council of Ministers in the past legislatures, who set the clear goals and vision, and historically made the right decision to let the Kingdom of Cambodia access to the World Trade Organization (WTO). The glorious achievements **Samdech Akka Moha Sena Padei Techo** brought to the nation in the trade and economic sectors are remarkable and priceless for the Kingdom of Cambodia and all Khmer people.

Furthermore, I would like to express my deep gratitude and profound appreciation to all 166 members of Cambodia's Accession Negotiation Team, head by **H.E. Kitti Settha Pandit CHAM Prasidh, former Minister of Commerce** and Chairman of Cambodia's Accession Negotiation Team, for successfully leading the negotiations for Cambodia's accession successfully. I would like to express my sincere thanks to the leaders of the Ministry of Commerce and relevant ministries-agencies of the previous legislatures in the last 20 years, who properly led and jointly implemented the reform of the trade regime compliant with the rules of the WTO framework as well as fully utilize this membership to the fullest potential and bring about the real prosperity of the national economy. Taking this opportunity, I would also like to thank all the development partners who have supported Cambodia in the pre-accession and post-accession periods, including technical and financial assistance, all of which are the crucial contribution to the successful accession negotiation and implementation of the reform.

Finally, I would like to express my deepest gratitude to **Samdech Moha Borvor Thipadei HUN MANET, Prime Minister of the Kingdom of Cambodia** for continuing to sustain Cambodia's achievements and lead Cambodia with a long-term vision in building the foundation to achieve the Cambodia Vision 2050. On behalf of the leaders and officials of the Ministry of Commerce, I would like to commit as the civil servant to more effectively delivering significant results and jointly implementing the policies of the Royal Government, especially the Pentagon Strategy-First Phase to bring about the development, growth, prosperity, stability, sustainability for the nation.

## Co-writers:

Mr. **Cato Adrian** and Mr. **Angelo Silvy**, retired staff members of the Trade Policy Review Division of the World Trade Organisation, and experts in trade policy and accessions.

## Contributors:

| | |
|---|---|
| - H.E. Mr. **SOK Sopheak** | Secretary of State, Ministry of Commerce, Cambodia |
| - H.E. Mr. **PICH Rithy** | Secretary of State, Ministry of Commerce, Cambodia |
| - H.E. Mr. **LONG Kemvichet** | Director-General of International Trade |
| - H.E. Mr. **SUON Prasith** | Ambassador and Permanent Representative of the Permanent Mission of the Kingdom of Cambodia to the World Trade Organisation (WTO) and other International Organisations (Economy and Trade) in Geneva, Switzerland |
| - H.E. Mr. **Sven CALLEBAUT** | Advisor to the Ministry of Commerce, Cambodia |
| - Mr. **ENG Sothyvon** | Deputy Director-General of Trade in Service |
| - Mr. **SOK Bunthorn** | Deputy Director-General of International Trade |
| - Mr. **SEANG Hong** | Director of Department of Notification and Legal Compliance (DNLC) |
| - Mr. **KONG Sokheng** | Trade Counsellor |
| - Mr. **SUOS Imsouchivy** | Trade Counsellor |
| - Mr. **KONG Sotheara** | Deputy Director of DNLC |
| - Mr. **NEN Chansamuth** | Commercial Attaché |
| - Mr. **TENG Chivon** | Chief of Office, DNLC |
| - Ms. **MEY Molika** | Chief of Office, DNLC |
| - Mr. **THOEM Pheara** | Deputy Chief of Office |

## Reviewed and edited by:

Information and Public Relations Working Group, Ministry of Commerce

**Published in Khmer and English**
**First Edition: October 2024**

**Copyright and Published by the Ministry of Commerce, Kingdom of Cambodia.**

**Address:** Lot 19-61, Boulevard of the Russian Federation
Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of Cambodia
**Phone:** 1266
**Email:** cabinet.info@moc.gov.kh

# CAMBODIA'S 20-YEAR JOURNEY AS A WTO MEMBER

## 1. INTRODUCTION

**1.** The Royal Government of Cambodia (RGC) adopted a *National Programme to Rehabilitate and Develop Cambodia* based on market economy principles in 1994. The reintegration of Cambodia into the regional and global economy featured among the many necessary elements of the programme. Cambodia submitted a request to be a founding member of the WTO in October 1994, and the WTO Working Group was formed. However, the process of reviewing and approving Cambodia's proposal was delayed because the WTO was officially established on January 1, 1995, and Cambodia needed to go through negotiation process to become a member in accordance with Article XII of the Marrakesh Agreement Establishing the WTO, which required Cambodia to prepare a memorandum of understanding on the foreign trade regime and the government's negotiating team.

**2.** Between 1996 and 1999, the RGC created a team to prepare the relevant documents and officially submitted the Memorandum on the Foreign Trade Regime of Cambodia to the WTO in May 1999. The Working Party held five formal meetings under the Chairmanship of Mr. Andrea Meloni (Italy) to work out the accession terms between May 2001 and 22 July 2003. In all, 24 Member delegations (counting the European Communities and its member states as one delegation) joined the Working Party.

**3.** WTO Members approved Cambodia's accession package (as well as Nepal's package) at the Fifth WTO Ministerial Conference in Cancún, Mexico on 11 September 2003. Cambodia and Nepal became the first least-developed countries (LDCs) to join the WTO through full working party negotiations. Cambodia formally notified the WTO Secretariat that it had accepted its accession terms on 13 September 2004, and consequently became the WTO's 148th Member 30 days later, i.e. on 13 October 2004.

**4.** In the later stages, Cambodia's negotiations were given impetus by the Decision of the WTO General Council of 10 December 2002 (document WT/L/508)

to facilitate and accelerate the accessions of LDCs through simplified and streamlined procedures. Under this Decision, WTO Members were to exercise restraint in seeking concessions and commitments on trade in goods and services, keeping in mind the terms of existing WTO LDC Members. Accession to the WTO's Plurilateral Agreements (Government procurement and trade in civil aircraft) or participation in optional sectoral market access initiatives would not be a precondition for WTO Membership. Nevertheless, acceding LDCs were to offer reasonable market access for goods and services commensurate with their individual development, financial and trade needs. Special and differential treatment rules, as laid down in WTO agreements and other legal instruments, were applicable to all LDCs. Transitional periods and arrangements were to be granted, taking into account individual development, financial and trade needs, to be accompanied by specific action plans to reach WTO compliance. As necessary, implementation would be supported by technical assistance and capacity building measures from WTO Members.

**5.** Cambodia's accession Working Party report (document WT/ACC/KHM/21), which includes its Protocol of Accession, sets out the terms and conditions for ensuring, or reaching, compliance with WTO rules. Market access granted by Cambodia to other WTO Members is spelled out in documents WT/ACC/KHM/21/Add.1 (goods) and WT/ACC/KHM/21/Add.2 (services).

**6.** The accession process went hand-in-hand with domestic reforms, and the accession package provided blueprints for additional work as Cambodia joined the WTO. Through its decision to anchor trade policies in the multilateral trading system (MTS) embodied in the WTO, the Royal Government provided a predictable environment for investors, traders, and other stakeholders. WTO Membership also offers a platform and reference point for further, selective economic integration. Cambodia's impressive record of economic growth over the last two decades, aided by outward-looking trade policies, has visibly improved the standards of living of its population, and helped to lift a large segment of it out of poverty.

# TESTIMONIAL

"One of the most memorable things about Cambodia's accession to the WTO was indeed a timely completion of the accession negotiations prior to the expiry of the Agreement on Textiles and Clothing and all restrictions thereunder on January 1, 2005. The conclusion of the accession negotiations before 2005 has significantly boosted Cambodia's exports to the members' markets without quotas. In addition, the subsequent structural reforms in the economy and trade, as committed during the accession process, have played a crucial role in steering the Cambodia's economy toward sustainable, inclusive, and resilient growth, marking a great milestone in the modern history of the country."

**H.E. Kitti Settha Bundit CHAM Prasidh,**

Former Minister of Commerce and

Chief Negotiator of Cambodia's Accession to the WTO

"Both as European Trade Commissioner and, later, as WTO DG, I have kept a vivid memory of the journey of Cambodia to its accession to the WTO, and of my own involvement in this endeavor. A memory of cooperation, determination, consistency, hard work, and skillful sequencing of the necessary economic reforms. After 20 years, I think that Cambodia is a living proof of how trade opening can work for the welfare of the people."

**Mr. Pascal Lamy,**

Former Director General of World Trade Organization (2005-2013)

# 2. CAMBODIA IN THE WTO

**7.** Cambodia has been participating actively in the work of the WTO since acceding in 2004 pursuant to Article XII of the WTO Agreement. Cambodia takes part in the work of all main WTO's committees and subcommittees, as well as of its higher bodies, such as its three Councils, and its Ministerial Conferences. It also partakes actively in negotiations, including on new issues such as fisheries, WTO and dispute settlement reforms, LDC graduation, trade and environment, and on some of the new Joint Initiatives: Cambodia participates in the joint initiative on *Investment Facilitation for Development*, and in the environmental initiative on *Plastics pollution and environmentally sustainable plastics trade*. Cambodia is a member of several of the negotiations groups, including the following: Asian developing members, ASEAN, G-90, and Least-developed countries (LDCs). Cambodia accords at least MFN treatment to trading partners, including non-WTO Members, and has shared its experience and national good practices with Members, through its interventions in Committees and Subcommittees, and working groups.

**8.** Cambodia places serious interest in and fully understands the benefits of the multilateral trading system (MTS). As such, it established a permanent Mission to the WTO and other international organizations in 2017, the first LDC to do so. Also in 2017, Cambodia assumed the role of coordinator of the LDC group and as such it has been the focal point supporting the LDC group in various topics/issues, including Duty-Free Quota Free (DFQF) market access and WTO reform. In sum, Cambodia has actively pursued the interest of the LDC group in the WTO. In the Eleventh WTO Ministerial Conference in Buenos Aires, in December 2017, Cambodia on behalf of the LDC Group issued a communication emphasizing that special and differential treatment for developing countries, particularly LDCs, was central for the credibility and efficiency of the MTS. Cambodia stressed the special needs of post-acceded LDCs to address the impact of the accession process, and called for the elimination of all forms of trade distorting domestic support in agriculture. Cambodia noted that the principle of special and differential treatment should be an integral part of all future negotiations including on fisheries subsidies,

which LDCs supported, and called upon Members to fully implement the decisions in favour of LDCs, adopted in previous Ministerial Conferences.[1]

**9.** Cambodia accepted the 2005 Protocol Amending the TRIPS Agreement on 1 November 2011, and the 2014 Protocol concerning the Trade Facilitation Agreement on 12 February 2016. Cambodia accepted the WTO TBT code of good practice in 2017. On 6 May 2024, Cambodia deposited its document of acceptance of the Fisheries Agreement and continues to engage actively in the negotiations on phase 2 on this agreement.[2]

